សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ការចាត់ចែងរក្សាការពារ
# រំលែងរូបសំណងជាបណ្ដោះអាសន្នអចលនវត្ថុ

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ៖

និស្សិតឈ្មោះ លោក **ម៉ូល គីមសេង**

កញ្ញា **ខាត់ សុផាន្នា**

សាស្ត្រាចារ្យណែនាំ៖

លោកសាស្ត្រាចារ្យ **ម៉ៅ មុន្នីណា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២១

ឆ្នាំសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការចាត់ចែងរក្សាការពារ

# រឹបអូសជាបណ្ដោះអាសន្នអចលនវត្ថុ

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ៖

និស្សិតឈ្មោះ   លោក **ប៉ូល គីមសេង**

កញ្ញា **ខាត់ សុផាន្នា**

សាស្ត្រាចារ្យណែនាំ៖

លោកសាស្ត្រាចារ្យ **ម៉ៅ បុណ្ណា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២១

ឆ្នាំសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ម៉ូល គីមសេង** និងឈ្មោះ **ខាត់ សុផាន្នា** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២១ លេខកូដថ្នាក់L៤C៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ៖

១. លោកឪពុក **ឈន ម៉ូល** និងអ្នកម្តាយ **ទ្រី គីមហ៊ុន**។

២. លោកឪពុក **លន ធឿន** និងអ្នកម្តាយ **ទ៉ាន់ ចាន់ពី**។

សូមសម្តែងនូវការគោរព និងដឹងគុណជាទីបំផុត ដែលបានបង្កើត ព្រមទាំងបំពេញករណីយកិច្ចជាឪពុកម្តាយដ៏មានព្រហ្មវិហារធម៌សម្រាប់យើងខ្ញុំ និងបានអនុញ្ញាតឱ្យយើងខ្ញុំទទួលបានការសិក្សាអប់រំ ដោយលោកទាំងពីរតែងតែប្រៀនប្រដៅ ជ្រោមជ្រែង គាំទ្រ ទំនុកបម្រុងទាំងប្រាក់កាក់ សម្ភារៈសិក្សា និងការផ្គត់ផ្គង់ផ្សេងៗទៀតច្រើនរាប់មិនអស់ ចំពោះគុណបំណាច់យ៉ាងធំធេងនេះ យើងខ្ញុំនឹងមិនអាចបំភ្លេចឡើយ។

សូមថ្លែងអំណរគុណជូនចំពោះ **ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងសាស្ត្រាចារ្យផ្នែកនីតិសាស្ត្រគ្រប់រូប** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់ឱកាសឱ្យយើងខ្ញុំទទួលបានការសិក្សាអប់រំដ៏ល្អឥតខ្ចោះ ហើយតែងតែខិតខំបង្ហាត់បង្រៀនអស់ពីកម្លាំងកាយ និងកម្លាំងចិត្ត មិនបានខ្វល់ពីសុខភាពឡើយ។

យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេសជូនលោកសាស្ត្រាចារ្យ **ម៉ៅ បុណ្ណា** ជាសាស្ត្រាចារ្យណែនាំសារណា ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការពន្យល់ ណែនាំ ត្រួតពិនិត្យ និងព្យាយាមក្នុងការកែលំអកិច្ចការស្រាវជ្រាវនេះ តាំងពីចំណុចចាប់ផ្តើមរហូតមកដល់ទីបញ្ចប់ ហើយទទួលបានផលជាទីគាប់ចិត្ត។

ជាទីបញ្ចប់ យើងខ្ញុំសូមជូនពរសាធុការជូនចំពោះ **មាតាបិតា ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោកសាស្ត្រាចារ្យ លោកស្រីសាស្ត្រាចារ្យ និងនិស្សិត** ព្រមទាំងក្រុមគ្រួសារ ឱ្យជួបតែសេចក្តីសុខ សេចក្តីចម្រើន មានសុខភាពល្អ ជៀសផុតពីជំងឺរាតត្បាតកាចសាហាវទាំងឡាយ ដែលកើតឡើងនាពេលបច្ចុប្បន្ននេះ ជាពិសេសសូមគោរពជូននូវពុទ្ធិពរទាំង ០៤ (បួន) ប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

សូម **មាតាបិតា ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោកសាស្ត្រាចារ្យ លោកស្រីសាស្ត្រាចារ្យ និងនិស្សិត** ព្រមទាំងក្រុមគ្រួសារ ទទួលយកការជូនពរពីសំណាក់យើងខ្ញុំដោយការគោរពដ៏ខ្ពង់ខ្ពស់។

# អារម្ភកថា

ក្នុងអំឡុងពេល០៤(បួន)ឆ្នាំ ដែលយើងខ្ញុំបានខិតខំសិក្សាជំនាញនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចកន្លងមក ជាលទ្ធផល ការខិតខំនោះបានផ្តល់មកវិញចំណេះដឹងទាំងផ្នែកទ្រឹស្តី និងផ្នែកអនុវត្ត រួមទាំងបានផ្តល់បទពិសោធន៍ដល់យើងខ្ញុំជាច្រើនអនេក។ ពេលវេលាបញ្ចប់ការសិក្សាផ្នែកនីតិសាស្ត្រក្នុងកម្រិតបរិញ្ញាបត្រក៏បានមកដល់ ទន្ទឹមនឹងនេះសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបានផ្តល់ឱកាសឱ្យយើងខ្ញុំបានរៀបចំស្រាវជ្រាវ និងរៀបរៀងសារណាមួយនេះឡើង ដើម្បីទុកជាស្នាដៃសម្រាប់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រ និងតម្កល់ទុកជាឯកសារជូនសិស្សានុសិស្សជំនាន់ក្រោយ។ ក្នុងសារណានេះផ្ទាល់យើងខ្ញុំទាំងពីរនាក់បានជ្រើសរើសយកប្រធានបទផ្នែកនីតិវិធីរដ្ឋប្បវេណីពាក់ព័ន្ធ "**ការចាត់ចែងរក្សាការពាររឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ**" ដោយសារតែនីតិវិធីនេះត្រូវបានគេនិយមប្រើប្រាស់យ៉ាងខ្លាំងក្នុងវិស័យនីតិសាស្ត្រ ហើយការសិក្សាប្រធានបទនេះ យើងខ្ញុំបានលើកយកគ្រប់ដំណាក់កាលទាំងអស់នៃនីតិវិធីចាត់ចែងរក្សាការពាររឹបអូសជាបណ្តោះអាសន្ន ដូចជាការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន និងការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន។

យើងខ្ញុំសង្ឃឹមថាកិច្ចការស្រាវជ្រាវមួយនេះ នឹងក្លាយជាឯកសារដែលផ្តល់ចំណេះដឹងពាក់ព័ន្ធការចាត់ចែងរក្សាការពាររឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ ដល់ប្រជាប្រិយមិត្តអ្នកអាន និងនិស្សិតដែលមានបំណងសិក្សាស្វែងយល់ប្រធានបទមួយនេះ។ ជាបទពិសោធន៍របស់យើងខ្ញុំផ្ទាល់ ការសិក្សាពីក្រមនីតិវិធីរដ្ឋប្បវេណី គឺមានភាពលំបាកខ្លាំងណាស់បើគ្មានការចង្អុលបង្ហាញតឹកតាងដែលបញ្ជាក់ពីអង្គហេតុនោះ ហេតុដូច្នេះហើយសារណាមួយនេះ យើងខ្ញុំបានព្យាយាមរៀបរៀងដោយយកចិត្តទុកដាក់បំផុត ដោយមានការលើកយកមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត មកធ្វើការបកស្រាយ និងចង្អុលបង្ហាញឱ្យជាក់ច្បាស់បញ្ហាទាំងអស់នោះ។ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាឯកសារនេះនឹងអាចផ្តល់ភាពងាយស្រួលទៅដល់ប្រជាប្រិយមិត្តអ្នកអាន និងនិស្សិតដើម្បីសិក្សាស្រាវជ្រាវបន្ត។

ជាចុងក្រោយយើងខ្ញុំពិតជាមោទនភាពខ្លាំងណាស់ បើឯកសារនេះបានជួយសម្រួលដល់ការសិក្សារបស់ប្រជាប្រិយមិត្តអ្នកអាន និងនិស្សិត ហើយយើងខ្ញុំសូមធ្វើការអភ័យទោសទុកជាមុន បើកំហុសឆ្គងដែលពុំបានព្រៀងទុកបានកើតឡើងដោយប្រការណាមួយ និងស្វាគមន៍ជានិច្ចរាល់ការរិះគន់ក្នុងន័យស្ថាបនា ពីព្រោះបើយើងខ្ញុំបានព្យាយាមផ្ចិតផ្ចង់អស់ពីកម្លាំងកាយ កម្លាំងចិត្ត យ៉ាងណាក៏ដោយ ក៏នៅតែមានចំណុចខ្វះខាតណាមួយកើតឡើងជាក់ជាមិនខាន ហេតុដូច្នេះយើងខ្ញុំរីករាយនឹងទទួលយកមតិរិះគន់ក្នុងន័យស្ថាបនា និងព្យាយាមកែប្រែនូវកំហុសឆ្គងទាំងនោះ ដើម្បីឱ្យសារណាមួយនេះឱ្យកាន់តែមានភាពល្អប្រសើរ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** .......... ០១

១. លំនាំបញ្ហានៃការស្រាវជ្រាវ .......... ០២

២. ចំណោទបញ្ហានៃការដោះស្រាយ .......... ០២

៣. គោលបំណងនៃការស្រាវជ្រាវ .......... ០២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ .......... ០២

៥. សារៈសំខាន់នៃការស្រាវជ្រាវ .......... ០៣

៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ .......... ០៣

## ជំពូកទី១

## សញ្ញាណទូទៅ

**ផ្នែកទី១៖ ទិដ្ឋភាពទូទៅនៃការចាត់ចែងរក្សាការពារ និងអចលនវត្ថុ** .......... ០៤

១. ទិដ្ឋភាពទូទៅនៃការចាត់ចែងរក្សាការពារ .......... ០៤

១.១. គោលបំណង .......... ០៥

១.២. ប្រភេទនៃការចាត់ចែងរក្សាការពារ .......... ០៥

១.២.១. ការរឹបអូសជាបណ្តោះអាសន្ន .......... ០៥

១.២.២. ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ .......... ០៦

១.២.៣. ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន .......... ០៦

២. ទិដ្ឋភាពទូទៅនៃអចលនវត្ថុ .......... ០៧

២.១. អចលនវត្ថុតាមច្បាប់ភូមិបាល .......... ០៧

២.២. អចលនវត្ថុតាមក្រមរដ្ឋប្បវេណី .......... ០៧

២.៣. អចលនវត្ថុតាមក្រមនីតិវិធីរដ្ឋប្បវេណី .......... ០៨

**ផ្នែកទី២៖ លក្ខណៈសម្បត្តិនៃការរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ** .......... ០៨

១. និយមន័យនៃការរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ .......... ០៨

២. ចរិតលក្ខណៈនៃការរឹបអូសជាបណ្តោះអាសន្ន .......... ០៩

២.១. លក្ខណៈបណ្តោះអាសន្ន .......... ០៩

២.២. លក្ខណៈបន្ទាន់ ..................... ០៩
២.៣. លក្ខណៈបន្ទាប់បន្សំ ..................... ១០
២.៤. លក្ខណៈសម្ងាត់ ..................... ១០

## ជំពូកទី២

## ការរឹបអូសជាបណ្ដោះអាសន្នអចលនវត្ថុ

**ផ្នែកទី១៖ ការស្នើសុំដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន** ..................... ១១
១. លក្ខខណ្ឌនៃការរឹបអូសជាបណ្ដោះអាសន្ន ..................... ១១
១.១. លក្ខខណ្ឌសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ..................... ១២
១.២. លក្ខខណ្ឌនៃភាពចាំបាច់ ..................... ១២
២. តុលាការមានសមត្ថកិច្ច ..................... ១៣
២.១. តុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងអង្គសេចក្ដី ..................... ១៣
២.២. សាលាដំបូងដែលអចលនវត្ថុត្រូវបានរឹបអូសជាបណ្ដោះអាសន្នស្ថិតនៅ..................... ១៤
៣. ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ..................... ១៤
៣.១. ទម្រង់នៃពាក្យសុំ ..................... ១៤
៣.២. ពន្ធដាក់ពាក្យសុំ..................... ១៥
៤. សេចក្ដីបញ្ជាក់ដំបូង ..................... ១៥
៤.១. ចំណុចដែលត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូង ..................... ១៦
៤.១.១. សិទ្ធិ ឬទំនាក់ទំនងគតិយុត្តត្រូវបានរក្សាការពារ ..................... ១៦
៤.១.២. ភាពចាំបាច់នៃការរក្សាការពារ ..................... ១៦
៤.២. ទម្រង់នៃសេចក្ដីបញ្ជាក់ដំបូង ..................... ១៧
**ផ្នែកទី២៖ ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នអចលនវត្ថុ** ..................... ១៨
១. ចំណុចដែលត្រូវសរសេរក្នុងដីកាសម្រេច..................... ១៨
១.១. អត្តសញ្ញាណភាគី ..................... ១៨
១.២. ខ្លឹមសារនៃការទាមទារ ..................... ១៨
១.៣. សំអាងហេតុ ..................... ១៨
១.៤. សេចក្ដីសម្រេចបញ្ចប់ ..................... ១៩

២. ប្រភេទប្រាក់ក្នុងការរឹបអូសជាបណ្ដោះអាសន្ន ...... ១៩
២.១. ប្រាក់ប្រដាប់ក្ដី ...... ១៩
២.២. ប្រាតិភោគ ...... ២០
២.៣. ប្រាក់រំដោះ ...... ២១

## ជំពូកទី៣
## ការអនុវត្ត ការផ្អាក និងការលុបចោលការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន

**ផ្នែកទី១៖ ការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន** ...... ២២
១. លក្ខខណ្ឌនៃការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ...... ២២
១.១. អំឡុងពេលនៃការអនុវត្ត ...... ២២
១.២. ភាពមិនចាំបាច់នៃរូបមន្តអនុវត្ត ...... ២៣
១.៣. ការបញ្ជូនដីកាសម្រេច ...... ២៤
២. តុលាការអនុវត្ត ...... ២៤
៣. ពាក្យសុំឱ្យអនុវត្ត ...... ២៥
៣.១. ទម្រង់នៃពាក្យសុំឱ្យអនុវត្ត ...... ២៥
៣.២. ឯកសារភ្ជាប់ ...... ២៦
៤. ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ...... ២៧
៤.១. ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជីចំពោះអចលនវត្ថុដែលបានចុះបញ្ជីដីធ្លី ...... ២៨
៤.២. ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជីចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីដីធ្លី ...... ២៩
**ផ្នែកទី២៖ ការផ្អាក និងការលុបចោលការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន** ...... ៣១
១. ការផ្អាកការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ...... ៣១
១.១. ខ្លឹមសារនៃការផ្អាកការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ...... ៣១
១.២. ហេតុដែលនាំឱ្យផ្អាកការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ...... ៣១
២. ការលុបចោលការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ...... ៣៤
២.១. ខ្លឹមសារនៃការលុបចោលការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ...... ៣៤
២.២. ហេតុដែលនាំឱ្យលុបចោលការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ...... ៣៥
៣. ការផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ...... ៣៥

# ជំពូកទី៤
# ការប្តឹងតវ៉ាក្នុងរឿងក្តីរបស់ជាបណ្តោះអាសន្ន

**ផ្នែកទី១៖ ការប្តឹងតវ៉ាក្នុងរឿងក្តីរបស់ជាបណ្តោះអាសន្ន**............ ៣៧
១. ការតវ៉ា ............ ៣៧
១.១. ការវិនិច្ឆ័យ ............ ៣៧
១.២. ការបញ្ចប់ការវិនិច្ឆ័យ ............ ៣៨
១.៣. ដីកាសម្រេចអំពីពាក្យសុំតវ៉ា ............ ៣៨
២. ការប្តឹងជំទាស់ ............ ៣៩
២.១. ដីកាសម្រេចដែលអាចប្តឹងជំទាស់............ ៣៩
២.១.១. ដីកាសម្រេចអំពីពាក្យសុំតវ៉ា ............ ៣៩
២.១.២. ដីកាសម្រេចអំពីពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរក្សាការពារ ............ ៤០
២.១.៣. ដីកាសម្រេចលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ............ ៤០
២.២. នីតិវិធីនៃបណ្តឹងជំទាស់ ............ ៤១
**ផ្នែកទី២៖ ការលុបចោលដីកាសម្រេចរបស់ជាបណ្តោះអាសន្ន** ............ ៤២
១. ការមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី ............ ៤២
២. ការផ្លាស់ប្តូរស្ថានភាព ............ ៤៣
**សេចក្តីសន្និដ្ឋាន** ............ ៤៤
**អនុសាសន៍**............ ៤៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ក្នុងសង្គមរស់នៅប្រចាំថ្ងៃ មនុស្សមិនអាចរស់នៅដោយគ្មានការប្រាស្រ័យទាក់ទងគ្នាបាននោះទេ ដោយការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកជាភាពចាំបាច់បំផុតនៅក្នុងសង្គមនិងមិនអាចខ្វះបាន។ ពាក្យថាសង្គមសំដៅលើស្ថានភាពដែលមនុស្សរស់នៅប្រមូលផ្តុំគ្នាច្រើន និងមានទំនាក់ទំនងទៅវិញទៅមកជាប្រចាំថ្ងៃ ហើយដើម្បីដឹកនាំ និងគ្រប់គ្រងសង្គមមួយឱ្យមានស្ថេរភាព សង្គមនោះត្រូវបង្កើតច្បាប់ ដែលច្បាប់ដើរតួយ៉ាងសំខាន់ក្នុងការដឹកនាំសង្គមជាតិមួយឱ្យមានភាពរីកចំរើន និងសន្តិភាព។ ជាគោលការណ៍ច្បាប់ត្រូវបានបង្កើតឡើងសម្រាប់ការពារសិទ្ធិ សេរីភាពរបស់បុគ្គលគ្រប់រូបដែលរស់នៅក្នុងសង្គម គួរបញ្ជាក់ដែរថាបុគ្គលម្នាក់ៗ អាចប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងរង្វង់ដែលច្បាប់អនុញ្ញាតតែប៉ុណ្ណោះ ការប្រើប្រាស់សិទ្ធិរបស់ខ្លួនមិនបានត្រឹមត្រូវអាចបណ្តាលឱ្យប៉ះពាល់ដល់សិទ្ធិ ឬផលប្រយោជន៍របស់អ្នកដទៃ។ ក្នុងសង្គមរស់នៅប្រចាំថ្ងៃរូបភាពនៃការបំពានសិទ្ធិមានលក្ខណៈច្រើនបែបច្រើនសណ្ឋានផ្សេងៗគ្នា អាស្រ័យទៅតាមអង្គហេតុជាក់ស្តែង ហើយបុគ្គលដែលទទួលរងការបំពានសិទ្ធិ អាចដាក់ពាក្យបណ្តឹងទៅតុលាការរដ្ឋប្បវេណី ដើម្បីដោះស្រាយបញ្ហាទាំងនោះជូនខ្លួនបាន។ មុនឈានដល់ការអនុវត្តសិទ្ធិទាមទាររបស់ខ្លួន ភាគីត្រូវទទួលបានសាលក្រម សាលដីកាស្ថាពរ ដែលត្រូវបានស្គាល់ថាជាលិខិតអនុវត្តតាមរយៈនីតិវិធីនៃបណ្តឹងអង្គសេចក្តីជាមុនសិន ប៉ុន្តែដោយសារនីតិវិធីនេះមានលក្ខណៈស្មុគស្មាញ និងចំណាយពេលវេលាយូរ ទើបច្បាប់បានបង្កើតឱ្យមាននីតិវិធីចាត់ចែងរក្សាការពារដាច់ដោយឡែកមួយទៀត ដើម្បីធានាឱ្យការអនុវត្តសិទ្ធិទាមទារនាពេលអនាគតអាចប្រព្រឹត្តិទៅបាន។ ការចាត់ចែងរក្សាការពារ ត្រូវបានបែងចែងជាបីប្រភេទរួមមាន ការរឹបអូសជាបណ្តោះអាសន្ន ការចាត់ចែងជាបណ្តោះអាសន្នវត្ថុដែលជាកម្មវត្ថុនៃវិវាទ និងការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ប៉ុន្តែក្នុងកិច្ចការស្រាវជ្រាវនេះនឹងជ្រើសយកតែ **"ការចាត់ចែងរក្សាការពាររឹបអូសជាបណ្តោះអាសន្ន"** តែប៉ុណ្ណោះ គួរបញ្ជាក់ដែរថា កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្នអាចជា អចលនវត្ថុ ចលនវត្ថុ នាវា សិទ្ធិលើបំណុល ឬសិទ្ធិលើទ្រព្យសម្បត្តិ ដោយឡែកសារណានេះនឹងលើកយកតែករណីកម្មវត្ថុជា **"អចលនវត្ថុ"** តែមួយគត់មកសិក្សាស្វែងយល់ឱ្យកាន់តែច្បាស់ពោលគឺ **"ការចាត់ចែងរក្សាការពាររឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ"** ដោយសិក្សាចាប់ពីដំណាក់កាលដំបូង រហូតដល់ដំណាក់កាលចុងក្រោយនៃការរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ ព្រមទាំងបង្ហាញពីនីតិវិធីលម្អិតដែលម្ចាស់បំណុលត្រូវប្រតិបត្តិ ដើម្បីទទួលបានដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ ហើយកិច្ចការស្រាវជ្រាវមួយនេះនឹងឆ្លើយតបចំពោះបញ្ហាមួយចំនួនដែលប្រជាជនទូទៅគប្បីយល់ដឹង ដើម្បីជៀសវាងពីការបាត់បង់ប្រយោជន៍ស្របច្បាប់របស់ខ្លួនដោយសារបញ្ហាទាំងអស់នោះ។

**២.ចំណោទបញ្ហានៃការដោះស្រាយ**

ការចាត់ចែងរក្សាការពាររឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ ត្រូវបានប្រើប្រាស់តែក្នុងករណីដែលសិទ្ធិទាមទារជាសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់តែប៉ុណ្ណោះ ពោលបើម្ចាស់បំណុលបានដាក់ពាក្យបណ្តឹងទាមទារឱ្យកូនបំណុលសងប្រាក់ដែលជំពាក់ ហើយនៅពេលឈ្នះបណ្តឹងអង្គសេចក្តី ម្ចាស់បំណុលអាចដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំនូវអចលនវត្ថុរបស់កូនបំណុល ដើម្បីឱ្យតុលាការសម្រេចលក់ដោយបង្ខំអចលនវត្ថុនោះបាន ប៉ុន្តែនីតិវិធីនៃបណ្តឹងអង្គសេចក្តីជានីតិវិធីដែលត្រូវចំណាយពេលវេលាយូរដើម្បីដោះស្រាយ ហើយក្នុងករណីនេះប្រាកដណាស់កូនបំណុលនឹងដឹងខ្លួនមុន និងអាចព្យាយាមបង្វែរអចលនវត្ថុរបស់ខ្លួន ក្នុងគោលបំណងគេចវេសពីការអនុវត្តលក់ដោយបង្ខំតាមផ្លូវតុលាការបានយ៉ាងស្រួល ដើម្បីបង្ការហានិភ័យទាំងនេះម្ចាស់បំណុលចាំបាច់ស្នើសុំឱ្យតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុរបស់កូនបំណុល ក្នុងកិច្ចការស្រាវជ្រាវនេះនឹងបង្ហាញថាតើការចាត់ចែងរក្សាការពាររឹបអូសជាបណ្តោះអាសន្ន មានខ្លឹមសារយ៉ាងដូចម្តេច? ហើយដើម្បីឱ្យតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តើម្ចាស់បំណុលត្រូវប្រតិបត្តិលក្ខខណ្ឌអ្វីខ្លះ? តើការអនុវត្តរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ ត្រូវធ្វើឡើងដោយរបៀបណា? តើអាជ្ញាធរណាខ្លះដែលមានសមត្ថកិច្ចពាក់ព័ន្ធនឹងការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន? តើការរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុអាចនឹងត្រូវប្តឹងតវ៉ាក្នុងកាលៈទេសៈណាខ្លះ? តើមានមូលហេតុអ្វីខ្លះដែលនាំឱ្យការអនុវត្តរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ ត្រូវបានតុលាការសម្រេចឱ្យផ្អាក ឬលុបចោល?

**៣. គោលបំណងនៃការស្រាវជ្រាវ**

ការចាត់ចែងរក្សាការពាររឹបអូសជាបណ្តោះអាសន្ន ជានីតិវិធីមួយដែលមានបញ្ញត្តិក្នុងក្រមនីតិវិធីរដ្ឋប្បវេណីដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ក្នុងគន្ថីទី៧ ហើយគោលបំណងនៃការស្រាវជ្រាវនេះ គឺដើម្បីសិក្សាស្វែងយល់ឱ្យកាន់តែស៊ីជម្រៅពីនីតិវិធីរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុទាំងផ្នែកទ្រឹស្តី និងការអនុវត្តជាក់ស្តែង លើសពីនេះទៀតការចងក្រងសារណានេះឡើងក៏ជួយឱ្យសិស្សានុសិស្ស មិត្តអ្នកអានគ្រប់មជ្ឈដ្ឋានទាំងអស់ រឹតតែមានប្រភពឯកសារច្រើនបន្ថែមទៀត សម្រាប់សិក្សាស្រាវជ្រាវទាក់ទងនឹងប្រធានបទនេះឱ្យបានទូលំទូលាយ។ ម្យ៉ាងវិញទៀតការសិក្សាស្រាវជ្រាវនេះ នឹងចូលរួមចំណែកយ៉ាងសំខាន់ ក្នុងវិស័យនីតិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ឱ្យមានភាពរីកចម្រើន និងថ្កើនថ្កានតទៅមុខជាដរាប ដោយសារណានេះនឹងជួយសម្រួលដល់ការសិក្សារបស់និស្សិតជំនាន់ក្រោយ ដែលជាទំពាំងស្នងឫស្សីអាចសិក្សាស្រាវជ្រាវ និងប្រើប្រាស់ឯកសារមួយនេះតាមដែលអាចធ្វើទៅបាន។

**៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ**

ការចាត់ចែងរក្សាការពារ មានរហូតដល់ ០៣ (បី) ប្រភេទហើយមាននីតិវិធីដោយឡែកៗពីគ្នានឹងត្រូវបាន

ប្រើប្រាស់ក្នុងកាលៈទេសៈផ្សេងៗពីគ្នា។ ក្នុងកិច្ចការស្រាវជ្រាវមួយនេះបានជ្រើសរើសយកប្រធានបទពាក់ព័ន្ធនឹង **"ការចាត់ចែងរក្សាការពាររឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ"** ដូចធ្លាប់បានបញ្ជាក់រួចមកហើយការរឹបអូសជាបណ្តោះអាសន្នអាចធ្វើទៅបានចំពោះកម្មវត្ថុជាច្រើនទៀត សម្រាប់ប្រធានបទនេះនឹងសិក្សាតែក្នុងករណីដែលកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្នជា **"អចលនវត្ថុ"** តែប៉ុណ្ណោះ ពោលអចលនវត្ថុត្រង់ចំណុចនេះសំដៅតែលើ **"ដី"** តែមួយគត់ដោយនឹងសិក្សាទាំងករណីអចលនវត្ថុជា **"អចលនវត្ថុដែលបានចុះបញ្ជីដីធ្លី(ប្លង់រឹង)"** និងករណីអចលនវត្ថុជា **"អចលនវត្ថុដែលមិនទាន់បានចុះបញ្ជីដីធ្លី(ប្លង់ទន់)"** ផងដែរ។

**៥. សារៈសំខាន់នៃការស្រាវជ្រាវ**

កិច្ចការស្រាវជ្រាវនេះ គឺជាសមិទ្ធផលដែលបានព្យាយាមអស់ពីលទ្ធភាពដើម្បីរៀបរៀង ដោយបានសម្រឹតសម្រាំងយ៉ាងយកចិត្តទុកដាក់បំផុត ហេតុនេះប្រជាប្រិយមិត្តអ្នកអាន និងនិស្សិតអាចទទួលបានចំណេះដឹងបន្ថែមពាក់ព័ន្ធនឹងការចាត់ចែងរក្សាការពាររឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ បន្ទាប់ពីបានសិក្សាអត្ថបទមួយនេះចប់។ ហើយខ្លឹមសារដែលមានក្នុងកិច្ចការស្រាវជ្រាវមួយនេះ ប្រាកដណាស់ប្រជាប្រិយមិត្តអ្នកអាន និងនិស្សិតអាចយកទៅប្រើប្រាស់ដើម្បីដោះស្រាយបញ្ហាផ្សេងៗ ដែលកើតមានឡើងក្នុងជីវភាពរស់នៅជាក់ស្តែងនាពេលបច្ចុប្បន្ននេះបាន។

**៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ**

ចំពោះការសិក្សាលើប្រធានបទនេះ ត្រូវបានបែងចែកចេញជាជំពូកចំនួន ០៤ (បួន) រួមមាន៖

**ជំពូកទី១៖ សញ្ញាណទូទៅ។**

**ជំពូកទី២៖ ការរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ។**

**ជំពូកទី៣៖ ការអនុវត្ត ការផ្អាក និងការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន។**

**ជំពូកទី៤៖ ការប្តឹងតវ៉ាក្នុងរឿងក្តីរឹបអូសជាបណ្តោះអាសន្ន។**

ក្នុងជំពូកនីមួយៗនឹងចែកចេញជា ០២ (ពីរ) ផ្នែកផ្សេងទៀត ដោយផ្នែកនីមួយៗត្រូវបានបែងចែកជាចំណុចតូចៗជាច្រើនទៀត ដើម្បីយកធ្វើជាទឡ្ហីករណ៍ក្នុងការបកស្រាយអត្ថន័យក្នុងជំពូកនីមួយៗខាងលើនេះឱ្យបានក្បោះក្បាយនឹងកាន់ស៊ីជម្រៅ ព្រមទាំងមានការលើកជាឧទាហរណ៍ខ្លីៗ ដើម្បីប្រជាប្រិយមិត្តអ្នកអាន និងនិស្សិតងាយស្រួលយល់ និងចាប់បានផងដែរ។

# ជំពូកទី១

# សញ្ញាណទូទៅ

# ជំពូកទី១
# សញ្ញាណទូទៅ

ជាចំណុចចាប់ផ្តើមនៃការសិក្សាពីការចាត់ចែងរក្សាការពាររឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ[1] គួរគប្បីសិក្សាស្វែងយល់ពី **(ផ្នែកទី១) ទិដ្ឋភាពទូទៅនៃការចាត់ចែងរក្សាការពារ និងអចលនវត្ថុ** ដែលនឹងបង្ហាញពីសញ្ញាណទូទៅពាក់ព័ន្ធនឹងការចាត់ចែងរក្សាការពារ ព្រមទាំងខ្លឹមសារទូទៅនៃអចលនវត្ថុផងដែរ ហើយចំពោះចំណុចស្តីពី **(ផ្នែកទី២) លក្ខណៈសម្បត្តិនៃការរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ** នឹងមានសម្រាយបញ្ជាក់ពីនិយមន័យ រួមទាំងចរិតលក្ខណៈពិសេសមួយចំនួននៃការរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុថែមទៀតផង។

## ផ្នែកទី១៖ ទិដ្ឋភាពទូទៅនៃការចាត់ចែងរក្សាការពារ និងអចលនវត្ថុ

ក្នុងផ្នែកនេះនឹងមានការលើកយកសញ្ញាណគតិយុត្តចំនួន ០២ (ពីរ) មកធ្វើជាទឡ្ហីករណ៍ដើម្បីបកស្រាយទិដ្ឋភាពទូទៅនៃការចាត់ចែងរក្សាការពារ ព្រមទាំងអចលនវត្ថុ ដែលត្រូវបានប្បញ្ញត្តិក្នុងលិខិតបទដ្ឋានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជារួមមាន (១) **ទិដ្ឋភាពទូទៅនៃការចាត់ចែងរក្សាការពារ** នឹងបកស្រាយពីគោលបំណងប្រភេទនៃការចាត់ចែងរក្សាការពារ និងចំណុចស្តីពី (២) **ទិដ្ឋភាពទូទៅនៃអចលនវត្ថុ** នឹងបង្ហាញឱ្យបានជ្រាបច្បាស់ពីសញ្ញាណទូទៅមួយចំនួនពាក់ព័ន្ធនឹងអចលនវត្ថុ។

### ១. ទិដ្ឋភាពទូទៅនៃការចាត់ចែងរក្សាការពារ

នីតិវិធីចាត់ចែងរក្សាការពារ បានចាត់គ្រឹះក្នុងវិស័យនីតិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជាអស់រយៈពេលជាយូរណាស់មកហើយ គ្រាន់តែមិនទាន់មានការប្បញ្ញត្តិឱ្យច្បាស់លាស់ពីគោលបំណង ឬប្រភេទនៃការចាត់ចែងរក្សាការពារ ឬនីតិវិធីដែលត្រូវប្រតិបត្តិនោះទេ ពោលគឺត្រូវអនុវត្តតាមសារាចរណែនាំចេញដោយក្រសួងយុត្តិធម៌តែប៉ុណ្ណោះ[2] ក្នុងនោះក៏មានការណែនាំពីនីតិវិធីមួយស្តីពី **"វិធានការបណ្តោះអាសន្ន"** ដែលអាចពិនិត្យបានថានីតិវិធីនេះមានលក្ខណៈស្រដៀងនឹង **"ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន"** ដែលបានបញ្ញត្តិក្នុងក្រមនីតិវិធីរដ្ឋប្បវេណីបច្ចុប្បន្ននេះ[3]។ ដើម្បីឆ្លើយតបនឹងការរីកចម្រើននៃវិស័យនីតិសាស្ត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ បានប្បញ្ញត្តិពាក់ព័ន្ធនឹងការចាត់ចែងរក្សាការពារ ដូច្នេះគប្បីសិក្សាស្វែងយល់ពីមូលដ្ឋានគ្រឹះធំៗមួយចំនួនពាក់ព័ន្ធនឹងការចាត់ចែងរក្សាការពារ ដែលបានប្បញ្ញត្តិក្នុងក្រមនីតិវិធីរដ្ឋប្បវេណីរួមមាន (១.១) **គោលបំណង** ព្រមទាំង (១.២) **ប្រភេទនៃការចាត់ចែងរក្សាការពារ** ដូចខាងក្រោម។

[1] **ការចាត់ចែងរក្សាការពាររឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ** ឬអាចហៅម្យ៉ាងទៀតថា **ការរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ** ដែលពាក្យទាំងពីរនេះអាចប្រើប្រាស់បានដូចគ្នា ហើយនៅក្នុងសារណានេះអ្នកសិក្សានឹងបានឃើញការប្រើប្រាស់ពាក្យទាំងពីរនេះ

[2] សារាចររបស់ក្រសួងយុត្តិធម៌ស្តីពីសេចក្តីណែនាំអំពីនីតិវិធីរដ្ឋប្បវេណី, លេខ ០៤សរចង៤, ០៨ កញ្ញា ១៩៨៤

[3] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

**១.១. គោលបំណង**

បើនិយាយដល់ការចាត់ចែងរក្សាការពារ គួរគប្បីយល់ដឹងថានីតិវិធីមួយនេះមានគោលបំណងសំខាន់ការពារសិទ្ធិរបស់បុគ្គលណាម្នាក់ តាមរយៈការកម្រិតសិទ្ធិចាត់ចែងទ្រព្យសម្បត្តិ ឬធ្វើឱ្យស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុលមានស្ថេរភាព ឬកំណត់នូវឋានៈជាបណ្ដោះអាសន្ន ដើម្បីជៀសវាងពីកាលៈទេសៈដែលការអនុវត្តដោយបង្ខំនាពេលអនាគតនឹងមិនអាចធ្វើទៅបាន ឬលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំដោយសារការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុល ឬបើបារម្ភថាការខូចខាតយ៉ាងធ្ងន់ធ្ងរនឹងកើតមានឡើងដោយសកម្មភាពរបស់កូនបំណុល ឬគ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគី ដោយសារវិវាទទំនាក់ទំនងនៃសិទ្ធិ ក្នុងករណីហេតុទាំងអស់នេះបានកើតឡើង ឬមានភាគរយខ្ពស់ថានឹងអាចកើតឡើង បុគ្គលដែលមានបំណងចង់រក្សាការពារសិទ្ធិរបស់ខ្លួន អាចទាមទារឱ្យតុលាការសម្រេចចាត់ចែងរក្សាការពារចំពោះកម្មវត្ថុទាំងអស់នេះបាន។[4]

**១.២. ប្រភេទនៃការចាត់ចែងរក្សាការពារ**

ការចាត់ចែងរក្សាការពារ ត្រូវបានបែងចែកជា ០៣ (បី) ប្រភេទផ្សេងៗគ្នា ដែលប្រភេទនីមួយៗមាននីតិវិធីមិនដូចគ្នានោះទេ ហើយត្រូវបានប្រើប្រាស់ស្របតាមអង្គហេតុ និងកាលៈទេសៈនៃរឿងក្ដីរដ្ឋប្បវេណី មានន័យថាមុនពេលស្នើសុំឱ្យតុលាការចេញដីកាសម្រេចរក្សាការពារ ម្ចាស់បំណុលត្រូវពិចារណាឱ្យបានច្បាស់លាស់ពីអង្គហេតុរបស់ខ្លួន ហើយត្រូវសរសេរខ្លឹមសារដែលខ្លួនស្នើសុំឱ្យតុលាការចេញឱ្យបានត្រឹមត្រូវ មុនពេលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារជូនតុលាការ ដើម្បីជៀសវាងការប្រើប្រាស់ការចាត់ចែងរក្សាការពារ ដែលមានអត្ថន័យផ្ទុយពីបណ្ដឹងអង្គសេចក្ដី ជាហេតុបណ្ដាលនាំឱ្យខាតបង់ពេលវេលា និងប្រយោជន៍ស្របច្បាប់របស់ខ្លួនហើយការចាត់ចែងរក្សាការពារទាំង ០៣ (បី) ប្រភេទ ដែលបានបញ្ជាក់ខាងលើនេះរួមមាន **(១.២.១) ការរឹបអូសជាបណ្ដោះអាសន្ន** ហើយ **(១.២.២) ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ** និង **(១.២.៣) ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន**។

**១.២.១. ការរឹបអូសជាបណ្ដោះអាសន្ន**

ការរឹបអូសជាបណ្ដោះអាសន្ន គឺជាការចាត់ចែងដែលកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុលដើម្បីរក្សាការពារការអនុវត្តដោយបង្ខំសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់។[5] មានន័យថា ការរឹបអូសជាបណ្ដោះអាសន្ន សំដៅដល់វិធានមួយដែលប្រើប្រាស់ដើម្បីការពារជាបណ្ដោះអាសន្នសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ដោយកម្រិតសិទ្ធិចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុលនឹង

[4] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣០

[5] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣០ ចំណុច ក

អាចធ្វើឡើងចំពោះ អចលនវត្ថុ ចលនវត្ថុ នាវា សិទ្ធិលើបំណុល សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត។ **ឧទាហរណ៍៖** ខ ជំពាក់ប្រាក់ ក ចំនួន២០លានរៀល ហើយ ខ មានប្រាក់ក្នុងធនាគារប្រហែល២៥លានរៀល ក្នុងនីតិវិធីបណ្ដឹងទាមទារប្រាក់កម្ចី ត្រូវចំណាយពេលវេលាច្រើនដោយសារ ក អាចនឹងប្រឈមនឹងការបាត់បង់ផលប្រយោជន៍ក្នុងករណី ខ ទៅធនាគារដកប្រាក់កម្ចីទាំងអស់។ ក អាចការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្លួន ដោយស្នើសុំឱ្យតុលាការសម្រេចរឹបអូសជាបណ្ដោះអាសន្នប្រាក់កម្ចីរបស់ ខ ដែលមានក្នុងធនាគារដើម្បីទុកអនុវត្តសិទ្ធិពេលដែល ក ឈ្នះបណ្ដឹងអង្គសេចក្ដីនាពេលអនាគត។

**១.២.២. ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ**

ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ត្រូវប្រើប្រាស់ដើម្បីរក្សាទុកស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិ ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុ។[6] មានន័យថាការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ គឺជាវិធានការមួយដើម្បីការពារការខូចខាតដែលអាចកើតឡើងផ្ទាល់ចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ដោយរក្សាការពារវត្ថុជាកម្មវត្ថុនៃវិវាទកុំឱ្យប្រែប្រួលស្ថានភាពបច្ចុប្បន្ន។ **ឧទាហរណ៍៖** ក បានទិញរថយន្តពី ខ ក្នុងតម្លៃ១០លានរៀល ហើយ ក បានប្រគល់ប្រាក់គ្រប់ចំនួនឱ្យ ខ រួចរាល់អស់ហើយ ប៉ុន្តែ ខ បែរជាមិនព្រមប្រគល់រថយន្តតាមការកំណត់។ ដោយសារតែបណ្ដឹងទាមទារឱ្យប្រគល់រថយន្តត្រូវប្រើប្រាស់ពេលវេលាយូរដូច្នេះ ក អាចស្នើសុំឱ្យតុលាការសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះរថយន្តនោះ ដោយហាមឃាត់ ខ ពីការលក់ ឬផ្ទេររថយន្តទៅតតិយជនណាផ្សេង។

**១.២.៣. ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន**

ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន សំដៅដល់ការចាត់ចែងដែលកំណត់ស្ថានភាពជាបណ្ដោះអាសន្នរហូតដល់មានសាលក្រម ឬសាលដីកាចូលជាស្ថាពរ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ។[7] ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន គឺជានីតិវិធីមួយដើម្បីកំណត់ជាបណ្ដោះអាសន្ននូវឋានៈរបស់ភាគីរហូតដល់មានសេចក្ដីសម្រេចជាស្ថាពរ ដើម្បីបង្ការការខូចខាតធ្ងន់ធ្ងរដោយសារការកំណត់ពីទំនាក់ទំនងសិទ្ធិយឺតយ៉ាវ។ **ឧទាហរណ៍៖** ក ជាម្ចាស់អចលនវត្ថុមួយកន្លែងក្រោយមកទៀត ខ បានមកសាងសង់សំណង់លើអចលនវត្ថុនោះ ដោយសារបណ្ដឹងបង្គាប់ឱ្យរុះរើសំណង់ចេញត្រូវការពេលវេលាយូរ។ ក អាចស្នើសុំឱ្យតុលាការសម្រេចហាមឃាត់មិនឱ្យសាងសង់ ឬបន្តការ

---

[6] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣១ កថាខណ្ឌ ខ

[7] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣១ កថាខណ្ឌ គ

សាងសង់សំណង់ជាបណ្តោះអាសន្នបាន ប្រសិនបើមិនដូច្នេះទេ ក អាចនឹងជួបប្រទះភាពលំបាកនៅពេលអនុវត្តដោយបង្ខំជាក់ជាមិនខាន ដោយសារស្ថានភាពសំណង់ត្រូវបានបញ្ចប់ការសាងសង់។

## ២. ទិដ្ឋភាពទូទៅនៃអចលនវត្ថុ

សព្វថ្ងៃនេះវិស័យអចលនវត្ថុនៅព្រះរាជាណាចក្រកម្ពុជា កំពុងតែរីកចម្រើនស្ទើរតែគ្រប់ទីកន្លែងជាពិសេសនៅតាមទីប្រជុំជនដូចជារាជធានីភ្នំពេញ ឬទីក្រុង ឬបណ្តាទីរួមខេត្តនានា ទន្ទឹមនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនេះក៏បានទាក់ទាញឱ្យអ្នកវិនិយោគជាតិ និងអន្តរជាតិជាច្រើនបានដាក់ទុនលើវិស័យអចលនទ្រព្យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ហើយចំណុចនេះនឹងបង្ហាញឱ្យបានស្គាល់ពីអចលនវត្ថុរឹតតែច្បាស់បន្ថែមទៀត ដោយមានការលើកយកលិខិតបទដ្ឋានគតិយុត្តមួយចំនួន ដែលបានបញ្ញត្តិពីអចលនវត្ថុមកបកស្រាយ រួមមាន **(២.១) អចលនវត្ថុតាមច្បាប់ភូមិបាល** និង **(២.២) អចលនវត្ថុតាមក្រមរដ្ឋប្បវេណី** ព្រមទាំង **(២.៣) អចលនវត្ថុតាមក្រមនីតិវិធីរដ្ឋប្បវេណី**។

### ២.១. អចលនវត្ថុតាមច្បាប់ភូមិបាល

តាមច្បាប់ភូមិបាល អចលនវត្ថុបានបែងចែកជា ០៣ (បី) ប្រភេទដូចជា៖ អចលនវត្ថុតាំងពីកំណើត និងអចលនវត្ថុតាមការកំណត់របស់ច្បាប់ ព្រមទាំងអចលនវត្ថុតាមភ័ព្វវាសនា។ **អចលនវត្ថុតាំងពីកំណើត** រួមមានដីធម្មជាតិ ដីព្រៃឈើ ដីដាំដុះ ដីទុកទំនេរ ឬមិនអាចដាំដុះ ដីលិចទឹកដោយទឹកនៅនឹង ឬទឹកកំពុងហូរ និងសំណង់ ឬការរៀបចំទាំងឡាយដែលស្ថិតនៅជាប់ហ្នឹងមួយកន្លែងកើតឡើង មិនអាចរំកិល ឬផ្លាស់ទីបានឡើយ។[8] **អចលនវត្ថុតាមការកំណត់ដោយច្បាប់** គឺជាសិទ្ធិភណ្ឌិក[9]ទាំងឡាយលើអចលនវត្ថុ ឬលើចលនវត្ថុដែលច្បាប់បានសន្មតថាជាអចលនវត្ថុ។[10] **អចលនវត្ថុតាមភ័ព្វវាសនា** សំដៅដល់វត្ថុជាប់នឹងដី ឬបញ្ចូលជាមួយសំណង់ទាំងឡាយ ដែលមិនអាចបំបែកចេញបានដោយមិនធ្វើឱ្យខូចខាត ឬមិនដូរសភាពដើម ដូចជា៖ កង្ហារ ពិដាន ម៉ាស៊ីន ត្រជាក់ កញ្ចក់ ឧបករណ៍តែងលំអ ជាដើម។[11]

### ២.២. អចលនវត្ថុតាមក្រមរដ្ឋប្បវេណី

តាមក្រមរដ្ឋប្បវេណី វត្ថុសំដៅលើវត្ថុដែលមានរូបរាង ជាសារធាតុឧស្ម័ន ជាសារធាតុរាវ ជាសារធាតុរឹង ដែលត្រូវបានចែកចេញជា ០២ (ពីរ) គឺចលនវត្ថុ និងអចលនវត្ថុ។[12] អចលនវត្ថុ ត្រូវបានគេសំដៅលើ ដីធ្លី និងវត្ថុដែលជាប់នឹងដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបាន ដូចជាអគារ សំណង់ ដំណាំ រុក្ខជាតិ ជាអាទិ៍ ហើយ

---

[8] ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា២ កថាខណ្ឌទី២

[9] សិទ្ធិភណ្ឌិក (សិទ្ធិប្រត្យក្ស) សំដៅលើសិទ្ធិមួយដែលច្បាប់បានផ្តល់ឱ្យម្ចាស់កម្មសិទ្ធិគ្រប់គ្រង ដោយផ្ទាល់មុខលើវត្ថុ ហើយមានលក្ខណៈដាច់ខាតដែលអាចអះអាងចំពោះបុគ្គលដទៃទៀតបាន និងកម្មសិទ្ធិករមានសិទ្ធិក្នុងការចាត់ចែង និងគ្រប់គ្រងដោយសេរី

[10] ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា២ កថាខណ្ឌទី៤

[11] ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា២ កថាខណ្ឌទី៣

[12] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣១, ០៨ ធ្នូ ២០០៧, មាត្រា១២០

ចំពោះវត្ថុផ្សេងៗ ក្រៅពីនេះទៀត ត្រូវបានរាប់បញ្ចូលជាចលនវត្ថុ។[13] ដូចបានបញ្ជាក់រួចហើយថាវត្ថុដែលជាប់នឹងដីក៏ត្រូវបូកបញ្ចូនជាអចលនវត្ថុដែរ ហើយជារឿយៗត្រូវបានស្គាល់ថាជា **"សមាសភាពនៃដី"** មានអត្ថន័យថាវត្ថុដែលក្លាយជាភាគមួយនៃដី ជាពិសេសអគារ ឬសំណង់ដែលនៅជាប់នៅលើដី ហើយមិនអាចប្តូរកន្លែងបាន ឬពូជដែលបានសាបនៅលើដី ដំណាំដែលបានដាំ រុក្ខជាតិដែលរស់នៅលើដី ឬជាសមាសធាតុដែលមិនអាចបំបែកចេញពីដីបាន។[14]

### ២.៣. អចលនវត្ថុតាមក្រមនីតិវិធីរដ្ឋប្បវេណី

តាមក្រមនីតិវិធីរដ្ឋប្បវេណី អចលនវត្ថុសំដៅលើដី អគារដែលត្រូវបានចុះបញ្ជី ចំណែកនៃកម្មសិទ្ធិអវិភាគលើដី ឬអគារនោះ សិទ្ធិជួលអចិន្ត្រៃយ៍ និងផលុបភោគ ដែលត្រូវបានចុះបញ្ជី និងចំណែកនៃសិទ្ធិទាំងនេះដែលជាសិទ្ធិរួម។[15] ដូច្នេះហើយអ្នកសិក្សាអាចសង្កេតបានថាអចលនវត្ថុក្នុងន័យដែលបានរៀបរាប់ទាំងនេះសុទ្ធសឹងតែជាសិទ្ធិប្រត្យក្ស រួមមាន សិទ្ធិលើកម្មសិទ្ធិ កម្មសិទ្ធិអវិភាគ សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគជាដើម ហើយអចលនវត្ថុនេះក៏ជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំដែរ។

## ផ្នែកទី២៖ លក្ខណៈសម្បត្តិនៃការរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ

ដើម្បីបកស្រាយផ្នែកនេះឱ្យបានក្បោះក្បាយ និងកាន់តែស៊ីជម្រៅ គួរគប្បីលើកយកចំណុចចំនួន ០២ (ពីរ) ធ្វើជាទឡ្ហីករណ៍ក្នុងការបកស្រាយរួមមាន (១) **និយមន័យនៃការរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ** ដោយមានបញ្ជាក់ពីខ្លឹមសារនៃប្រធានបទទាំងមូលព្រមទាំង (២) **ចរិតលក្ខណៈ** នឹងបង្ហាញពីចរិតលក្ខណៈពិសេសមួយចំនួននៃការរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ។

### ១. និយមន័យនៃការរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ

ការរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ គឺជាវិធានមួយដែលម្ចាស់បំណុលស្នើសុំឱ្យតុលាការប្រើប្រាស់អំណាចខ្លួន ដើម្បីធានាដល់ការការពារសិទ្ធិរបស់ខ្លួន តាមរយៈការរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុណាមួយរបស់កូនបំណុលដោយកម្រិតសិទ្ធិចាត់ចែងអចលនវត្ថុ ដោយសារសកម្មភាពមួយចំនួនរបស់កូនបំណុលបានបណ្តាលឱ្យអចលនវត្ថុធ្លាក់តម្លៃជាខ្លាំង ឬធ្វើឱ្យការអនុវត្តដោយបង្ខំនាពេលអនាគតនឹងមិនអាចប្រព្រឹត្តទៅបាន ឬលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តលក់ដោយបង្ខំ។ ការរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ ត្រូវបានប្រើប្រាស់តែក្នុងករណីដែលសិទ្ធិទាមទារជាសិទ្ធិលើបំណុលមានគោលបំណងឱ្យសងជាប្រាក់តែប៉ុណ្ណោះ ហើយវិធានការនេះមានគោលបំណងសំខាន់ ដើម្បីធានាឱ្យការអនុវត្តដោយបង្ខំនាពេលអនាគត នឹងអាចអនុវត្តទៅបានដោយគ្មានឧបសគ្គណាមួយមករារាំង។

---

[13] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣១, ០៨ ធ្នូ ២០០៧, មាត្រា១២០ កថាខណ្ឌទី១ កថាខណ្ឌទី២ និងកថាខណ្ឌទី៣

[14] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣១, ០៨ ធ្នូ ២០០៧, មាត្រា១២២

[15] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤១៧

## ២. ចរិតលក្ខណៈនៃការរឹបអូសជាបណ្តោះអាសន្ន

ការរឹបអូសជាបណ្តោះអាសន្ន គឺជានីតិវិធីមួយដែលមានលក្ខណៈពិសេសខុសប្លែកពីនីតិវិធីដទៃទៀត ដែលគួរសិក្សាឱ្យគ្រប់ជ្រុងជ្រោយ ហើយចំណុចដែលខ្វះមិនបាននោះគឺចរិតលក្ខណៈនៃការរឹបអូសជាបណ្តោះអាសន្នរួមមាន (២.១) **លក្ខណៈបណ្តោះអាសន្ន** និង (២.២) **លក្ខណៈបន្ទាន់** ព្រមទាំង (២.៣) **លក្ខណៈបន្ទាប់បន្សំ** ចុងក្រោយ (២.៤) **លក្ខណៈសម្ងាត់** ដែលចរិតលក្ខណៈពិសេសទាំងអស់នេះ ត្រូវបានដកស្រង់ចេញពីក្រមនីតិវិធីរដ្ឋប្បវេណីនេះឯង។[16]

### ២.១. លក្ខណៈបណ្តោះអាសន្ន

ការរឹបអូសជាបណ្តោះអាសន្ន ជានីតិវិធីដែលមានលក្ខណៈបណ្តោះអាសន្ន[17] មានន័យថាការរឹបអូសជាបណ្តោះអាសន្ន ពុំមានឥទ្ធិពលលើការសម្រេចសេចក្តីនៅក្នុងបណ្តឹងអង្គសេចក្តី ឬធ្វើឱ្យមានការប្រែប្រួលលើការសម្រេចសេចក្តីឡើយ។ ទោះបីជាមានការរឹបអូសជាបណ្តោះអាសន្នក៏ដោយ ក៏សិទ្ធិលើបំណុល ឬសិទ្ធិទាមទារផ្សេងទៀតលើបណ្តឹងអង្គសេចក្តីមិនទាន់ត្រូវបានបញ្ជាក់ពីអត្ថិភាព ឬនត្ថិភាពឡើយ គឺការរឹបអូសជាបណ្តោះអាសន្ន គ្រាន់តែជានីតិវិធីដែលបង្កើតឡើងសម្រាប់ការពារផលប្រយោជន៍ជាបណ្តោះអាសន្នតែប៉ុណ្ណោះ មិនមែនមានន័យថា ម្ចាស់បំណុលមានសិទ្ធិទាំងស្រុងចំពោះអចលនវត្ថុ ដែលត្រូវបានរឹបអូសជាបណ្តោះអាសន្ននោះទេ ហើយក៏មិនមែនមានន័យថាកូនបំណុលបានបាត់បង់សិទ្ធិចាត់ចែងទាំងស្រុង ចំពោះអចលនវត្ថុរបស់ខ្លួនដែរ ពោលគឺគ្រាន់តែច្បាប់បានកម្រិតសិទ្ធិចាត់ចែងអចលនវត្ថុនោះតែប៉ុណ្ណោះ។ ម្ចាស់បំណុលមិនអាចយកការរឹបអូសជាបណ្តោះអាសន្នមកអះអាងបាននោះទេ បើបណ្តឹងអង្គសេចក្តីរបស់ខ្លួនបានចាញ់ដោយសាលក្រមសាលដីកាស្ថាពរ ដោយសារការរឹបអូសជាបណ្តោះអាសន្នមានអានុភាពជាបណ្តោះអាសន្ន ស្របទៅបណ្តឹងអង្គសេចក្តី ដោយគ្រាន់តែកម្រិតសិទ្ធិចាត់ចែងអចលនវត្ថុរបស់កូនបំណុលជាបណ្តោះអាសន្នប៉ុណ្ណោះ ដូច្នេះម្ចាស់បំណុលមិនអាចយកការរឹបអូសជាបណ្តោះអាសន្នមកអះអាងថាខ្លួនមានសិទ្ធិលើអចលនវត្ថុបានឡើយ។

### ២.២. លក្ខណៈបន្ទាន់

ការរឹបអូសជាបណ្តោះអាសន្ន គឺមានលក្ខណៈបន្ទាន់ប្រញាប់ និងអនុវត្តឱ្យបានលឿនបំផុត[18] ពីព្រោះការរឹបអូសជាបណ្តោះអាសន្ន ត្រូវបានបង្កើតឡើងដើម្បីការពារផលប្រយោជន៍ស្របច្បាប់ ឬការពារការខូចខាតដែលរំពឹងទុកថានឹងកើតមានឡើងនាពេលអនាគត ហេតុនេះហើយទើបតុលាការកម្រនឹងកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ណាស់ ដោយតុលាការជ្រើសយកតែនីតិវិធីសាកសួរម្ចាស់បំណុល និងសម្រេចសេចក្តីតាមរយៈសេចក្តីបញ្ជាក់ដំបូងរបស់ម្ចាស់បំណុលតែប៉ុណ្ណោះ ដោយសារថាមានភាពងាយស្រួល

[16] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣១ មាត្រា៥៥៧ មាត្រា៥៦២

[17] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣១

[18] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦២

ក្នុងដំណើរការនីតិវិធី និងចំណេញពេលវេលាសម្រាប់ម្ចាស់បំណុល ហើយដើម្បីឆ្លើយតបចំពោះសកម្មភាពចាត់ចែងអចលនវត្ថុរបស់កូនបំណុលឱ្យទាន់ពេលវេលា។ ចំពោះនីតិវិធីក្នុងការសាកសួរម្ចាស់បំណុល គឺមិនមានភាពស្មុគស្មាញឡើយ ដោយតុលាការគ្រាន់តែធ្វើការពិនិត្យភស្តុតាង និងសេចក្តីបញ្ជាក់ដំបូងជាការស្រេច ដែលសេចក្តីបញ្ជាក់ដំបូងត្រូវធ្វើឡើងដោយផ្អែកលើភស្តុតាង ដែលតុលាការអាចធ្វើការពិនិត្យបានភ្លាមៗ។ នៅក្នុងនីតិវិធីរឹបអូសជាបណ្តោះអាសន្នពេលវេលាគឺមានសារៈសំខាន់ខ្លាំងណាស់ ដោយហេតុថាបើនីតិវិធីនេះត្រូវការពេលវេលាយូរសម្រាប់សម្រេចសេចក្តីនោះម្ចាស់បំណុលងាយស្រួលនឹងទទួលរងការខូចខាត ឬប៉ះពាល់ដល់ប្រយោជន៍ខ្លាំង ហេតុដូច្នេះនីតិវិធីនេះត្រូវតែអនុវត្តឱ្យបានរហ័សបំផុត ពីព្រោះថាបើម្ចាស់បំណុលបានឈ្នះបណ្តឹងអង្គសេចក្តីក៏ដោយ ប្រសិនបើអចលនវត្ថុនោះត្រូវបានចាត់ចែងរួចហើយ នោះការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើទៅបាន ឬលំបាកយ៉ាងខ្លាំងក្នុងអនុវត្តដោយបង្ខំ។

### ២.៣. លក្ខណៈបន្ទាប់បន្សំ

ការរឹបអូសជាបណ្តោះអាសន្ន គឺជានីតិវិធីបន្ទាប់បន្សំចំពោះបណ្តឹងអង្គសេចក្តី[19] ដូចបានដឹងហើយថាការរឹបអូសជាបណ្តោះអាសន្នជានីតិវិធីបណ្តោះអាសន្ន ពុំមានឥទ្ធិពលលើបណ្តឹងអង្គសេចក្តីនោះទេ បើទោះបីជាមានការរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុណាមួយរបស់កូនបំណុលក៏ពិតមែន ប៉ុន្តែក្នុងករណីដែលម្ចាស់បំណុលមិនបានដាក់ពាក្យបណ្តឹងអង្គសេចក្តី តាមពេលវេលាដែលកំណត់ដោយតុលាការនោះទេ តុលាការនឹងចេញដីកាសម្រេចលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តាមរយៈពាក្យសុំជាលាយល័ក្ខណ៍អក្សររបស់កូនបំណុល។[20] ថ្វីបើការរឹបអូសជាបណ្តោះអាសន្នមានលក្ខណៈជាបណ្តោះអាសន្នពិតមែន ប៉ុន្តែសិទ្ធិចាត់ចែងអចលនវត្ថុរបស់កូនបំណុលក៏ត្រូវបានកម្រិតជាបណ្តោះអាសន្នដែរ ដូច្នេះបើម្ចាស់បំណុលមិនដាក់ពាក្យបណ្តឹងអង្គសេចក្តីនោះទេ កូនបំណុលនឹងប្រឈមមុខជាមួយការខាតបង់ផលប្រយោជន៍ស្របច្បាប់របស់ខ្លួន ការណ៍នេះបានសបញ្ជាក់ពីទំនាក់ទំនងគ្នារវាងការចាត់ចែងរក្សាការពារ និងបណ្តឹងអង្គសេចក្តី ដែលការចាត់ចែងរក្សាការពារនឹងត្រូវលុបចោលក្នុងករណីមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី ដែលបានបង្ហាញអំពីលក្ខណៈបន្ទាប់បន្សំនៃការចាត់ចែងរក្សាការពារចំពោះបណ្តឹងអង្គសេចក្តី។

### ២.៤. លក្ខណៈសម្ងាត់

ជាទូទៅម្ចាស់បំណុលតែងតែបារម្ភថា នៅពេលដែលតុលាការសម្រេចឱ្យខ្លួនឈ្នះបណ្តឹងអង្គសេចក្តីរួចហើយខ្លួននឹងមិនអាចអនុវត្តសិទ្ធិទាមទារបាន ដោយសារស្ថានភាពដែលកូនបំណុលបានដឹងខ្លួនជាមុនថាខ្លួននឹងចាញ់ក្តីនៅនីតិវិធីនៃបណ្តឹងអង្គសេចក្តី ហើយព្យាយាមចាត់ចែងអចលនវត្ថុរបស់ខ្លួន ក្នុងគោលបំណង

[19] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៥៧

[20] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៥៧ កថាខណ្ឌទី១

គេចវេសពីការទទួលខុសត្រូវ។ ដើម្បីឆ្លើយតបនឹងបញ្ហានេះនីតិវិធីរឹបអូសជាបណ្ដោះអាសន្ន ត្រូវមានលក្ខណៈសម្ងាត់ ដែលលក្ខណៈសម្ងាត់នេះបានលុបចោលគោលការណ៍ចំពោះមុខ មានន័យថាម្ចាស់បំណុលអាចអនុវត្តរឹបអូសជាបណ្ដោះអាសន្ន មុនពេលកូនបំណុលទទួលបានការបញ្ជូនដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន។[21] ទោះបីជានីតិវិធីនេះបានធ្វើឱ្យប៉ះពាល់ដល់គោលការណ៍ចំពោះមុខក៏ដោយ ក៏នីតិវិធីនេះមិនបានធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍កូនបំណុលដែរ ដោយតុលាការអាចបង្គាប់ឱ្យម្ចាស់បំណុលដាក់ប្រាតិភោគបើយល់ឃើញថាចាំបាច់។ តុលាការក៏អាចកំណត់កាលបរិច្ឆេទនៃការទាញហេតុផលផ្ទាល់មាត់ ពិនិត្យឯកសារ សាកសួរភាគីក៏បាន ប៉ុន្តែនីតិវិធីនេះត្រូវធ្វើឡើងជាសាធារណៈ ហើយអាចប្រឈមនឹងហានិភ័យខ្ពស់ ដោយសារកូនបំណុលអាចដឹងខ្លួនមុន ហើយព្យាយាមចាត់ចែងអចលនវត្ថុរបស់ខ្លួនមុនពេលមានការផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ដែលសកម្មភាពនេះអាចធ្វើឱ្យខូចប្រយោជន៍ម្ចាស់បំណុលយ៉ាងធ្ងន់ធ្ងរ ហេតុនេះដើម្បីជៀសវាងហានិភ័យទាំងអស់នេះ តុលាការតែងតែដំណើរការនីតិវិធីនេះដោយមានលក្ខណៈសម្ងាត់បំផុត។

[21] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦២

# ជំពូកទី២

# ការរឹបអូសជាបណ្ដោះអាសន្ន

# អចលនវត្ថុ

# ជំពូកទី២
# ការរឹបអូសជាបណ្ដោះអាសន្នអចលនវត្ថុ

បន្ទាប់ពីទទួលបានចំណេះដឹងពីសញ្ញាណទូទៅ ពាក់ព័ន្ធនឹងការរឹបអូសជាបណ្ដោះអាសន្នអចលនវត្ថុរួចមក ជាកិច្ចបន្ទាប់ជានីតិវិធីដែលម្ចាស់បំណុលស្នើសុំឱ្យតុលាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នជូនសាមីខ្លួនស្នើសុំដែលនឹងបកស្រាយក្នុង **(ផ្នែកទី១) ការស្នើសុំដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន** ដោយមានបង្ហាញពីលក្ខខណ្ឌតម្រូវផ្សេងៗ ព្រមទាំងកិច្ចការដែលម្ចាស់បំណុលត្រូវអនុវត្ត ដើម្បីឱ្យតុលាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ហើយក្នុង **(ផ្នែកទី២) ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន** នឹងមានបញ្ជាក់ពីចំណុចដែលត្រូវសរសេរក្នុងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន រួមទាំងប្រភេទប្រាក់ផ្សេងៗដែលបានប្បញ្ញត្តិក្នុងនីតិវិធីរឹបអូសជាបណ្ដោះអាសន្នដែរ។

## ផ្នែកទី១៖ ការស្នើសុំដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

នៅក្នុងចំណុចនេះផ្ដោតសំខាន់លើនីតិវិធីលម្អិតដែលម្ចាស់បំណុលត្រូវអនុវត្ត ដើម្បីតុលាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នដោយក្នុង (១) **លក្ខខណ្ឌនៃការរឹបអូសជាបណ្ដោះអាសន្ន** នឹងមានបង្ហាញអំពីលក្ខខណ្ឌតម្រូវដើម្បីស្នើសុំឱ្យមានការរឹបអូសជាបណ្ដោះអាសន្នអចលនវត្ថុ ហើយ (២) **តុលាការមានសមត្ថកិច្ច** នឹងបញ្ជាក់ថាតើម្ចាស់បំណុលត្រូវដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នទៅតុលាការណាចំណែក (៣) **ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន** នឹងបកស្រាយពីអត្ថន័យទូទៅ និងទម្រង់នៃពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ហើយចុងក្រោយនឹងមានបញ្ជាក់ពីទម្រង់ និងចំណុចដែលត្រូវធ្វើ (៤) **សេចក្ដីបញ្ជាក់ដំបូង** ផងដែរ។

### ១. លក្ខខណ្ឌនៃការរឹបអូសជាបណ្ដោះអាសន្ន

មុនចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នអចលនវត្ថុ តុលាការនឹងពិនិត្យមើលលក្ខខណ្ឌចំនួន ០២ (ពីរ) រួមមាន **(១.១) លក្ខខណ្ឌសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ** នឹងមានបញ្ជាក់ពីប្រភេទសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលត្រូវទទួលបានការរក្សាការពារដោយការរឹបអូសជាបណ្ដោះអាសន្ន ព្រមទាំងសញ្ញាណគតិយុត្តមួយចំនួនពាក់ព័ន្ធនឹងសិទ្ធិទាមទារនោះផងដែរ ហើយចំណុចស្ដីពី **(១.២) លក្ខខណ្ឌនៃភាពចាំបាច់** ដោយហេតុថាភាពចាំបាច់គឺជាលក្ខខណ្ឌសំខាន់មួយទៀត ដែលតុលាការនឹងត្រូវពិចារណាមុនពេលចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នអចលនវត្ថុ។ ហេតុដូច្នេះហើយគួរគប្បីសិក្សាអំពីលក្ខខណ្ឌទាំងនេះឱ្យបានច្បាស់លាស់ជាមុនសិន ទើបអាចកំណត់ថាតើហេតុអ្វីបានជាលក្ខខណ្ឌទាំង ០២ (ពីរ) ខាងលើមានសារៈសំខាន់ដល់ការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន។

**១.១. លក្ខខណ្ឌសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ**

សិទ្ធិដែលត្រូវបានរក្សាការពារ ដោយនីតិវិធីរឹបអូសជាបណ្ដោះអាសន្ន ត្រូវតែជាសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់[22] ជាទូទៅយើងអាចសម្គាល់ថាជាសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់តាមរយៈសិទ្ធិដែលម្ចាស់បំណុលមាន ហើយអាចទាមទារឱ្យកូនបំណុលសងមកវិញជាប្រាក់។ បើទោះបីជាសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់មានភ្ជាប់លក្ខខណ្ឌ ឬកំណត់ពេលក៏ដោយក៏ការរឹបអូសជាបណ្ដោះអាសន្នអាចធ្វើទៅបានដែរ។[23] គួរបញ្ជាក់ដែរថា **"លក្ខខណ្ឌ"** គឺជាព្រឹត្តិការណ៍ដែលកើតឡើងនាពេលអនាគត និងមិនមានភាពទៀងទាត់ឡើយ[24] ផ្ទុយពីនេះកាលមានព្រឹត្តិការណ៍ណាមួយជាក់លាក់ ព្រឹត្តិការណ៍នោះមិនអាចក្លាយជាលក្ខខណ្ឌបានទេ ហើយចំពោះ **"កំណត់ពេល"** ជាព្រឹត្តិការណ៍ដែលនឹងប្រាកដកើតឡើងនាពេលអនាគតត្រង់បន្ទាត់ពេលវេលាជាក់លាក់ណាមួយ។[25] សរុបជារួមមកនៅពេលកកើតសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ម្ចាស់បំណុលអាចស្នើសុំឱ្យតុលាការរឹបអូសជាបណ្ដោះអាសន្នអចលនវត្ថុ បើបានបំពេញលក្ខខណ្ឌចាំបាច់មួយទៀត ទោះបីជាសិទ្ធិទាមទារនោះជាសិទ្ធិលើទ្រព្យសម្បត្តិ ប៉ុន្តែត្រូវសម្រេចមកសងជាប្រាក់វិញក៏ការរឹបអូសជាបណ្ដោះអាសន្នអាចធ្វើទៅបានផងដែរ។

**១.២. លក្ខខណ្ឌភាពចាំបាច់**

ភាពចាំបាច់ សំដៅលើស្ថានភាពដែលការអនុវត្តដោយបង្ខំនាពេលអនាគត នឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកខ្លាំងក្នុងការអនុវត្តដោយបង្ខំ[26] ដោយសារកូនបំណុលបានរត់គេចខ្លួន ឬប្ដូរលំនៅឋានជាច្រើនលើកច្រើនសារ ឬលក់អចលនវត្ថុក្នុងតម្លៃទាប ឬស្ថានភាពផ្សេងទៀតដែលយល់ឃើញថានឹងក្លាយជាឧបសគ្គដល់ការអនុវត្តដោយបង្ខំនាពេលអនាគត។ ការរឹបអូសជាបណ្ដោះអាសន្ន មិនត្រឹមតែផ្អែកលើអត្ថិភាពនៃសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ប៉ុណ្ណោះទេ គឺរួមផ្សំទាំងភាពចាំបាច់មួយទៀត ដែលជាកត្តាសំខាន់ក្នុងការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នអចលនវត្ថុ។ ករណីដែលកូនបំណុលបានបដិសេធចំពោះសិទ្ធិដែលត្រូវបានរក្សាការពារ ឬឥរិយាបថដែលកូនបំណុលមិនព្រមអនុវត្តកាតព្វកិច្ច មិនត្រូវចាត់ទុកជាភាពចាំបាច់ទេ ពីព្រោះសកម្មភាពនេះមិនបង្កជាឧបសគ្គដល់ការអនុវត្តដោយបង្ខំឡើយ។ **ឧទាហរណ៍៖** ក បានបង្កើតកិច្ចសន្យាខ្ចីបរិភោគជាមួយ ខ ហើយបានដាក់អចលនវត្ថុ (ដី) ដើម្បីធានាដល់ការអនុវត្តកាតព្វកិច្ចរបស់ខ្លួនប៉ុន្តែ ខ មិនបានសង ក តាមពេលកំណត់នោះទេ ហើយបានប្រកាសលក់អចលនវត្ថុ (ដី) ដាក់ធានានោះ

---

[22] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣១ ចំណុចក និងមាត្រា៥៤៥ កថាខណ្ឌទី១

[23] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤៥ កថាខណ្ឌទី២

[24] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣១, ០៨ ធ្នូ ២០០៧, មាត្រា៣២៥ កថាខណ្ឌទី២

[25] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣១, ០៨ ធ្នូ ២០០៧, មាត្រា៣២៩

[26] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣១, ០៨ ធ្នូ ២០០៧, មាត្រា៥៤៥ កថាខណ្ឌទី១

ទៀត។ ជាដំណោះស្រាយ ក អាចស្នើសុំឱ្យតុលាការរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ (ដី) របស់ ខ បាន ដោយហេតុថា ក មានសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ហើយស្ថានភាពដែល ខ បាន ព្យាយាមចាត់ចែងអចលនវត្ថុ (ដី) ត្រូវបានចាត់ទុកថាជាភាពចាំបាច់ ដូច្នេះលក្ខខណ្ឌនៃការរឹបអូសជាបណ្តោះអាសន្នត្រូវបានបំពេញ។

## ២. តុលាការមានសមត្ថកិច្ច

ដូចបានដឹងហើយថា ការស្នើសុំឱ្យតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុត្រូវធ្វើឡើងតាមពាក្យសុំរបស់ម្ចាស់បំណុល សំណួរសួរថាតើម្ចាស់បំណុលត្រូវដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នទៅស្ថាប័នតុលាការណា? បើយោងតាមក្រមនីតិវិធីរដ្ឋប្បវេណី សមត្ថកិច្ចតុលាការចំពោះការរឹបអូសជាបណ្តោះអាសន្ន ត្រូវតែជាសមត្ថកិច្ចផ្តាច់មុខ។[27] តុលាការមានសមត្ថកិច្ចផ្តាច់មុខត្រង់ចំណុចនេះសំដៅទៅលើ **(១.១) តុលាការដែលមានសមត្ថកិច្ចលើបណ្តឹងអង្គសេចក្តី** និង **(១.២) សាលាដំបូងដែលអចលនវត្ថុត្រូវបានរឹបអូសជាបណ្តោះអាសន្នស្ថិតនៅ។**

### ២.១. តុលាការដែលមានសមត្ថកិច្ចលើបណ្តឹងអង្គសេចក្តី

ម្ចាស់បំណុលអាចដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ទៅតុលាការដែលមានសមត្ថកិច្ចលើបណ្តឹងអង្គសេចក្តី[28] ពោលគឺជាតុលាការដែលអាចទទួលដោយស្របច្បាប់យកពាក្យបណ្តឹងអង្គសេចក្តី មានសិទ្ធិវិនិច្ឆ័យរឿងក្តី ដោយការចេញសាលក្រម ឬសាលដីកា[29] មានន័យថាម្ចាស់បំណុលអាចដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ ទៅតុលាការដែលកំពុងចាត់ការនីតិវិធីនៃបណ្តឹងអង្គសេចក្តី ដូចដែលបានបង្ហាញនៅខាងក្រោមនេះ៖

ក. បើសាលាដំបូងរាជធានី ខេត្ត កំពុងចាត់ការនីតិវិធីនៃបណ្តឹងអង្គសេចក្តី ម្ចាស់បំណុលអាចដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ទៅសាលាដំបូងរាជធានី ខេត្តនោះបាន។

ខ. បើសាលាឧទ្ធរណ៍តំបន់ កំពុងចាត់ការនីតិវិធីនៃបណ្តឹងអង្គសេចក្តី ម្ចាស់បំណុលអាចដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ទៅសាលាឧទ្ធរណ៍នោះបាន។

គ. បើតុលាការកំពូល កំពុងចាត់ការនីតិវិធីនៃបណ្តឹងអង្គសេចក្តី ម្ចាស់បំណុលត្រូវដាក់ពាក្យសុំទៅសាលាដំបូងរាជធានីខេត្ត ដែលអចលនវត្ថុត្រូវបានរឹបអូសជាបណ្តោះអាសន្នស្ថិតនៅ។[30]

[27] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣៣

[28] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤០ កថាខណ្ឌទី១

[29] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧

[30] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤០ កថាខណ្ឌទី២

### ២.២. សាលាដំបូងដែលអចលនវត្ថុត្រូវបានរឹបអូសជាបណ្ដោះអាសន្នស្ថិតនៅ

ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន អាចដាក់ទៅសាលាដំបូងរាជធានី ខេត្តដែលមានសមត្ថកិច្ចលើទីកន្លែងដែលអចលនវត្ថុនឹងត្រូវរឹបអូសជាបណ្ដោះអាសន្នស្ថិតនៅផងដែរ[31] មានអត្ថន័យថាម្ចាស់បំណុលត្រូវកំណត់ពីទីតាំងអចលនវត្ថុ ដែលខ្លួនចង់ស្នើសុំឱ្យរឹបអូសជាបណ្ដោះអាសន្នឱ្យបានច្បាស់លាស់ បន្ទាប់មកអាចដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ទៅសាលាដំបូងរាជធានី ខេត្តដែលអចលនវត្ថុនឹងត្រូវរឹបអូសជាបណ្ដោះអាសន្នស្ថិតនៅ។

តាមរយៈការសិក្សាកន្លងមកបានបង្ហាញថា ម្ចាស់បំណុលអាចដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នអចលនវត្ថុទៅ **តុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងអង្គសេចក្ដី ឬ សាលាដំបូងដែលអចលនវត្ថុត្រូវបានរឹបអូសជាបណ្ដោះអាសន្នស្ថិតនៅ** ក៏បាន។ បន្ទាប់ពីទទួលពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នតុលាការនឹងពិនិត្យអំពីអត្ថិភាព ឬនត្ថិភាពនៃសមត្ថកិច្ចរបស់ខ្លួន បើរកឃើញថាខ្លួនមិនមានសមត្ថកិច្ចនោះទេ តុលាការត្រូវសម្រេចផ្ទេររឿងក្ដីនោះទៅតុលាការដែលមានសមត្ថកិច្ចវិញតាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិរបស់ខ្លួន។[32] ដូចបានដឹងមកហើយថាតុលាការមានសមត្ថកិច្ច ត្រូវតែជាសមត្ថកិច្ចផ្ដាច់មុខក៏ពិតមែនក៏ច្បាប់បានបើកសិទ្ធិឱ្យម្ចាស់បំណុលអាចជ្រើសរើសតុលាការមានសមត្ថកិច្ចបានដោយខ្លួនឯង ហេតុនេះមុនពេលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ម្ចាស់បំណុលត្រូវពិចារណាឱ្យបានច្បាស់លាស់ថាតើស្ថាប័នតុលាការណាដែលជាជម្រើសដ៏ល្អសម្រាប់ខ្លួន។

## ៣. ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

បន្ទាប់ពីបានស្វែងយល់ពីលក្ខខណ្ឌនៃការរឹបអូសជាបណ្ដោះអាសន្ន និងតុលាការមានសមត្ថកិច្ចរួចមក ជាកិច្ចបន្ទាប់គឺពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដោយម្ចាស់បំណុលត្រូវដាក់ពាក្យសុំនេះជាលាយល័ក្ខណ៍អក្សរ[33] ទៅតុលាការដែលបានរៀបរាប់នៅចំណុចស្ដីពីតុលាការមានសមត្ថកិច្ចខាងលើ ចំពោះទម្រង់នៃពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នអចលនវត្ថុ ត្រូវបានច្បាប់កំណត់ពីចំណុចដែលត្រូវសរសេរដោយមានបង្ហាញក្នុង (២.១) **ទម្រង់នៃពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន** លើសពីនេះទៅទៀតចំណុច (២.២) **ពន្ធដាក់ពាក្យសុំ** បង្ហាញតម្លៃពន្ធដែលត្រូវបង់នៅពេលដាក់ពាក្យសុំ។

### ៣.១. ទម្រង់នៃពាក្យសុំ

ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវសរសេរបញ្ជាក់ចំណុចដូចខាងក្រោមនេះ៖

ក. **ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយនឹងឈ្មោះ និងអាសយដ្ឋានរបស់អ្នក**

[31] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤០ កថាខណ្ឌទី១

[32] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣៩ និងមាត្រា១៩ កថាខណ្ឌទី១

[33] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣៤ ចំណុច ក

**តំណាង ដែលច្បាប់បានកំណត់៖** ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវបញ្ជាក់ឱ្យបានច្បាស់ពីអត្តសញ្ញាណរបស់ម្ចាស់បំណុល និងកូនបំណុល ក្នុងករណីមានអ្នកតំណាងដែលច្បាប់បានកំណត់ ឬប្រសិនបើមានអ្នកតំណាងដោយអាណត្តិ ត្រូវបញ្ជាក់ពីអត្តសញ្ញាណឱ្យបានច្បាស់លាស់។

ខ. **ខ្លឹមសារនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដែលម្ចាស់បំណុលទាមទារ៖** ម្ចាស់បំណុលត្រូវសរសេរបញ្ជាក់ទៅកាន់តុលាការឱ្យបានច្បាស់ពីខ្លឹមសារ ដែលទាមទារឱ្យតុលាការចេញ ដោយបញ្ជាក់ថាតើខ្លួនទាមទាររឹបអូសជាបណ្តោះអាសន្នអចលនវត្ថុមួយណា?

គ. **សិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលនឹងត្រូវបានរក្សាការពារ៖** ម្ចាស់បំណុលត្រូវសរសេរឱ្យបានច្បាស់ពីមូលហេតុនៃការកកើតសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ ឬសរសេរបញ្ជាក់ពីទំនាក់ទំនងសិទ្ធិ និងករណីយកិច្ចរវាងខ្លួន និងកូនបំណុល។

ឃ. **ភាពចាំបាច់នៃការរក្សាការពារ៖** ម្ចាស់បំណុលត្រូវសរសេរបញ្ជាក់ពីចំណុចសំខាន់ៗ ដែលជាភាពចាំបាច់ ដើម្បីឱ្យតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នមកឱ្យខ្លួន ជាទូទៅភាពចាំបាច់អាចជាសកម្មភាព នឹងបណ្តាលឱ្យការអនុវត្តដោយបង្ខំមិនអាចធ្វើទៅបាន ឬលំបាកក្នុងការអនុវត្តដោយបង្ខំនាពេលអនាគត[34]។

### ៣.២. ពន្ធដាក់ពាក្យសុំ

ពេលដាក់សុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ម្ចាស់បំណុលត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀលជូនតុលាការ។[35] ដោយការបង់ពន្ធនេះ ត្រូវធ្វើឡើងជាការបង់ជាប្រាក់នៅកន្លែងទទួលពាក្យសុំរបស់តុលាការ គួរបញ្ជាក់ដែរថាបើម្ចាស់បំណុលមិនបានបង់ពន្ធដាក់ពាក្យសុំនេះទេ ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននឹងត្រូវចាត់ទុកថាជាពាក្យសុំមិនស្របច្បាប់។[36]

### ៤. សេចក្តីបញ្ជាក់ដំបូង

សេចក្តីបញ្ជាក់ដំបូង ត្រូវធ្វើឡើងដោយភស្តុតាងដែលអាចពិនិត្យភ្លាមៗបាន[37] បន្ទាប់ពីម្ចាស់បំណុលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុរួចហើយ ម្ចាស់បំណុលត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងចំពោះចំណុចមួយចំនួន ដើម្បីឱ្យតុលាការយកធ្វើជាមូលដ្ឋានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដែលជាទូទៅម្ចាស់បំណុលតែងតែដាក់ឯកសារណាដែលតុលាការអាចធ្វើការពិនិត្យបានភ្លាមៗ ដោយ

---

[34] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤១ កថាខណ្ឌទី១

[35] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣៧ កថាខណ្ឌទី១

[36] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦១ កថាខណ្ឌទី៦ និងកថាខណ្ឌទី៧

[37] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៣១

មិនត្រូវការពេលវេលាយូរដើម្បីពិនិត្យភស្តុតាងទាំងនោះ។ ហេតុនេះហើយនឹងពិនិត្យមើលថាតើម្ចាស់បំណុលត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងចំណុចណាខ្លះ? ដែលមានបកស្រាយក្នុងចំណុច (៤.១) **ចំណុចដែលត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង** ព្រមទាំងចំណុច (៤.២) **ទម្រង់នៃសេចក្តីបញ្ជាក់ដំបូង** នឹងអនុញ្ញាតឱ្យបានស្គាល់ពីទម្រង់ទូទៅនៃសេចក្តីបញ្ជាក់ដំបូងដែលអ្នកវិជ្ជាជីវៈចូលចិត្តប្រើប្រាស់។

**៤.១. ចំណុចដែលត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង**

ចំណុចដែលត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង រួមមានសិទ្ធិ ឬទំនាក់ទំនងគតិយុត្តនឹងត្រូវបានរក្សាការពារ និងភាពចាំបាច់នៃការរក្សាការពារ។[38] ចំណុចទាំង ០២ (ពីរ) នេះច្បាប់បានកំណត់ឱ្យម្ចាស់បំណុលត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង ក្នុងគោលបំណងបញ្ជាក់ពីលក្ខខណ្ឌនៃការរឹបអូសជាបណ្តោះអាសន្នជូនតុលាការ ដើម្បីទាមទារឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុរបស់កូនបំណុល។ ដោយម្ចាស់បំណុលត្រូវបញ្ជាក់ពីលក្ខខណ្ឌទាំងពីរនេះឱ្យបានច្បាស់លាស់ដូចការបកស្រាយក្នុងចំណុច (៣.១.១) **សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ** ព្រមទាំង (៣.១.២) **ភាពចាំបាច់នៃការរក្សាការពារ** ខាងក្រោមនេះ។

**៤.១.១. សិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលត្រូវបានរក្សាការពារ**

ម្ចាស់បំណុលត្រូវបញ្ជាក់ឱ្យបានច្បាស់ពីហេតុនាំឱ្យកកើតសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវបានច្បាប់រក្សាការពារ ពោលគឺម្ចាស់បំណុលត្រូវសរសេរបញ្ជាក់ពីរបៀបដែលសិទ្ធិ ឬទំនាក់ទំនងគតិយុត្តរវាងខ្លួន និងកូនបំណុលកើតឡើងតាមរយៈកិច្ចសន្យា សាលក្រម សាលដីកាជាដើម រួមមកចំណុចទាំងអស់នេះ បានបញ្ជាក់ឱ្យតុលាការបានដឹងអំពីមូលហេតុនៃការកើតឡើងនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ព្រមទាំងគោលបំណងនៃការស្នើសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ថែមទៀតផង។ គួរបញ្ជាក់ដែរថាគោលបំណងសំខាន់នៃការធ្វើសេចក្តីបញ្ជាក់ដំបូងដោយសារតែការរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ គឺច្បាស់ណាស់ចង់ ឬមិនចង់សកម្មភាពនេះនឹងធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍របស់ម្ចាស់អចលនវត្ថុ ឬកូនបំណុល ហេតុដូច្នេះហើយទើបច្បាប់បង្គាប់ឱ្យម្ចាស់បំណុលដាក់សេចក្តីបញ្ជាក់ដំបូងដើម្បីបញ្ជាក់ពីហេតុការណ៍អស់ទាំងនេះ ជៀសវាងការសម្រេចសេចក្តីមិនបានត្រឹមត្រូវ។

**៤.១.២. ភាពចាំបាច់នៃការរក្សាការពារ**

ភាពចាំបាច់ តែងតែសំដៅលើស្ថានភាពដែលម្ចាស់បំណុលនឹងមិនអាចធ្វើការអនុវត្តដោយបង្ខំ ឬលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំនាពេលអនាគត ករណីនេះម្ចាស់បំណុលអាចបង្ហាញស្ថានភាពដែលកូនបំណុលព្យាយាមធ្វើឱ្យមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុរបស់ខ្លួន ហើយស្ថានភាពនោះនឹងជះឥទ្ធិពលដល់ការអនុវត្តដោយបង្ខំនាពេលអនាគត ហើយក៏ជាមូលហេតុដែលធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍

[38] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤១ កថាខណ្ឌទី៣

របស់ខ្លួនដែរ។ គួរបញ្ជាក់ថាតុលាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នអចលនវត្ថុ មិនត្រឹមតែផ្អែកលើសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារនោះទេ គឺមានភាពចាំបាច់មួយទៀតដែលតុលាការនឹងត្រូវពិនិត្យ ហើយភាពចាំបាច់ក៏អាចជាស្ថានភាពដែលគួរឱ្យបារម្ភដោយសកម្មភាពមិនប្រក្រតីរបស់កូនបំណុលដូចជាការព្យាយាមបង្វែរអចលនវត្ថុ ការធ្វើឱ្យធ្លាក់តម្លៃជាបរិមាណ ឬគុណភាព ការលក់ក្នុងតម្លៃថោក ការធ្វើឱ្យខូចខាត ឬបំបាត់ចោលអចលនវត្ថុ ជាអាទិ៍។

### ៤.២. ទម្រង់នៃសេចក្ដីបញ្ជាក់ដំបូង

ច្បាប់មិនបានកំណត់ពីទម្រង់នៃសេចក្ដីបញ្ជាក់ដំបូងទេ ប៉ុន្តែច្បាប់បានកំណត់អំពីចំណុចដែលត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូងរួមមាន **សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ** និង **ភាពចាំបាច់នៃការរក្សាការពារ** ប៉ុន្តែក្នុងការអនុវត្តជាក់ស្ដែងសេចក្ដីបញ្ជាក់ដំបូងអាចសរសេរចំណុចដូចជា៖

ក. ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ព្រមទាំងអ្នកតំណាងដោយអាណត្តិបើមាន។

ខ. សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងបានរក្សាការពារ ម្ចាស់បំណុលត្រូវសរសេរចំណុចនេះជាដាច់ខាតដូចបង្ហាញនៅ **(៤.១.១) នៃចំណុចដែលត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូង** ខាងលើ។[39]

គ. ភាពចាំបាច់នៃការរក្សាការពារ ម្ចាស់បំណុលត្រូវសរសេរចំណុចនេះជាដាច់ខាត ដូចបានបង្ហាញនៅ **(៤.១.២) នៃចំណុចដែលត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូង** ខាងលើនេះ។[40]

ឃ. អង្គច្បាប់ ចំណុចនេះម្ចាស់បំណុលអាចសរសេរពីបទប្បញ្ញត្តិច្បាប់ ដែលមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីគាំទ្រអង្គហេតុរបស់ខ្លួន។

ង. ភស្តុតាង ក្នុងផ្នែកនេះម្ចាស់បំណុលគប្បីសរសេរឱ្យបានច្បាស់លាស់អំពីអង្គហេតុ ព្រមទាំងសរសេរបញ្ជាក់ពីភស្តុតាងចំពោះហេតុនីមួយៗនោះផងដែរ[41] ដើម្បីឱ្យតុលាការងាយស្រួលក្នុងការពិនិត្យពីទំនាក់ទំនងអង្គហេតុ និងភស្តុតាងដែលម្ចាស់បំណុលបានអះអាង។

ច. សន្និដ្ឋាន និងសំណូមពរ ជាការបញ្ចប់សេចក្ដី ម្ចាស់បំណុលអាចធ្វើការសន្និដ្ឋានចំពោះចំណុចដូចបានរៀបរាប់ខាងលើនេះ ហើយសំណូមពរទៅតុលាការពីអ្វីដែលខ្លួនស្នើសុំ។

សូមបញ្ជាក់ម្ដងទៀតទម្រង់នៃសេចក្ដីបញ្ជាក់ដំបូងនេះ មិនមែនជាទម្រង់ដែលច្បាប់បានកំណត់នោះទេ គឺគ្រាន់តែជាទម្រង់ដែលជាទូទៅត្រូវបានគេនិយមសរសេរ ដាក់ជូនតុលាការ ចំពោះទម្រង់នៃសេចក្ដីបញ្ជាក់ដំបូងម្ចាស់បំណុលអាចសរសេរចំណុចដែលច្បាប់បានកំណត់ឱ្យធ្វើសេចក្ដីបញ្ជាក់ក៏បានដែរ ដោយសរសេរតែចំណុច

[39] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤១ កថាខណ្ឌទី៣

[40] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤១ កថាខណ្ឌទី៣

[41] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤១ កថាខណ្ឌទី២

ដែលបញ្ជាក់អំពី **សិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលនឹងត្រូវបានរក្សាការពារ** និង **ភាពចាំបាច់នៃការរក្សាការពារ** ព្រមទាំង **ភស្តុតាង** សម្រាប់គាំទ្រនូវអង្គហេតុទាំងនេះជាការស្រេច។

## ផ្នែកទី២៖ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ

នៅពេលម្ចាស់បំណុលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ ព្រមទាំងបានដាក់សេចក្តីបញ្ជាក់ដំបូងតាមការកំណត់រួចហើយ តុលាការនឹងពិនិត្យមើលឯកសារទាំងអស់នោះ ហើយប្រសិនបើតុលាការយល់ឃើញថាស្ថានភាពនោះ បានបំពេញលក្ខខណ្ឌដើម្បីចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការនឹងចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ តាមពាក្យសុំរបស់ម្ចាស់បំណុល។ ផ្នែកនេះនឹងបង្ហាញពីសណ្ឋានទូទៅនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុមាន (១) **ចំណុចដែលត្រូវសរសេរក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន** និង (២) **ប្រភេទប្រាក់ក្នុងការរឹបអូសជាបណ្តោះអាសន្ន** នឹងសិក្សាពីប្រភេទប្រាក់ផ្សេងៗ ដែលច្បាប់បានកំណត់ក្នុងការរឹបអូសជាបណ្តោះអាសន្ននេះ។

### ១. ចំណុចដែលត្រូវសរសេរក្នុងដីកាសម្រេច

នៅពេលចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ តុលាការនឹងបញ្ជាក់ពីចំណុចមួយចំនួននៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុរួមមាន (១.១) **អត្តសញ្ញាណភាគី** (១.២) **ខ្លឹមសារនៃការទាមទារ** (១.៣) **សំអាងហេតុ** និង (១.៤) **សេចក្តីសម្រេចបញ្ចប់** នឹងបកស្រាយបញ្ជាក់ពីចំណុចនីមួយៗដូចខាងក្រោមនេះ៖

#### ១.១. អត្តសញ្ញាណភាគី

បន្ទាប់ពីសរសេរបញ្ជាក់ព័ត៌មានមួយចំនួនពាក់ព័ន្ធនឹងការរឹបអូសជាបណ្តោះអាសន្នរួមមាន លេខសំណុំរឿងរក្សាការពារ និងកាលបរិច្ឆេទ ចៅក្រមនិងក្រឡាបញ្ជីទទួលបន្ទុករឿងក្តី ព្រមទាំងស្ថាប័នតុលាការដែលចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នរួចហើយ តុលាការនឹងសរសេរបញ្ជាក់អំពីអត្តសញ្ញាណរបស់ម្ចាស់បំណុល កូនបំណុល អ្នកតំណាងដែលច្បាប់បានកំណត់ រួមទាំងអ្នកតំណាងដោយអាណត្តិបើមាន។

#### ១.២. ខ្លឹមសារនៃការទាមទារ

ត្រង់ចំណុចនេះតុលាការនឹងបញ្ជាក់ពីខ្លឹមសារនៃការទាមទាររបស់ម្ចាស់បំណុល ហើយជាទូទៅតុលាការតែងតែចម្លងយកសេចក្តីស្នើសុំទាំងមូលរបស់ម្ចាស់បំណុល ដែលមានលើពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុតែម្តង។

#### ១.៣. សំអាងហេតុ

ចំណុចនេះតុលាការនឹងវិនិច្ឆ័យអង្គហេតុដែលម្ចាស់បំណុលបានលើកឡើង ហើយតុលាការនឹងបង្ហាញពីការយល់ឃើញពាក់ព័ន្ធនឹងសិទ្ធិ ឬទំនាក់ទំនងគតិយុត្តរវាងម្ចាស់បំណុល និងកូនបំណុល ព្រមទាំងភាពចាំបាច់

ដែលជាលក្ខខណ្ឌតម្រូវសម្រាប់ចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន។ ក្នុងករណីយល់ឃើញថាចាំបាច់ក្នុងការលើកឡើងពីការបកស្រាយច្បាប់ តុលាការត្រូវបង្ហាញការយល់ឃើញ ដែលនាំឱ្យមានការបកស្រាយច្បាប់ និងមូលហេតុនោះ លើសពីនេះទៀតតុលាការក៏ត្រូវបង្ហាញពីការពិនិត្យភស្តុតាងផ្សេងៗ ដែលម្ចាស់បំណុលបានដាក់មកជាមួយសេចក្តីបញ្ជាក់ដំបូងដែរ។

**១.៤. សេចក្ដីសម្រេចបញ្ចប់**

ស្របតាមអត្ថន័យមានក្នុងសំអាងហេតុដែលតុលាការបានយល់ឃើញ ក្នុងសេចក្តីសម្រេចបញ្ចប់ តុលាការនឹងសម្រេចរឹបអូសជាបណ្ដោះអាសន្នអចលនវត្ថុរបស់កូនបំណុល តាមពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដែលម្ចាស់បំណុលបានទាមទារឱ្យតុលាការចេញ។

តាមក្រមនីតិវិធីរដ្ឋប្បវេណីមិនបានកំណត់ពីទម្រង់ជាក់លាក់ នៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នអចលនវត្ថុ ចំពោះការអនុវត្តជាក់ស្ដែងយើងតែងតែឃើញថាចំណុចដែលត្រូវសរសេរក្នុងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នអចលនវត្ថុ មិនមានលក្ខណៈដូចគ្នាឡើយ ហើយចំណុចដែលបានរៀបរាប់ខាងលើនេះ ក៏មិនមែនជាចំណុចដែលច្បាប់បង្គាប់ឱ្យសរសេរនោះទេ គឺគ្រាន់តែជាចំណុចទូទៅដែលតុលាការនិយមសរសេរលើដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នអចលនវត្ថុតែប៉ុណ្ណោះ។

## ២. ប្រភេទប្រាក់ក្នុងការរឹបអូសជាបណ្ដោះអាសន្ន

ក្នុងនីតិវិធីរឹបអូសជាបណ្ដោះអាសន្ន ច្បាប់បានបង្កើតប្រព័ន្ធប្រាក់មួយចំនួនដើម្បីធានាសំណងការខូចខាតសម្រាប់ម្ចាស់បំណុល និងកូនបំណុល ដែលអាចនឹងកើតឡើងដោយសារការរឹបអូសជាបណ្ដោះអាសន្នអចលនវត្ថុ ក្នុងចំណុចនេះនឹងលើកយកប្រភេទប្រាក់ចំនួន ០៣ (បី) ប្រភេទ មកធ្វើការបកស្រាយ រួមមាន **(២.១) ប្រាក់ប្រដាប់ក្ដី** និង **(២.២) ប្រាតិភោគ** ព្រមទាំង **(២.៣) ប្រាក់រំដោះ** ដោយត្រូវបានប្រើប្រាស់តាមកាលៈទេសៈផ្សេងៗគ្នាស្របតាមឋានៈរបស់ភាគី។

**២.១. ប្រាក់ប្រដាប់ក្ដី**

ប្រាប់ប្រដាប់ក្ដី រួមមានពន្ធដាក់ពាក្យសុំ ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ និងប្រាក់ប្រដាប់ក្ដីភាគី។ **ពន្ធដាក់ពាក្យសុំ** ធ្លាប់បានបញ្ជាក់ម្ដងរួចមកហើយនៅចំណុចខាងលើត្រង់ចំណុចស្ដីពីពន្ធដាក់ពាក្យសុំ ដោយម្ចាស់បំណុលត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀលជូនតុលាការ[42] បើសិនម្ចាស់បំណុលមិនបានបង់ពន្ធនោះទេ ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននឹងត្រូវចាត់ទុកថាជាពាក្យសុំមិនស្របច្បាប់។ **ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ** គឺជាចំនួនប្រាក់ចាំបាច់សម្រាប់ពិនិត្យភស្តុតាង ការបញ្ជូនឯកសារ សោហ៊ុយធ្វើដំណើរ សោហ៊ុយស្នាក់នៅ សោហ៊ុយចាំបាច់សម្រាប់ពិនិត្យភស្តុតាង ការស្រាវជ្រាវអង្គហេតុ ឬសកម្មភាព

[42] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣៧ កថាខណ្ឌទី១

ផ្សេងទៀត[43] បើសិនជាម្ចាស់បំណុលមិនបង់សោហ៊ុយតាមការបង្គាប់ទេ តុលាការអាចលើកចោលពាក្យសុំឱ្យធ្វើការអនុវត្ត ឬលុបចោលនូវនីតិវិធីអនុវត្តរក្សាការពារតែម្តង។[44] **ប្រាក់ប្រដាប់ក្តីភាគី** សំដៅលើប្រាក់ថ្លៃធ្វើលិខិតថ្លៃដាក់ឯកសារទៅតុលាការ សោយហ៊ុយធ្វើដំណើរ សោហ៊ុយស្នាក់នៅ ប្រាក់ឧបត្ថម្ភរបស់ភាគី ឬអ្នកតំណាងដើម្បីបង្ហាញខ្លួននៅកាលបរិច្ឆេទដែលបានកំណត់។[45] នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការតែងតែកំណត់ពីប្រាក់ប្រដាប់ក្តីថាតើភាគីណាជាអ្នកទទួលបន្ទុក ជាគោលការណ៍ប្រាក់ប្រដាប់ក្តី ត្រូវបានតុលាការកំណត់នៅក្នុងសាលក្រម សាលដីកា ហើយភាគីចាញ់ក្តីជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី។[46] ប៉ុន្តែក្នុងនីតិវិធីរឹបអូសជាបណ្តោះអាសន្ន មិនទាន់អាចកំណត់ថាភាគីណាចាញ់ក្តីបានទេពោលនីតិវិធីនេះត្រូវបានប្រើប្រាស់ជាបណ្តោះអាសន្នតែប៉ុណ្ណោះ ទោះបីជាយ៉ាងនេះក្តីនៅផ្នែកសេចក្តីសម្រេចបញ្ចប់តុលាការនឹងកំណត់ឱ្យកូនបំណុលទទួលបន្ទុកប្រាក់ប្រដាប់ក្តីជាបណ្តោះអាសន្នសិន។

### ២.២. ប្រាតិភោគ

នៅមុនពេលចេញ ឬក្រោយពេលចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ តុលាការអាចបង្គាប់ឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ ឬមិនឱ្យដាក់ប្រាតិភោគបាន[47] ដោយប្រាតិភោគត្រូវបានដាក់តាមរបៀបដែលម្ចាស់បំណុលធ្វើប្រាក់ ឬធ្វើឧបករណ៍ដែលអាចជួញដូរបាន ដែលតុលាការទទួលស្គាល់ថាសមរម្យ[48] ការធ្វើបែបនេះគឺដើម្បីបង្ការហានិភ័យចំពោះផលប្រយោជន៍របស់កូនបំណុលតែប៉ុណ្ណោះ ដោយសារតែការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការអាចនឹងជ្រើសរើសមិនកោះហៅកូនបំណុលមកចូលរួមនីតិវិធីឡើយហេតុនេះបើតុលាការយល់ឃើញថាចាំបាច់ត្រូវឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ តុលាការនឹងបង្គាប់ដើម្បីឱ្យម្ចាស់បំណុលតម្កល់ប្រាតិភោគ។ ក្នុងករណីនេះតុលាការដែលចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬតុលាការអនុវត្ត គឺសុទ្ធតែជាតុលាការដែលមានសិទ្ធិបង្គាប់ឱ្យម្ចាស់បំណុលដាក់ប្រាតិភោគបាន។[49] លើសពីនេះទៀតប្រាតិភោគ គឺជាប្រព័ន្ធដែលការពារកូនបំណុល ក្នុងករណីដែលម្ចាស់បំណុលចាញ់បណ្តឹងអង្គសេចក្តីកូនបំណុលមានសិទ្ធិប្តឹងទាមទារសំណងនៃការខូចខាតពីម្ចាស់បំណុល ក្នុងករណីនេះកូនបំណុលនឹងក្លាយជាម្ចាស់បំណុលអាទិភាពដែលទទួលបានការសងមុនគេថែមទៀតផង[50] ការណ៍នេះសបញ្ជាក់ថាច្បាប់បានហាមឃាត់ម្ចាស់បំណុលពីការប្រើប្រាស់សិទ្ធិដោយបំពាន និងតាមអំពើចិត្តមិនគិតពីប្រយោជន៍របស់កូនបំណុល។

[43] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦២ កថាខណ្ឌទី១

[44] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣៧ កថាខណ្ឌទី៣

[45] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦៣

[46] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦៤

[47] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤២

[48] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣៦

[49] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣៦

[50] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧២

ម្ចាស់បំណុល ក៏អាចលុបចោលប្រាតិភោគរបស់ខ្លួនវិញបាន ក្នុងករណីដែលហេតុដែលនាំឱ្យដាក់ប្រាតិភោគត្រូវបានរលត់[51] ពោលអាចជាពេលដែលម្ចាស់បំណុលឈ្នះបណ្តឹងអង្គសេចក្តីដោយសាលក្រម ឬសាលដីកាស្ថាពរ ដើម្បីលុបចោលប្រាតិភោគដែលខ្លួនបានដាក់ ម្ចាស់បំណុលត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរព្រមទាំងបញ្ជាក់ពីការរលត់នៃហេតុដែលត្រូវដាក់ប្រាតិភោគ។

**ឧទាហរណ៍៖** លោក ក បានដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុរបស់លោក ខ ដែលមានទីតាំងនៅខេត្តព្រះសីហនុ និងរាជធានីភ្នំពេញ។ ដោយយោងតាមស្ថានភាពបច្ចុប្បន្ន អចលនវត្ថុនៅខេត្តព្រះសីហនុមានតម្លៃ ២០០.០០០ ដុល្លាអាមេរិក ហើយអចលនវត្ថុនៅរាជធានីភ្នំពេញមានតម្លៃ ៤០០.០០០ ដុល្លាអាមេរិក គួរបញ្ជាក់ថាជាទូទៅចំនួនប្រាតិភោគត្រូវកំណត់ស្មើនឹងតម្លៃអចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន ហេតុនេះចំនួនប្រាតិភោគចំពោះករណីខាងលើនេះស្មើនឹង ៦០០.០០០ ដុល្លាអាមេរិក។

### ២.៣. ប្រាក់រំដោះ

ក្នុងសេចក្តីសម្រេចបញ្ចប់នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការតែងតែកំណត់ពីចំនួនទឹកប្រាក់ដែលកូនបំណុលត្រូវផ្ញើ ដើម្បីទទួលបានការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន[52] ប្រាក់ដែលកូនបំណុលត្រូវផ្ញើនេះត្រូវបានស្គាល់ថាជាប្រាក់រំដោះ។ ប្រាក់រំដោះ សំដៅលើប្រព័ន្ធមួយសម្រាប់ការពារកូនបំណុលពីការខូចខាតផ្សេងៗ ដែលកើតឡើងដោយសារការរឹបអូសជាបណ្តោះអាសន្ន ឬជាប្រព័ន្ធមួយដែលប្រើប្រាស់សម្រាប់រំដោះអចលនវត្ថុចេញពីការរឹបអូសជាបណ្តោះអាសន្ន ទោះបីជាការអនុវត្តរឹបអូសជាបណ្តោះអាសន្ន បានអនុវត្តចប់សព្វគ្រប់ក៏ដោយ ក៏តុលាការអាចសម្រេចលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ននោះនៅពេលកូនបំណុលបានបង់ប្រាក់រំដោះ។ ការដាក់ប្រាក់រំដោះ ត្រូវធ្វើតាមរបៀបដែលកូនបំណុលផ្ញើប្រាក់ ឬឧបករណ៍ដែលអាចជួញដូរបាន ដែលតុលាការយល់ឃើញថាសមរម្យ កូនបំណុលអាចផ្ញើប្រាក់រំដោះនៅតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬតុលាការអនុវត្តក៏បានដែរ។[53] ប្រាក់រំដោះ ត្រូវបានប្រើប្រាស់ចំពោះតែការរឹបអូសជាបណ្តោះអាសន្នតែប៉ុណ្ណោះ ដោយសារម្ចាស់បំណុលស្នើសុំឱ្យរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុរបស់កូនបំណុល ដើម្បីលក់ដោយបង្ខំនៅពេលដែលខ្លួនឈ្នះបណ្តឹងអង្គសេចក្តី ហេតុនេះបើកូនបំណុលដាក់ប្រាក់ដើម្បីរំដោះអចលនវត្ថុចេញពីការរឹបអូសជាបណ្តោះអាសន្ន នោះនៅពេលអនុវត្តដោយបង្ខំប្រាក់រំដោះនឹងត្រូវប្រើប្រាស់ដើម្បីសងម្ចាស់បំណុល ហើយអចលនវត្ថុរបស់កូនបំណុលក៏មិនប្រឈមនឹងការលក់ដោយបង្ខំដែរ មានន័យថាកូនបំណុលអាចចាត់ចែងអចលនវត្ថុខ្លួនដោយគ្មានការកម្រិតសិទ្ធិចាត់ចែង

[51] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៣
[52] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤៧ កថាខណ្ឌទី១
[53] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤៧ កថាខណ្ឌទី២

ហើយម្ចាស់បំណុលក៏មានអារម្មណ៍ធូរស្បើយ ពីព្រោះខ្លួននឹងទទួលបានការសងផងដែរ ដូច្នេះយើងអាចសង្កេតបានថាប្រព័ន្ធនៃប្រាក់រំដោះស្ថិតនៅចំផ្នែកកណ្តាល ដោយបានការពារផលប្រយោជន៍ភាគីទាំងសងខាងតែម្តង ទាំងកូនបំណុល និងម្ចាស់បំណុល។

**ឧទាហរណ៍៖** សិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់មានចំនួន ៤០០.០០០ ដុល្លាអាមេរិក ហើយអចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្នមានតម្លៃ ៥០០.០០០ ដុល្លាអាមេរិក នោះប្រាក់រំដោះត្រូវកំណត់ត្រឹមសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់គឺ ៤០០.០០០ ដុល្លាអាមេរិក។ ផ្ទុយទៅវិញបើសិទ្ធិលើបំណុលមានគោលបំណងឱ្យសងជាប្រាក់មានចំនួន ៣០០.០០០ ដុល្លាអាមេរិក ហើយអចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្នមានតម្លៃ ១០០.០០០ ដុល្លាអាមេរិក នោះប្រាក់រំដោះត្រូវកំណត់ត្រឹមតម្លៃអចលនវត្ថុគឺ ១០០.០០០ ដុល្លាអាមេរិក។

# ជំពូកទី៣

# ការអនុវត្ត ការផ្អាក និង
# ការលុបចោលការអនុវត្ត
# វិធានការមួយចំនួនក្នុងនីតិវិធីប្តឹងផ្តល់ និងប្រភេទស្រួលការដោះស្រាយ

# ជំពូកទី៣

# ការអនុវត្ត ការផ្អាក និងការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន

បន្ទាប់ពីទទួលបានដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ ម្ចាស់បំណុលត្រូវដាក់ពាក្យស្នើសុំឱ្យតុលាការអនុវត្តរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល ហេតុនេះការដែលដឹងពីលំហូរនីតិវិធីនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ ដោយក្នុងជំពូកនេះនឹងលើកយកលំហូរនីតិវិធីនេះមកបង្ហាញក្នុង **(ផ្នែកទី១) ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន** លើសពីនេះទៀតនៅក្នុង **(ផ្នែកទី២) ការផ្អាក និងការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន** ដែលបកស្រាយមូលហេតុមួយចំនួនធ្វើឱ្យការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ត្រូវបានតុលាការសម្រេចឱ្យផ្អាក ឬលុបចោលតែម្តង។

## ផ្នែកទី១៖ ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន

ដើម្បីសិក្សាលំហូរនីតិវិធីនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្នឱ្យបានសព្វគ្រប់ គួរគប្បីសិក្សាពីចំណុច (១) **លក្ខខណ្ឌនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន** ថាតើមានលក្ខខណ្ឌអ្វីខ្លះដើម្បីឱ្យការអនុវត្តរឹបអូសជាបណ្តោះអាសន្នធ្វើទៅបាន ហើយចំណុច (២) **ពាក្យសុំឱ្យអនុវត្ត** នឹងបកស្រាយពីរបៀបដែលម្ចាស់បំណុលត្រូវសរសេរពាក្យសុំឱ្យអនុវត្តដើម្បីដាក់ជូនតុលាការអនុវត្ត បន្តមកទៀតចំណុច (៣) **តុលាការអនុវត្ត** នឹងបង្ហាញពីតុលាការដែលម្ចាស់បំណុលអាចដាក់ពាក្យសុំឱ្យអនុវត្តរបស់ខ្លួនបានជាចុងក្រោយ (៤) **ការផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន** នឹងពិនិត្យរបៀបនៃការផ្ទុកផ្តាក់អចលនវត្ថុឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នក្នុងសៀវភៅគោលបញ្ជីដីធ្លីដែរ។

### ១. លក្ខខណ្ឌនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន

មុនឈានដល់ការដាក់ពាក្យសុំឱ្យអនុវត្ត ម្ចាស់បំណុលត្រូវស្វែងយល់លក្ខខណ្ឌមួយចំនួនទាក់ទងនឹងការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នជាមុនសិន រួមមាន (១.១) **អំឡុងពេលនៃការអនុវត្ត** ដែលនៅក្នុងនេះនឹងបង្ហាញពីថេរវេលាដែលម្ចាស់បំណុលគួរធ្វើការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ហើយក្នុង (១.២) **ភាពមិនចាំបាច់នៃរូបមន្តអនុវត្ត** ដោយមានបញ្ជាក់ពីភាពមិនចាំបាច់នៃរូបមន្តអនុវត្ត និងបង្ហាញថាតើមានករណីណាខ្លះដែលច្បាប់បានកំណត់ឱ្យម្ចាស់បំណុលត្រូវដាក់ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត ដើម្បីអនុវត្តរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុរបស់កូនបំណុល ព្រមទាំងក្នុង (១.៣) **ការបញ្ជូនលិខិតអនុវត្ត** នៅចំណុចចុងក្រោយនេះនឹងមានការបកស្រាយអំពីលក្ខខណ្ឌពិសេសមួយទៀត ទាក់ទងនឹងការបញ្ជូនដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នថាតើការអនុវត្តបានឬទេ មុនពេលកូនបំណុលទទួលបានការបញ្ជូនដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន?

#### ១.១. អំឡុងពេលនៃការអនុវត្ត

ម្ចាស់បំណុល ត្រូវអនុវត្តរឹបអូសជាបណ្តោះអាសន្ន ក្នុងអំឡុងពេល ០២ (ពីរ) សប្តាហ៍ គិតចាប់ថ្ងៃដែល

ម្ចាស់បំណុលទទួលការបញ្ជូនដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នអចលនវត្ថុ បើលើសរយៈពេលដែលបានកំណត់ខាងលើនេះ ការរឹបអូសជាបណ្ដោះអាសន្ន នឹងមិនអាចអនុវត្តបានឡើយ[54] ដោយយោងតាមស្មារតីច្បាប់ការកំណត់បែបនេះគឺដើម្បីឆ្លើយតបចំពោះភាពបន្ទាន់នៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ពោលបើដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន មិនត្រូវបានអនុវត្តភ្លាមៗនោះទេ ភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននឹងត្រូវបាត់បង់ ហើយដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន បានប្រែក្លាយជាអស់ន័យ។ គួរបញ្ជាក់ដែរថាការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ត្រូវបានកំណត់ឱ្យអនុវត្តក្នុងអំឡុងពេល ០២ (ពីរ) សប្ដាហ៍ ប៉ុន្តែនីតិវិធីបន្តបន្ទាប់ច្បាប់មិនបានកំណត់ពេលវេលានោះទេ។

### ១.២. ភាពមិនចាំបាច់នៃរូបមន្តអនុវត្ត

ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន មានចរិតលក្ខណៈបន្ទាន់ ត្រូវមានអានុភាពអនុវត្តបានភ្លាមៗ និងលឿនបំផុត ដើម្បីកម្រិតសិទ្ធិចាត់ចែងអចលនវត្ថុរបស់កូនបំណុលឱ្យទាន់ពេលវេលា ជៀសវាងការចាត់ចែងអចលនវត្ថុដោយសេរី មានន័យថាដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន មានអានុភាពអនុវត្តបានភ្លាមៗ ដោយមិនត្រូវការរូបមន្តអនុវត្តឡើយ។[55] ជាទូទៅបុគ្គលដែលទទួលរងវិសាលភាពនៃការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន គឺមានតែភាគីដែលត្រូវបានបញ្ជាក់នៅក្នុងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នអចលនវត្ថុតែប៉ុណ្ណោះ[56] ហេតុនេះបើការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះ ឬសម្រាប់ជនក្រៅពីភាគី ដែលបានកំណត់ក្នុងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ព្រមទាំងរូបមន្តអនុវត្ត[57] ដែលរូបមន្តអនុវត្តក្នុងន័យនេះ គឺជារូបមន្តអនុវត្តពិសេស ត្រូវផ្ដល់ដោយក្រឡាបញ្ជីនៃតុលាការដែលទទួលបន្ទុករឿងក្ដីរឹបអូសជាបណ្ដោះអាសន្ននោះ[58] ហើយត្រូវបង្ហាញគោលការណ៍អនុញ្ញាតពីតុលាការដែលខ្លួនស្ថិតនៅថែមទៀត។[59] ដើម្បីទទួលបានរូបមន្តអនុវត្តពិសេសនេះម្ចាស់បំណុលនៃការអនុវត្តត្រូវដាក់ពាក្យសុំឱ្យផ្ដល់រូបមន្តអនុវត្ត ជាលាយល័ក្ខណ៍អក្សរ ដែលមានទម្រង់ដូចតទៅ៖

ក. ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋាន របស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ព្រមទាំងឈ្មោះ និងអាសយដ្ឋានអ្នកតំណាងដែលច្បាប់បានកំណត់។

ខ. សញ្ញាណនៃលិខិតអនុវត្ត។

[54] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦២ កថាខណ្ឌទី២

[55] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦២ កថាខណ្ឌទី១ វាក្យខណ្ឌទី១

[56] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦៤ និងមាត្រា៣៥១ កថាខណ្ឌទី១

[57] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦២ កថាខណ្ឌទី១ វាក្យខណ្ឌទី២

[58] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦៤ និងមាត្រា៣៥៤ កថាខណ្ឌទី២ ២០០៦

[59] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦៤ និងមាត្រា៣៥៦ កថាខណ្ឌទី៤

គ. ហេតុការណ៍ និងមូលហេតុ ដែលទាមទារឱ្យផ្តល់រូបមន្តអនុវត្តពិសេស ឬទាមទារឱ្យផ្តល់រូបមន្តអនុវត្តច្រើនច្បាប់។[60]

បន្ទាប់ពីម្ចាស់បំណុលនៃការអនុវត្តបានដាក់ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្តពិសេស ក្រឡាបញ្ជីនឹងចេញរូបមន្តអនុវត្តពិសេសជូនម្ចាស់បំណុលនៃការអនុវត្ត ព្រមទាំងមានចុះហត្ថលេខារបស់ក្រឡាបញ្ជី និងសរសេរថ្ងៃខែឆ្នាំនៃការផ្តល់រូបមន្តអនុវត្តពិសេស ដោយរូបមន្តអនុវត្តពិសេសត្រូវសរសេរចំណុចដូចខាងក្រោម៖

ក. បុគ្គលដែលអាចទាមទារឱ្យធ្វើការអនុវត្តរឹបអូសជាបណ្តោះអាសន្នបាន ដោយដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬភាគីម្ខាងទៀត។

ខ. ហេតុការណ៍ដែលផ្តល់រូបមន្តអនុវត្តពិសេស។

គ. ទំហំដែលអាចអនុវត្តរឹបអូសជាបណ្តោះអាសន្ន (ទាំងមូល ឬផ្នែកណាមួយនៃសិទ្ធិទាមទារ)។

ឃ. ហេតុការណ៍ ក្នុងករណីដែលផ្តល់រូបមន្តអនុវត្តច្រើនច្បាប់ជាអាទិ៍។[61]

### ១.៣. ការបញ្ជូនដីកាសម្រេច

ការរឹបអូសជាបណ្តោះអាសន្ន គឺមានលក្ខណៈស្ងៀមស្ងាត់ និងសម្ងាត់ជាទីបំផុត មានន័យថាជាទូទៅក្នុងការអនុវត្តដោយបង្ខំអាចចាប់ផ្តើមធ្វើទៅបាន តែក្នុងករណីដែលឯកសារចម្លងយថាភូត ឬឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃលិខិតអនុវត្ត ឬសេចក្តីសម្រេចដែលនឹងក្លាយជាលិខិតអនុវត្តនៅពេលចូលជាស្ថាពរ ត្រូវបានបញ្ជូនដល់កូនបំណុលនៃការអនុវត្តជាមុនតែប៉ុណ្ណោះ[62] ប៉ុន្តែដោយសារចរិតលក្ខណៈពិសេសរបស់ការរឹបអូសជាបណ្តោះអាសន្ន ទើបធ្វើឱ្យការបញ្ជូនដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ ទៅកូនបំណុលនៃការអនុវត្តមិនមានភាពចាំបាច់ឡើយ ដោយម្ចាស់បំណុលនៃការអនុវត្តអាចដាក់ពាក្យសុំឱ្យអនុវត្តយកតែម្តងដើម្បីអនុវត្តរឹបអូសជាបណ្តោះអាសន្នឱ្យបានឆាប់រហ័ស និងលាក់ការសម្ងាត់ជានិច្ច[63] ជៀសវាងកូនបំណុលនៃការអនុវត្តបានដឹងខ្លួនជាមុន ហើយបានចាត់ចែងអចលនវត្ថុដោយសេរី ដែលធ្វើឱ្យដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុប្រែក្លាយជាគ្មានប្រយោជន៍។

## ២. តុលាការអនុវត្ត

ក្នុងការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ម្ចាស់បំណុលនៃការអនុវត្ត ត្រូវដាក់ពាក្យសុំឱ្យអនុវត្តទៅស្ថាប័នតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។[64] មានន័យថា ស្ថាប័នតុលាការដែលបានចេញ

[60] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦៤ និងមាត្រា៣៥៥ កថាខណ្ឌទី១

[61] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦៤ និងមាត្រា៣៥៧

[62] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៦០

[63] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦២ កថាខណ្ឌទី៣

[64] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦៧ កថាខណ្ឌទី២

ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ក៏ជាស្ថាប័នតុលាការដែលមានសមត្ថកិច្ចសម្រាប់ការអនុវត្តរឹបអូសជាបណ្តោះអាសន្នដែរ ឬអាចហៅម្យ៉ាងទៀតថាតុលាការអនុវត្ត។ ដោយបានដឹងរួចមកហើយថាការរឹបអូសជាបណ្តោះអាសន្នស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខ[65] របស់តុលាការដែលមានសមត្ថកិច្ចលើបណ្តឹងអង្គសេចក្តី ឬសាលាដំបូងដែលអចលនវត្ថុត្រូវបានរឹបអូសជាបណ្តោះអាសន្នស្ថិតនៅ[66] ពោលបើសាលាដំបូងរាជធានីភ្នំពេញបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុរបស់លោក ខ ជាកូនបំណុលនៃការអនុវត្ត ក្នុងករណីនេះលោក ក ដែលជាម្ចាស់បំណុលនៃការអនុវត្ត ត្រូវដាក់ពាក្យសុំឱ្យអនុវត្តរឹបអូសជាបណ្តោះអាសន្នទៅសាលាដំបូងរាជធានីភ្នំពេញដដែល។

### ៣. ពាក្យសុំឱ្យអនុវត្ត

បន្ទាប់ពីបានដឹងតុលាការដែលទទួលបន្ទុកអនុវត្តរឹបអូសជាបណ្តោះអាសន្នរួចមក ជាកិច្ចបន្ទាប់ត្រូវដឹងពីរបៀបសរសេរពាក្យសុំឱ្យអនុវត្តដើម្បីដាក់ជូនតុលាការអនុវត្ត។ ពាក្យសុំឱ្យអនុវត្ត ត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ[67] មិនអាចធ្វើឡើងដោយផ្ទាល់មាត់បានទេ ដោយសារតែពាក្យសុំឱ្យអនុវត្តត្រូវបានក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់យ៉ាងជាក់លាក់ពីចំណុចដែលត្រូវសរសេរក្នុងពាក្យសុំនឹងបង្ហាញក្នុងចំណុច **(៣.១) ទម្រង់នៃពាក្យសុំឱ្យអនុវត្ត** នៅពេលដាក់ពាក្យសុំឱ្យអនុវត្ត ម្ចាស់បំណុលក៏ត្រូវភ្ជាប់ឯកសារសំខាន់ៗមួយចំនួនជាមួយពាក្យសុំឱ្យអនុវត្ត ហេតុនេះនឹងពិនិត្យថាតើម្ចាស់បំណុលត្រូវភ្ជាប់ជូនឯកសារអ្វីទៅតុលាការអនុវត្ត? ដែលមានបង្ហាញនៅក្នុងចំណុចស្តីពី **(៣.២) ឯកសារភ្ជាប់**។

#### ៣.១. ទម្រង់នៃពាក្យសុំឱ្យអនុវត្ត

ក្នុងពាក្យសុំឱ្យអនុវត្តរឹបអូសជាបណ្តោះអាសន្ន ម្ចាស់បំណុលត្រូវសរសេរបញ្ជាក់ចំណុចដូចតទៅ៖

ក. ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋាន របស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

ខ. សញ្ញាណនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។

គ. សេចក្តីសុំឱ្យអនុវត្ត(វិធានអនុវត្តបង្ខំដោយផ្ទាល់)។

ឃ. សញ្ញាណអចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន និងវិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ ក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់។[68]

ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តសុំឱ្យអនុវត្តរឹបអូសជាបណ្តោះអាសន្ន ត្រង់ផ្នែកណាមួយនៃ

[65] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣៣

[66] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤០

[67] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣៤ ចំណុច ច

[68] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦៤ និងមាត្រា៣៤៩ កថាខណ្ឌទី២ និងកថាខណ្ឌទី៣

សិទ្ធិទាមទារដែលបានសរសេរលើដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ម្ចាស់បំណុលនៃការអនុវត្ត ត្រូវសរសេរបញ្ជាក់ពីសេចក្ដីសុំនោះ ក្នុងពាក្យសុំឱ្យអនុវត្តរឹបអូសជាបណ្ដោះអាសន្ន។[69] ចំពោះទម្រង់ និងចំណុចដែលត្រូវសរសេរទាំងនេះ ម្ចាស់បំណុលនៃការអនុវត្ត គួរគប្បីសរសេរឱ្យបានត្រឹមត្រូវតាមអ្វីដែលក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់ ដើម្បីឱ្យកិច្ចដំណើរការនីតិវិធីបន្តបន្ទាប់មានភាពងាយស្រួល ឆាប់រហ័ស និងមានប្រសិទ្ធភាពខ្ពស់។

**៣.២. ឯកសារភ្ជាប់**

ពេលដែលម្ចាស់បំណុលនៃការអនុវត្តដាក់ពាក្យសុំឱ្យអនុវត្តទៅតុលាការអនុវត្ត ម្ចាស់បំណុលនៃការអនុវត្ត ត្រូវភ្ជាប់ជូនឯកសារដូចខាងក្រោមនេះ ជាមួយពាក្យសុំឱ្យអនុវត្តរឹបអូសជាបណ្ដោះអាសន្នៈ

ក. ឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នអចលនវត្ថុ[70] សំដៅដល់ឯកសារដែលក្រឡាបញ្ជីបានចម្លងចេញពីដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នច្បាប់ដើម និងមានរំលេចពាក្យថា "បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម" ហើយបានការប្រថាប់ត្រាថា "បានឃើញ" ពីចៅក្រមទទួលបន្ទុកផងដែរ។

ខ. លិខិតបញ្ជាក់ពីការតម្កល់ប្រាតិភោគ ជាទូទៅការបង្គាប់ឱ្យតម្កល់ប្រាតិភោគជាឆន្ទានុសិទ្ធិរបស់តុលាការ នៅក្នុងករណីដែលតុលាការបង្គាប់ឱ្យតម្កល់ប្រាតិភោគ[71] នោះពេលដែលម្ចាស់បំណុលបានតម្កល់ប្រាតិភោគរួចរាល់ហើយ ម្ចាស់បំណុលគប្បីភ្ជាប់ជូនឯកសារដែលបានបញ្ជាក់ពីការតម្កល់ប្រាតិភោគរបស់ខ្លួនទៅតុលាការអនុវត្ត។

គ. លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ(បើមានអ្នកតំណាងដោយអាណត្តិ) ជាគោលការណ៍អ្នកតំណាងដោយអាណត្តិត្រូវតែជាមេធាវី ដែលសិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិត្រូវបញ្ជាក់ដោយលិខិតលាយលក្ខណ៍អក្សរ[72] លើសពីនេះទៀតនៅក្នុងវិធានវិជ្ជាជីវៈមេធាវីក៏បានប្បញ្ញត្តិថាមេធាវីត្រូវមានលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ដែលត្រូវសរសេរលំអិតពីសិទ្ធិ និងតួនាទីរបស់មេធាវី ដែលអតិថិជនប្រគល់ឱ្យស្របតាមច្បាប់[73] ស្របតាមអត្ថន័យខាងលើនេះអ្នកតំណាងដោយអាណត្តិ ត្រូវភ្ជាប់ជូនលិខិតប្រគល់តំណាងដោយអាណត្តិជូនតុលាការអនុវត្ត ដើម្បីបង្ហាញពីការតំណាងដោយអាណត្តិជូនកូនក្តីរបស់ខ្លួនក្នុងសំណុំរឿងអនុវត្ត។

[69] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦៤ និងមាត្រា៣៤៩ កថាខណ្ឌទី៣

[70] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦២ កថាខណ្ឌទី១

[71] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣៦

[72] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣ កថាខណ្ឌទី១ និងកថាខណ្ឌទី២

[73] ក្រមសីលធម៌មេធាវីនៃគណៈមេធាវី, ២១ កញ្ញា ២០១២, មាត្រា២៣

ឃ. ឯកសារបន្ទាប់បន្សំមួយចំនួនទៀត ក្នុងករណីខ្លះម្ចាស់បំណុលនៃការអនុវត្តអាចរៀបចំឯកសារមួយចំនួនបន្ថែមទៀតដើម្បីសម្រួលដល់ការអនុវត្តនីតិវិធីរឹបអូសជាបណ្តោះអាសន្ន ដូចជា៖ ឧបសម្ព័ន្ធស្តីពីអចលនវត្ថុ(ការរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុច្រើនទីតាំង)ជាដើម។

### ៤. ការផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន

ការអនុវត្តរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ ត្រូវធ្វើតាមរបៀបនៃការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន[74] ដោយក្រឡាបញ្ជីត្រូវធ្វើការផ្ទុកផ្តាក់ទៅស្ថាប័នមានសមត្ថកិច្ច ដើម្បីចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុនោះ[75] ពាក្យថាស្ថាប័នមានសមត្ថកិច្ចនៅត្រង់នេះ សំដៅលើរដ្ឋបាលសុរិយោដីថ្នាក់រាជធានីខេត្តដែលអចលនវត្ថុតាំងនៅ។ បច្ចុប្បន្នអចលនវត្ថុ នៅព្រះរាជាណាចក្រកម្ពុជាមួយចំនួនធំ នៅមិនទាន់មានការចុះបញ្ជីដីធ្លី ឱ្យបានត្រឹមត្រូវស្របតាមលិខិតបទដ្ឋានរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នោះទេ។ ហេតុដូច្នេះការផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ននេះ នឹងធ្វើការបកស្រាយចំពោះ **(៤.១) ការផ្ទុកផ្តាក់ឱ្យចុះបញ្ជីចំពោះអចលនវត្ថុដែលបានចុះបញ្ជីដីធ្លី** និង **(៤.២) ការផ្ទុកផ្តាក់ឱ្យចុះបញ្ជីចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីដីធ្លី។**

ការផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ ត្រូវធ្វើឡើងតាមរយៈការបញ្ជូនលិខិតផ្ទុកផ្តាក់ទៅស្ថាប័នមានសមត្ថកិច្ចក្នុងការចុះបញ្ជី ដើម្បីចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ហើយលិខិតផ្ទុកផ្តាក់ត្រូវសរសេរបាវចនានៃព្រះរាជាណាចក្រកម្ពុជា ឈ្មោះតុលាការ លេខលិខិតផ្ទុកផ្តាក់ ឈ្មោះក្រឡាបញ្ជី កាលបរិច្ឆេទ ហត្ថលេខា និងត្រូវបោះត្រារបស់ក្រឡាបញ្ជី[76] ចំណុចដែលបានរៀបរាប់នេះជាចំណុចទូទៅដែលត្រូវសរសេរក្នុងលិខិតផ្ទុកផ្តាក់ ហើយត្រូវសរសេរបន្ថែមចំណុចមួយចំនួនទៀត ស្របតាមប្រភេទលិខិតផ្ទុកផ្តាក់។

គួរបញ្ជាក់ដែរថា ក្រោមគោលនយោបាយនៃការបង្កើតយន្តការច្រកចេញចូលតែមួយ សម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ បានធ្វើឱ្យការផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ប្រែប្រួលចំណុចមួយចំនួន។ គោលបំណងនៃបង្កើតច្រកចេញចូលតែមួយ គឺដើម្បីលើកកម្ពស់ គុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាពនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការប្រមូលផ្តុំការផ្តល់សេវារដ្ឋបាលលើវិស័យនានានៅកន្លែងតែមួយ ដើម្បីបង្កលក្ខណៈងាយស្រួល និងឆ្លើយតបទាន់ពេលវេលាតាមតម្រូវការរបស់ប្រជាពលរដ្ឋ។[77] ការអនុវត្តកន្លងមកលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជា

[74] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦៧ កថាខណ្ឌទី១

[75] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦៧ កថាខណ្ឌទី៣

[76] ប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី, លេខ ៥៩ប្រកដនស/១១, ០៣ ឧសភា ២០១១, ប្រការ៥

[77] អនុក្រឹត្យស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ, លេខ ១៨ អនក្រ.បក, ០៨ កុម្ភៈ ២០១៧, មាត្រា១

បណ្ដោះអាសន្ន ត្រូវបញ្ជូនទៅរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្តតែម្ដង ប៉ុន្តែក្រោមទម្រង់នៃការផ្លាស់ប្ដូរថ្មីគ្រប់ប្រភេទនៃលិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នអចលនវត្ថុ[78] ត្រូវបញ្ជូនទៅផ្នែកជួរមុខ[79] នៃការិយាល័យច្រកចេញចូលតែមួយរបស់រដ្ឋបាលរាជធានី ខេត្ត ជាមុនសិន បន្ទាប់មកទើបការិយាល័យច្រកចេញចូលតែមួយបញ្ជូនលិខិតផ្ទុកផ្ដាក់នេះបន្តទៅរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ដើម្បីដំណើរការនីតិវិធីបន្ទាប់។ ក្នុងកំឡុងពេលនោះ ការិយាល័យច្រកចេញចូលតែមួយនឹងចេញ "**បង្កាន់ដៃទទួលពាក្យ**" ដើម្បីបញ្ជាក់ពីការទទួលយកលិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ទន្ទឹមនឹងនេះម្ចាស់បំណុលក៏ត្រូវ "**បង់សេវាសាធារណៈ**" ដូចមានកំណត់ក្នុងប្រកាសស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ផងដែរ។

### ៤.១. ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជីចំពោះអចលនវត្ថុដែលបានចុះបញ្ជីដីធ្លី

អចលនវត្ថុដែលបានចុះបញ្ជីដីធ្លី គឺជាអចលនវត្ថុដែលបានចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី ស្របតាមអនុក្រឹត្យស្ដីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ឬអនុក្រឹត្យស្ដីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ដែលត្រូវបានស្គាល់ថាជាវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬអាចហៅម្យ៉ាងទៀតថាជាប្លង់រឹង។ ក្នុងករណីដែលអចលនវត្ថុបានចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លីរួចរាល់ ក្រឡាបញ្ជីត្រូវធ្វើលិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ទៅរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត[80] ហើយលិខិតផ្ទុកផ្ដាក់នេះត្រូវសរសេរបន្ថែមចំណុចដូចខាងក្រោម៖

- ក. កម្មវត្ថុ(សរសេរអំពីខ្លឹមសារចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន)។
- ខ. អត្តសញ្ញាណនៃអចលនវត្ថុ(លេខក្បាលដី ឬលេខប័ណ្ណ និងទីតាំង)។
- គ. គោលបំណងនៃការចុះបញ្ជី(ចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ននូវកម្មសិទ្ធិ)។
- ឃ. មូលហេតុ(ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខ ចុះថ្ងៃទី ខែ ឆ្នាំ និងឈ្មោះតុលាការ)។
- ង. ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត(អាសយដ្ឋាន)។
- ច. ឈ្មោះកូនបំណុលនៃការអនុវត្ត(អាសយដ្ឋាន)។

---

[78] អនុក្រឹត្យស្ដីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្ដល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ, លេខ ១៨ អនក្រ.បក, ០៨ កុម្ភៈ ២០១៧, តារាងឧបសម្ព័ន្ធទី១, សេវាសុរិយោដី និងភូមិសាស្ត្រ, លេខរៀងទី១៣

[79] ផ្នែកជួរមុខ គឺជាកន្លែងដែលប្រជាពលរដ្ឋប្រាស្រ័យដោយផ្ទាល់ ដើម្បីទទួលបានព័ត៌មាននានាអំពីការផ្ដល់សេវារដ្ឋបាល ទទួលទម្រង់បែបបទ ដាក់ពាក្យស្នើសុំបង់ប្រាក់កម្រៃ និងទទួលយកលទ្ធផលសម្រេចជាផ្លូវការនៃការស្នើសុំសេវារដ្ឋបាល (អនុក្រឹត្យស្ដីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្ដល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ, លេខ ១៨ អនក្រ.បក, ០៨ កុម្ភៈ ២០១៧, មាត្រា៥)

[80] ប្រកាសអន្តរក្រសួងស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី, លេខ ៥៩ប្រក.ដនស/១១, ០៣ ឧសភា ២០១១, ប្រការ៥ កថាខណ្ឌទី១ ចំណុចទី១

ដោយមានភ្ជាប់ជូននូវឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន[81] និងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុផងដែរ។

បន្ទាប់មកទៀតមន្ត្រីសុរិយោដីថ្នាក់រាជធានី ខេត្តត្រូវសរសេរក្នុង "សៀវភៅគោលបញ្ជីដីធ្លី" នៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ដោយត្រូវសរសេរថា "ត្រូវបានរឹបអូសជាបណ្ដោះអាសន្នកម្មសិទ្ធិតាមដីកាសម្រេចលេខ....... ចុះថ្ងៃទី..... ខែ....... ឆ្នាំ....... របស់តុលាការ......... លរ.Aj........(ជាទឹកក្រហម) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬខ្មៅ)"។[82]

### ៤.២. ការផ្ដុកផ្ដាក់ឱ្យចុះបញ្ជីចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីដីធ្លី

អចលនវត្ថុដែលមិនទាន់បានចុះបញ្ជីដីធ្លី ជាអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី និងត្រូវបានសន្មតថាជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត[83] ដោយស្គាល់ថាជាលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែង ឬលិខិតផ្ទេរសិទ្ធិកាន់កាប់ ឬលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លី ឬអាចហៅម្យ៉ាងទៀតថាប្លង់ទន់ ។ ក្នុងករណីអចលនវត្ថុមិនទាន់បានចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លីទេ ក្នុងនោះមានស្ថាប័នចំនួន ០២ (ពីរ) ដែលអាចទទួលលិខិតផ្ដុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន រួមមានរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ឬរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលអចលនវត្ថុតាំងនៅ។[84] បន្ទាប់ពីបានទទួលលិខិតផ្ដុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត និងរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវចុះលេខរៀងនៃការទទួលលិខិតផ្ដុកផ្ដាក់នេះ ក្នុងសៀវភៅទទួលពាក្យសុំចុះបញ្ជីអំពីសិទ្ធិប្រត្យក្ស ដែលបង្កើតដាច់ដោយឡែកពីសៀវភៅទទួលពាក្យសុំផ្សេងទៀត[85] ដោយការចុះលេខរៀងនេះ ដើម្បីសម្គាល់ពីលំដាប់នៃការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នអចលនវត្ថុនោះ បើមានការដាក់ពាក្យសុំចុះបញ្ជីច្រើនលើអចលនវត្ថុតែមួយ។[86]

ក. កម្មវត្ថុ(ចាប់ផ្ដើមនីតិវិធីចុះបញ្ជីលើកដំបូងអំពីការរឹបអូសជាបណ្ដោះអាសន្ន)។

សរសេរអំពីខ្លឹមសារនៃការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន)។

---

[81] ប្រកាសអន្តរក្រសួងស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី, លេខ ៥៩ប្រកដនស/១១, ០៣ ឧសភា ២០១១, ប្រការ១៦

[82] ប្រកាសអន្តរក្រសួងស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី, លេខ ៥៩ប្រកដនស/១១, ០៣ ឧសភា ២០១១, ប្រការ៣២ ចំណុច ក

[83] ប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី, លេខ ២១៤ ប្រកដនស, ២១ វិច្ឆិកា ២០១៤, ប្រការ៤

[84] ប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី, លេខ ២១៤ ប្រកដនស, ២១ វិច្ឆិកា ២០១៤, ប្រការ៥

[85] ប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី, លេខ ២១៤ ប្រកដនស, ២១ វិច្ឆិកា ២០១៤, ប្រការ៥ កថាខណ្ឌទី១ និងប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី, លេខ ៣០កយដនសប្រក/១៣, ២៩ មករា ២០១៣, ប្រការ៥

[86] ប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី, លេខ ៣០កយដនសប្រក/១៣, ២៩ មករា ២០១៣, ប្រការ៧

ខ. អត្តសញ្ញាណនៃអចលនវត្ថុ(ទីតាំងដី ទំហំដី និងលេខប័ណ្ណ)។

គ. កម្មសិទ្ធិករ ឬភោគីនៃដីដែលត្រូវបានសន្មត(ឈ្មោះ អាសយដ្ឋាន)។

ឃ. គោលបំណងនៃការចុះបញ្ជី(ការរឹបអូសជាបណ្ដោះអាសន្ន)។

ង. មូលហេតុ(ដីកាសម្រេចរឹបអូសជាបណ្ដោះលេខ ចុះថ្ងៃទី ខែ ឆ្នាំ)។

ច. សរសេរឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត។

ឆ. សរសេរឈ្មោះ និងអាសយដ្ឋានរបស់កូនបំណុលនៃការអនុវត្ត។

ដោយមានការភ្ជាប់ជូនឯកសារយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន និងសេចក្ដីបញ្ជាក់ដំបូងពីកម្មសិទ្ធិជាអាទិ៍ របស់កូនបំណុលនៃការអនុវត្ត។[87]

ទោះបីជារដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ អាចទទួលលិខិតផ្ដុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នពិតមែន ប៉ុន្តែរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ មិនមានសិទ្ធិផ្ដល់សេវារដ្ឋបាលទាក់ទងនឹងការផ្ដុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ននោះទេ ដោយរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនច្បាប់ដើមនៃលិខិតផ្ដុកផ្ដាក់អំពីការរឹបអូសជាបណ្ដោះអាសន្ន និងឯកសារពាក់ព័ន្ធផ្សេងៗទៀត ទៅកាន់រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ដែលអចលនវត្ថុតាំងនៅ ដោយគ្មានការយឺតយ៉ាវ ហើយបន្ទាប់ពីរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត បានទទួលលិខិតផ្ដុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នរួចហើយ រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវបញ្ជូនលិខិតផ្ដុកផ្ដាក់នោះ និងឯកសារផ្សេងៗ ព្រមទាំងលិខិតអនុញ្ញាតឱ្យចាប់ផ្ដើមនីតិវិធីចុះបញ្ជីលើកដំបូង ទៅរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលអចលនវត្ថុតាំងនៅ ដើម្បីអនុវត្តនីតិវិធីចុះបញ្ជីលើកដំបូងឱ្យបានឆាប់រហ័ស និងគ្មានការយឺតយ៉ាវ ដោយអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។[88] ទន្ទឹមគ្នានេះដែរម្ចាស់បំណុលនៃការអនុវត្តមានកាតព្វកិច្ចបង់ជាមុនការចំណាយក្នុងការចុះបញ្ជីដីលើកដំបូង ឬសោហ៊ុយនៃការរឹបអូសជាបណ្ដោះអាសន្ន ជាអាទិ៍។[89] នៅពេលបញ្ចប់នីតិវិធីនៃការចុះបញ្ជីលើកដំបូង រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវសរសេរក្នុង "សៀវភៅគោលបញ្ជីដីធ្លី" នៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ដូច **ការផ្ដុកផ្ដាក់ឱ្យចុះបញ្ជីចំពោះអចលនវត្ថុដែលបានចុះបញ្ជីដីធ្លី** (ប្លង់រឹង) ខាងលើនេះ។[90]

[87] ប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី, លេខ ២១៤ ប្រកដនស, ២១ វិច្ឆិកា ២០១៤, ប្រការ៦

[88] ប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី, លេខ ២១៤ ប្រកដនស, ២១ វិច្ឆិកា ២០១៤, ប្រការ៥

[89] ប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី, លេខ ២១៤ ប្រកដនស, ២១ វិច្ឆិកា ២០១៤, ប្រការ៩

[90] ប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី, លេខ ២១៤ ប្រកដនស, ២១ វិច្ឆិកា ២០១៤, ប្រការ៨ និងប្រកាសអន្តរក្រសួងស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី, លេខ ៥៩ប្រកដនស/១១, ០៣ ឧសភា ២០១១, ប្រការ៣២ ចំណុច ក

## ផ្នែកទី២៖ ការផ្អាក និងការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន

គួររំលឹកថាការអនុវត្តរឹបអូសជាបណ្តោះអាសន្នមិនមែនផ្អាក ឬលុបចោលតាមតែអំពើចិត្តនោះទេ គឺត្រូវមានមូលហេតុត្រឹមត្រូវតាមច្បាប់កំណត់ ទើបការអនុវត្តរឹបអូសជាបណ្តោះអាសន្នត្រូវបានផ្អាក ឬលុបចោល ដែលក្នុងចំណុចនេះយើងនឹងសិក្សាពីមូលហេតុដែលនាំឱ្យការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ត្រូវបានតុលាការសម្រេចឱ្យផ្អាក ឬលុបចោលតែម្តង ដែលមានបង្ហាញក្នុងចំណុច (១) **ការផ្អាកការអនុវត្តរឹបអូសជាបណ្តោះអាសន្ន** និង (២) **ការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន** ព្រមទាំង (៣) **ការផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន** ដោយបង្ហាញអំពីនីតិវិធីផ្ទុកផ្តាក់ឱ្យលុបចោលការចុះបញ្ជីរឹបអូសជាបណ្តោះអាសន្ន និងចំណុចដែលត្រូវសរសេរបន្ថែមក្នុងលិខិតផ្ទុកផ្តាក់នោះផងដែរ។

### ១. ការផ្អាកការអនុវត្តរឹបអូសជាបណ្តោះអាសន្ន

ក្នុងចំណុចនេះមានការបកស្រាយពីសញ្ញាណទូទៅ ពាក់ព័ន្ធនឹងការផ្អាកការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ព្រមទាំងមូលហេតុចម្បងផ្សេងៗដែលនាំឱ្យតុលាការសម្រេចផ្អាកការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ដោយនឹងបញ្ជាក់នៅក្នុងចំណុចស្តីពី (១.១) **ខ្លឹមសារនៃការផ្អាកការអនុវត្តរឹបអូសជាបណ្តោះអាសន្ន** និង (១.២) **មូលហេតុដែលនាំឱ្យផ្អាកការអនុវត្តរឹបអូសជាបណ្តោះអាសន្ន**។

#### ១.១. ខ្លឹមសារនៃការផ្អាកការអនុវត្តរឹបអូសជាបណ្តោះអាសន្ន

ការផ្អាកការអនុវត្តរឹបអូសជាបណ្តោះអាសន្ន គឺជាស្ថានភាពដែលតុលាការអនុវត្តមិនអាចចាប់ផ្តើម ឬបន្តការអនុវត្តរឹបអូសជាបណ្តោះអាសន្នតាមច្បាប់កំណត់ ហើយទំហំនៃការផ្អាកប្រែប្រួលតាមមូលហេតុនៃការផ្អាក។[91] ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន មិនត្រូវការចំណាយរយៈពេលដើម្បីអនុវត្តនោះទេ ដោយបញ្ចប់ត្រឹមដំណាក់កាលរឹបអូសជាបណ្តោះអាសន្នតែប៉ុណ្ណោះ ហេតុនេះហើយបើមូលហេតុនៃការផ្អាកការអនុវត្តបានកើតឡើង បន្ទាប់ពីការអនុវត្តរឹបអូសជាបណ្តោះអាសន្នត្រូវបានបញ្ចប់នោះ ការផ្អាកការអនុវត្តរឹបអូសជាបណ្តោះអាសន្ន គឺគ្មានន័យអ្វីសោះឡើយ។ ទោះបីជាយ៉ាងនេះក្តីមិនមែនមានន័យថា ការផ្អាកការអនុវត្តក្នុងនីតិវិធីនេះមិនមានប្រសិទ្ធភាពនោះទេ គឺគ្រាន់តែទាមទារឱ្យផ្អាកមុនពេលបញ្ចប់នីតិវិធីអនុវត្តតែប៉ុណ្ណោះ។

#### ១.២. មូលហេតុដែលនាំឱ្យផ្អាកការអនុវត្តរឹបអូសជាបណ្តោះអាសន្ន

ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន អាចត្រូវបានផ្អាកបើមានមូលហេតុដូចខាងក្រោមនេះ៖

**ក. ការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន**

នៅពេលមានពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការអាចបង្គាប់ឱ្យផ្អាកឬលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្នបាន ប៉ុន្តែមិនមែនមានន័យថាការដាក់ពាក្យសុំតវ៉ាចំពោះ

[91] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, បោះពុម្ពឆ្នាំ២០០៩, ភាគទី២ ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ, ទំព័រទី៧០

ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន បានបង្កើតអានុភាពផ្អាក ឬលុបចោលការអនុវត្តនោះទេ គឺត្រូវមានសេចក្ដីសម្រេចដោយឡែកមួយទៀត ដែលបង្គាប់ឱ្យផ្អាក ឬលុបចោលការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន។ ដោយសេចក្ដីសម្រេចពីការផ្អាក ឬលុបចោលការអនុវត្តនេះ ត្រូវធ្វើឡើងតាមពាក្យសុំរបស់កូនបំណុលនៃការអនុវត្តដោយឱ្យដាក់ប្រាតិភោគ រហូតដល់មានការសម្រេចសេចក្ដីលើពាក្យសុំតវ៉ាចំពោះដីសម្រេចរឹបអូសជាបណ្ដោះអាសន្ន ហើយត្រូវមានសេចក្ដីបញ្ជាក់ដំបូងអំពីស្ថានភាពដែលច្បាស់ថានឹងក្លាយជាមូលហេតុ នៃការលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន និងការបារម្ភថាការខូចខាតដែលមិនអាចសងបាន នឹងកើតឡើងដោយសារការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន។[92] ***"ស្ថានភាពដែលច្បាស់ថានឹងក្លាយជាមូលហេតុនៃការលុបដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន"*** គឺជាស្ថានភាពច្បាស់លាស់ដែលថាផ្ទុយនឹងសិទ្ធិដែលត្រូវបានរក្សាការពារ និងភាពចាំបាច់នៃការរក្សាការពារ **ឧទាហរណ៍៖** ករណីមានកំហុសឆ្គងពាក់ព័ន្ធនឹងការបកស្រាយច្បាប់ ឬករណីដែលគ្មានភាពចាំបាច់ក្នុងការរក្សាការពារ ជាអាទិ៍ ហើយពាក្យថា ***"ការបារម្ភថាការខូចខាតដែលមិនអាចសងបាន នឹងកើតឡើងដោយសារការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន"*** សំដៅលើករណីដែលសំណងជាប្រាក់តាមក្រោយទំនងជាមិនអាចសងគ្រប់ចំពោះការខូចខាតរបស់កូនបំណុល ដែលកើតឡើងដោយសារការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ឧទាហរណ៍៖ មុខរបររបស់កូនបំណុលនៃការអនុវត្តនឹងត្រូវក្ស័យធន ឬមិនអាចរស់បាន ដោយសារការរឹបអូសជាបណ្ដោះអាសន្ន។[93]

### ខ. ពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

មិនខុសគ្នាពីករណីខាងលើនេះទេ ទោះបីជាកូនបំណុលនៃការអនុវត្តបានដាក់ពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដោយសារការផ្លាស់ប្ដូរស្ថានភាពក៏ដោយ ក៏ការដាក់ពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននេះមិនបានបង្កើតអានុភាពឱ្យផ្អាក ឬលុបចោលការអនុវត្តនោះទេ ប៉ុន្តែតុលាការអាចបង្គាប់ឱ្យផ្អាក ឬលុបចោលការអនុវត្ត រហូតដល់មានសេចក្ដីសម្រេចពីពាក្យសុំទាមទារឱ្យលុបដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដោយសេចក្ដីសម្រេចដោយឡែកមួយទៀត ដែលធ្វើឡើងតាមពាក្យសុំរបស់កូនបំណុលនៃការអនុវត្តដោយឱ្យដាក់ប្រាតិភោគ និងមានសេចក្ដីបញ្ជាក់ដំបូងស្ថានភាពដែលច្បាស់ថានឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន និងការបារម្ភថាការខូចខាតដែលមិនអាចសងបាននឹងកើតឡើងដោយសារការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន។[94]

[92] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៥១

[93] សេចក្ដីកំណត់ចំពោះមាត្រានីមួយនៃក្រមនីតិវិធីរដ្ឋប្បវេណី, បោះពុម្ពឆ្នាំ២០០៧, មាត្រា៥៥១

[94] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦០ និងមាត្រា៥៥១

### គ. បណ្តឹងជំទាស់នឹងដីកាសម្រេចអំពីពាក្យសុំតវ៉ា ឬពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

ដូចគ្នានឹងករណីខាងលើនេះដែរ អានុភាពនៃបណ្តឹងជំទាស់នឹងដីកាសម្រេចអំពីពាក្យសុំតវ៉ា ឬពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន មិនធ្វើឱ្យការអនុវត្តរឹបអូសជាបណ្តោះអាសន្នត្រូវបានផ្អាក ឬលុបចោលដោយស្វ័យប្រវត្តិនោះទេ ក្នុងករណីនេះតុលាការអាចបង្គាប់ឱ្យផ្អាក ឬលុបចោលការអនុវត្ត រហូតដល់មានការសម្រេចសេចក្តីលើបណ្តឹងជំទាស់ ដោយសេចក្តីសម្រេចផ្សេងមួយទៀត តាមរយៈពាក្យសុំរបស់ភាគីដោយឱ្យដាក់ប្រាតិភោគ និងមានសេចក្តីបញ្ជាក់ដំបូងអំពីស្ថានភាពដែលច្បាស់ថា នឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន និងការបារម្ភថាការខូចខាតដែលមិនអាចសងបាននឹងកើតឡើងដោយសារការអនុវត្តរឹបអូសជាបណ្តោះអាសន្ន។[95]

### ឃ.បណ្តឹងតវ៉ាចំពោះការទាមទារ

នៅពេលកូនបំណុលនៃការអនុវត្ត បានដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ហើយបើមានសេចក្តីបញ្ជាក់ដំបូងពីមូលហេតុតវ៉ាដែលអះអាងនោះ តុលាការដែលទទួលបណ្តឹងអាចបង្គាប់ឱ្យផ្អាកការអនុវត្តរឹបអូសជាបណ្តោះអាសន្នបានមួយរយៈ តាមពាក្យសុំរបស់កូនបំណុលនៃការអនុវត្ត ដោយឱ្យដាក់ប្រាតិភោគ ឬមិនឱ្យដាក់ប្រាតិភោគបាន[96]។ បណ្តឹងតវ៉ាចំពោះការទាមទារ គឺជាបណ្តឹងដែលកូនបំណុលនៃការអនុវត្តតវ៉ាចំពោះអត្ថិភាព ឬអត្ថន័យនៃសិទ្ធិទាមទារ[97] ដែលកំណត់ក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ហើយមូលហេតុសិទ្ធិដែលត្រូវបានរក្សាការពារដោយច្បាប់សារធាតុត្រូវបានប្រែប្រួល ឧទាហរណ៍៖ ការសង ការទូទាត់ ការលះបង់ជាអាទិ៍។[98]

### ង. បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត

នៅពេលកូនបំណុលនៃការអនុវត្ត បានដាក់ពាក្យបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត ហើយបើមានសេចក្តីបញ្ជាក់ដំបូងពីមូលហេតុតវ៉ាដែលអះអាងនោះ តុលាការដែលទទួលបណ្តឹងអាចបង្គាប់ឱ្យផ្អាកការអនុវត្តរឹបអូសជាបណ្តោះអាសន្នបានមួយរយៈ តាមពាក្យសុំរបស់កូនបំណុលនៃការអនុវត្ត ដោយឱ្យដាក់ប្រាតិភោគ ឬមិនឱ្យដាក់ប្រាតិភោគបាន។[99] បណ្តឹងតវ៉ាចំពោះរូបមន្តអនុវត្តនេះ គឺជាបណ្តឹងដែលកូនបំណុលនៃការអនុវត្តតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្តពិសេស ដោយអះអាងពីនត្ថិភាព នៃហេតុដែលត្រូវនឹងលក្ខខណ្ឌនៃការ

[95] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦១ កថាខណ្ឌទី៣ និងមាត្រា៥៥១

[96] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦៤ និងមាត្រា៣៦៧

[97] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦៤ មាត្រា៣៦៧ និងមាត្រា៣៦៣

[98] សេចក្តីកំណត់ចំពោះមាត្រានីមួយនៃក្រមនីតិវិធីរដ្ឋប្បវេណី, បោះពុម្ពឆ្នាំ២០០៧, មាត្រា៣៦៣

[99] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦៤ និងមាត្រា៣៦៧

ផ្តល់រូបមន្តអនុវត្ត រួមមានការបំពេញលក្ខខណ្ឌ ការមកដល់នៃពេលកំណត់មិនពិតប្រាកដ ឬការអនុញ្ញាតឱ្យបុគ្គលក្រៅពីភាគីដែលបានកំណត់ក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬកូនបំណុលនៃការអនុវត្ត។[100]

### ច. បណ្តឹងតវ៉ារបស់តតិយជន

នៅពេលមានពាក្យបណ្តឹងតវ៉ារបស់តតិយជន ហើយបើមានសេចក្តីបញ្ជាក់ដំបូងពីមូលហេតុតវ៉ាដែលអះអាងនោះ តុលាការដែលទទួលបណ្តឹងអាចបង្គាប់ឱ្យផ្អាកការអនុវត្តរឹបអូសជាបណ្តោះអាសន្នមួយរយៈតាមពាក្យសុំរបស់កូនបំណុលនៃការអនុវត្ត ដោយឱ្យដាក់ប្រាតិភោគ ឬមិនឱ្យដាក់ប្រាតិភោគបាន។[101] បណ្តឹងតវ៉ារបស់តតិយជន ត្រូវធ្វើឡើងដោយតតិយជន ក្នុងគោលបំណងឱ្យតតិយជនក្រៅពីបុគ្គលដែលទទួលអានុភាពនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ទាមទារកុំឱ្យធ្វើការរឹបអូសជាបណ្តោះអាសន្ន ដោយហេតុថាការរឹបអូសជាបណ្តោះអាសន្នបានធ្វើឡើងចំពោះទ្រព្យសម្បត្តិរបស់តតិយជននោះ។[102]

## ២. ការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន

ចំពោះការសិក្សានៅត្រង់ចំណុចនេះ នឹងផ្តោតសំខាន់លើចំណុចចំនួន ០២ (ពីរ) រួមមាន **(២.១) ខ្លឹមសារនៃការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន** ដោយស្វែងយល់ពីនិយមន័យនៃការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន និង **(២.២) មូលហេតុដែលនាំឱ្យលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន** នឹងបង្ហាញពីមូលហេតុមួយចំនួននាំឱ្យការអនុវត្តរឹបអូសជាបណ្តោះអាសន្នត្រូវបានតុលាការសម្រេចលុបចោលផងដែរ។

### ២.១ ខ្លឹមសារនៃការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន

ការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន គឺជាការជម្រះចេញការចាត់ចែងការអនុវត្តទាំងមូល ឬផ្នែកណាមួយដែលបានធ្វើរួចហើយដោយតុលាការអនុវត្ត ក្នុងដំណើរការនីតិវិធីនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន។[103] ការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន មានលក្ខណៈស្រដៀងនឹងការលុបចោលការចាត់ចែងការអនុវត្តដោយបង្ខំ ហើយមិនមានភាពខុសគ្នាពីការផ្អាកការអនុវត្តរឹបអូសជាបណ្តោះអាសន្ននោះទេ គឺការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ត្រូវមានមូលហេតុច្បាស់លាស់ជាមុនសិន ទើបតុលាការអាចសម្រេចលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ននោះបាន។

---

[100] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦៤ និងមាត្រា៣៦៤ និងសេចក្តីកំណត់ចំពោះមាត្រានីមួយនៃក្រមនីតិវិធីរដ្ឋប្បវេណី, បោះពុម្ពឆ្នាំ២០០៧, មាត្រា៣៦៤

[101] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦៤ និងមាត្រា៣៦៧

[102] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦៤ និងមាត្រា៣៦៥ និងសេចក្តីកំណត់ចំពោះមាត្រានីមួយនៃក្រមនីតិវិធីរដ្ឋប្បវេណី, បោះពុម្ពឆ្នាំ២០០៧, មាត្រា៣៦៥

[103] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, បោះពុម្ពឆ្នាំ២០០៩, ភាគទី២ ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ, ទំព័រទី៧១

### ២.២ មូលហេតុដែលនាំឱ្យលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន

តុលាការត្រូវលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន បើមានហេតុដូចខាងក្រោមនេះ៖

ក. ឯកសារយថាភូតនៃសេចក្តីសម្រេចដែលកំណត់ថា លុបចោលលិខិតអនុវត្តក្រៅពីលិខិតយថាភូតកំណត់ក្នុងចំណុច ច កថាខណ្ឌ២ នៃមាត្រា៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឬឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ថា លុបចោលការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន។

ខ. ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ថា មិនអនុញ្ញាតឱ្យអនុវត្តដោយបង្ខំ។

គ. អនុសារសាលក្រមស្ថាពរ ឬអនុសារសាលដីកាស្ថាពរ ដែលប្រកាសថា ការផ្សះផ្សា ឬការទទួលស្គាល់ ដែលទាក់ទងនឹងលិខិតអនុវត្តគ្មានអានុភាព។

ឃ. ឯកសារចម្លងយថាភូតនៃកំណត់ហេតុ ឬឯកសារផ្សេងទៀត ដែលក្រឡាបញ្ជីបានធ្វើ ដែលបញ្ជាក់ថា លិខិតអនុវត្តចាប់ពីចំណុច ខ រហូតដល់ចំណុច ង កថាខណ្ឌ២ នៃមាត្រា៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវបានបាត់បង់អានុភាព ដោយសារការដកពាក្យបណ្តឹង ឬមូលហេតុផ្សេងទៀត។

ង. ឯកសារចម្លងយថាភូតនៃកំណត់ហេតុពីការផ្សះផ្សាតាមនីតិវិធីនៃការសម្រេចសេចក្តី ដែលបានកំណត់ថា មិនឱ្យអនុវត្តរឹបអូសដោយបង្ខំ ឬដកពាក្យសុំឱ្យអនុវត្តដោយបង្ខំនោះវិញ។

ច. ឯកសារបញ្ជាក់អំពីការដាក់ប្រាតិភោគ ដើម្បីរួចផុតពីការអនុវត្តដោយបង្ខំ។

ឆ. ឯកសារចម្លងយថាភូតនៃសេចក្តីដែលកំណត់ការបង្គាប់ឱ្យផ្អាកការអនុវត្ត និងលុបចោលការចាត់ចែងអនុវត្ត។[104]

ជ. កូនបំណុលនៃការអនុវត្ត បានធ្វើការផ្ញើប្រាក់រំដោះស្មើនឹងចំនួនប្រាក់ដែលបានកំណត់ដោយតុលាការ។[105]

## ៣. ការផ្តុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន

ដើម្បីលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ក្រឡាបញ្ជីត្រូវធ្វើការផ្តុកផ្តាក់ទៅរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ឱ្យធ្វើការលុបចោលការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន[106] ដោយការផ្តុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ននេះ ត្រូវធ្វើឡើងដូចការផ្តុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នដែរ ពោលគឺលិខិតផ្តុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ត្រូវបញ្ជូនទៅផ្នែកជួរមុខ

[104] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦៤ និងមាត្រា៣៧០ កថាខណ្ឌទី១

[105] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦៩

[106] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦៧ កថាខណ្ឌទី៤ និងមាត្រា៤២៨

នៃច្រកចេញចូលតែមួយរបស់រដ្ឋបាលរាជធានី ខេត្តជាមុនសិន បន្ទាប់មកទើបការិយាល័យច្រកចេញចូលតែមួយបញ្ជូនលិខិតផ្ទុកផ្តាក់នេះបន្តទៅរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ដើម្បីដំណើរការនីតិវិធីបន្ទាប់។ កំឡុងពេលនោះផងដែរ ការិយាល័យច្រកចេញចូលតែមួយនឹងចេញ "**បង្កាន់ដៃទទួលពាក្យ**" ដើម្បីបញ្ជាក់អំពីការទទួលយកលិខិតផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ទន្ទឹមនឹងនេះម្ចាស់បំណុលក៏ត្រូវ "**បង់សេវាសាធារណៈ**" ដូចកំណត់ក្នុងប្រកាសស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ផងដែរ។ ហើយលិខិតផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ត្រូវសរសេរបន្ថែមនូវចំណុចមួយចំនួនដូចខាងក្រោមនេះ៖

កម្មវត្ថុ(សរសេរអំពីខ្លឹមសារផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន)។

ក. អត្តសញ្ញាណនៃអចលនវត្ថុ(លេខក្បាលដី ឬលេខប័ណ្ណ និងទីតាំងដី)។

ខ. ឈ្មោះកម្មសិទ្ធិករ(អាសយដ្ឋាន)។

គ. គោលបំណងនៃការចុះបញ្ជី(ការលុបចោលការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន)។

ឃ. មូលហេតុ(ដីកាសម្រេចលេខ ចុះថ្ងៃ ខែ ឆ្នាំ និងឈ្មោះតុលាការ)។

ង. ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត(អាសយដ្ឋាន)។

ច. ឈ្មោះកូនបំណុលនៃការអនុវត្ត(អាសយដ្ឋាន)។[107]

ហើយឯកសារដែលត្រូវភ្ជាប់ជូន គឺអាស្រ័យតាមមូលហេតុនៃការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន។[108]

ជាកិច្ចបន្ទាប់សុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវសរសេរក្នុង "សៀវភៅគោលបញ្ជីដីធ្លី" នៅខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ដោយត្រូវសរសេរថា "ត្រូវបានលុបការរឹបអូសជាបណ្តោះអាសន្ន...... ដែលតុលាការ ......... បានចេញដីកាសម្រេចលេខ......... ចុះថ្ងៃទី........ ខែ...... ឆ្នាំ....... តាមដីកាសម្រេចលុបចោលលេខ..... ចុះថ្ងៃទី...... ខែ...... ឆ្នាំ....... របស់តុលាការ.......... លរ.Aj..... ឬដកពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬដកពាក្យសុំអនុវត្តរឹបអូសជាបណ្តោះអាសន្ន ចុះថ្ងៃទី.... ខែ..... ឆ្នាំ...... (ជាទឹកខៀវ ឬខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម)"។[109]

[107] ប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី, លេខ ៥៩ប្រកដនស/១១, ០៣ ឧសភា ២០១១, ប្រការ១៧

[108] ប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី, លេខ ៥៩ប្រកដនស/១១, ០៣ ឧសភា ២០១១, ប្រការ១៧ កថាខណ្ឌទី៤ (ឯកសារភ្ជាប់ជាមួយ)

[109] ប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី, លេខ ៥៩ប្រកដនស/១១, ០៣ ឧសភា ២០១១, ប្រការ៣៣ ចំណុច ក

# ជំពូកទី៤

# ការប្តឹងតវ៉ាក្នុងរឿងក្តី
# រឹបអូសជាបណ្ដោះអាសន្ន

# ជំពូកទី៤
# ការប្តឹងតវ៉ាក្នុងរឿងក្តីរឹបអូសជាបណ្តោះអាសន្ន

ក្នុងជំពូកចុងក្រោយនេះ នឹងធ្វើការបកស្រាយចំណុចសំខាន់ៗចំនួន ០២ (ពីរ) ដោយ **(ផ្នែកទី១) ការប្តឹងចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន** ដែលសិក្សាលម្អិតពីការតវ៉ា និងជំទាស់ ក្នុងករណីដែលភាគីមិនពេញចិត្តចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន និង **(ផ្នែកទី២) ការលុបដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន** ដោយសិក្សាអំពីហេតុផ្សេងៗពាក់ព័ន្ធនឹងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវបានលុប។

## ផ្នែកទី១៖ ការប្តឹងតវ៉ាក្នុងរឿងក្តីរឹបអូសជាបណ្តោះអាសន្ន

ការប្តឹងចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នមានដូចតទៅ (១) **ការតវ៉ា** បានកំណត់ពីរបៀបដែលកូនបំណុលតវ៉ានឹងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន និង (២) **ការប្តឹងជំទាស់** ដោយនឹងបង្ហាញពីការប្តឹងជំទាស់នឹងដីកាសម្រេចមួយចំនួនដែលមានកំណត់ក្នុងនីតិវិធីរឹបអូសជាបណ្តោះអាសន្ន។

### ១. ការតវ៉ា

នៅដំណាក់កាលដំបូងពេលដែលម្ចាស់បំណុល ដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ តុលាការនឹងចេញដីកាសម្រេចនោះ ដោយមិនបានកោះហៅកូនបំណុលមកសាកសួរ ឬកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ទេ ដោយតុលាការយកសេចក្តីបញ្ជាក់ដំបូងរបស់ម្ចាស់បំណុលជាមូលដ្ឋានសម្រាប់ចេញដីកាសម្រេច។ បើក្រឡេកមើលស្ថានភាពនេះប្រៀបដូចជាច្បាប់បានលំអៀងទៅភាគីម្ចាស់បំណុល ប៉ុន្តែជាក់ស្តែងបើមិនចេញដីកាសម្រេចរឹបអូសភ្លាមនោះទេ គឺមានភាពផ្ទុយពីចរិតលក្ខណៈបន្ទាន់នៃការរឹបអូសជាបណ្តោះអាសន្ន ហេតុដូច្នេះហើយទើបច្បាប់បានបើកផ្លូវឱ្យកូនបំណុលអាចធ្វើការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តាមរយៈការដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារជាលាយលក្ខណ៍អក្សរ[110] ទៅតុលាការដែលបានចេញដីកាសម្រេចនោះ[111] ដោយចំណុចនេះយើងនឹងពិនិត្យពាក់ព័ន្ធនឹង (១.១) **ការវិនិច្ឆ័យ** នូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន នឹងបកស្រាយ (១.២) **ដីកាសម្រេចអំពីពាក្យសុំតវ៉ា** ដោយត្រូវស្វែងយល់ថាបន្ទាប់ពីតុលាការបញ្ចប់ការវិនិច្ឆ័យហើយតើដីកាសម្រេចអំពីពាក្យសុំតវ៉ា ត្រូវកំណត់ខ្លឹមសារ ឬអត្ថន័យយ៉ាងដូចម្តេចខ្លះ?

#### ១.១. ការវិនិច្ឆ័យ

ជាទូទៅនៅពេលម្ចាស់បំណុលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការនឹងចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដោយមិនឆ្លងកាត់ការសាកសួរ ឬការទាញហេតុផលដោយ

[110] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣៤ ចំណុច គ
[111] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៥០

ផ្ទាល់មាត់ឡើយ ដោយសំអាងតាមសេចក្ដីបញ្ជាក់ដំបូងរបស់ម្ចាស់បំណុល ប៉ុន្តែនៅពេលដែលកូនបំណុលដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន តុលាការត្រូវកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬធ្វើការសាកសួរនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបាន។[112] ការកំណត់បែបនេះ គឺមានគោលបំណងសំខាន់ដើម្បីធានាដល់ការផ្ដល់ឱកាសឱ្យភាគីទាំងសងខាងជាពិសេសកូនបំណុលអាចចូលរួមក្នុងដំណើរការនីតិវិធីបាន ពោលគឺនៅកាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់ ឬការសាកសួរដែលភាគីទាំងសងខាងអាចចូលរួមបាន តុលាការត្រូវធានាឱ្យបាននូវកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបានតែម្ដងក៏ជាការគ្រប់គ្រាន់។[113]

### ១.២. ការបញ្ចប់ការវិនិច្ឆ័យ

ដើម្បីបញ្ចប់ការវិនិច្ឆ័យអំពីការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ជាគោលការណ៍ តុលាការត្រូវសម្រេចបញ្ចប់ការវិនិច្ឆ័យ ដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យមួយ។ ជាទូទៅតុលាការអាចសម្រេចបញ្ចប់ការវិនិច្ឆ័យរបស់ខ្លួននៅពេលណាក៏បាន ហើយការកំណត់អំឡុងពេលសមរម្យ ដើម្បីផ្ដល់ឱកាសឱ្យភាគីដាក់ឯកសារបន្ថែមជូនតុលាការឱ្យបានគ្រប់គ្រាន់ ដើម្បីវិនិច្ឆ័យមុនចេញដីកាសម្រេចអំពីពាក្យសុំតវ៉ា។[114] ផ្ទុយពីនេះវិញប្រសិនបើតុលាការយល់ឃើញថា បានផ្ដល់ឱកាសឱ្យភាគីដាក់ឯកសារសម្រាប់វិនិច្ឆ័យគ្រប់គ្រាន់ហើយ តុលាការអាចប្រកាសបញ្ចប់ការវិនិច្ឆ័យនៅកាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការសាកសួរដែលភាគីទាំងសងខាងអាចចូលរួមបាននោះតែម្ដងក៏បានដែរ។[115]

### ១.៣. ដីកាសម្រេចអំពីពាក្យសុំតវ៉ា

បន្ទាប់ពីបញ្ចប់ការវិនិច្ឆ័យ តុលាការនឹងចេញដីកាសម្រេចអំពីពាក្យសុំតវ៉ា ហើយត្រូវបញ្ជូនទៅភាគីទាំងសងខាង[116] ដោយតុលាការត្រូវសម្រេចក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ាខ្លឹមសារដូចខាងក្រោម៖

ក. **ទទួលស្គាល់៖** បើដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន មានភាពត្រឹមត្រូវ តុលាការត្រូវចេញដីកាសម្រេច ដោយទទួលស្គាល់ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នដើម។

ខ. **ផ្លាស់ប្ដូរ៖** បើដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន មានផ្នុកចំណុចដែលត្រូវធ្វើការផ្លាស់ប្ដូរ តុលាការត្រូវចេញដីកាសម្រេចផ្លាស់ប្ដូរ ដូចជាបញ្ចូលលក្ខខណ្ឌដែលម្ចាស់បំណុលត្រូវដាក់ប្រាតិភោគ ឬបន្ថែមប្រាតិភោគជាដើម។

---

[112] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៥២

[113] សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, បោះពុម្ពឆ្នាំ២០០៩, ភាគទី២ ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ, ទំព័រទី២០៣

[114] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៥៣ កថាខណ្ឌទី១ និងសេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, បោះពុម្ពឆ្នាំ២០០៩, ភាគទី២ ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ, ទំព័រទី២០៣

[115] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៥៣ កថាខណ្ឌទី២

[116] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៥៤ កថាខណ្ឌទី៣ និងមាត្រា៥៤៣

គ. **លុបចោល៖** បើដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន មានភាពមិនត្រឹមត្រូវ តុលាការត្រូវចេញដីកាសម្រេច លុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននោះ តុលាការអាចដាក់លក្ខខណ្ឌឱ្យកូនបំណុលដាក់ប្រាតិភោគបាន។[117]

ដីកាសម្រេចអំពីពាក្យសុំតវ៉ា មិនមានអានុភាពអនុវត្តភ្លាមនោះទេ ប្រសិនបើមិនទាន់ចូលជាស្ថាពរ ក៏ប៉ុន្តែប្រសិនយល់ឃើញថាចាំបាច់ពិសេសតុលាការអាចប្រកាសថា ដីកាសម្រេចអំពីពាក្យសុំតវ៉ានេះ មានអានុភាពអនុវត្តភ្លាមៗបាន។[118]

## ២. ការប្ដឹងជំទាស់

បណ្ដឹងជំទាស់ គឺជាបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដោយបណ្ដឹងជំទាស់អាចធ្វើឡើងបាន លុះត្រាតែច្បាប់កំណត់យ៉ាងច្បាស់ថាអាចប្ដឹងជំទាស់បាន[119] ទើបនីតិវិធីនៃបណ្ដឹងជំទាស់អាចប្រព្រឹត្តទៅបាន ចំពោះការរឹបអូសជាបណ្ដោះអាសន្ន ច្បាប់បានអនុញ្ញាតឱ្យធ្វើការប្ដឹងជំទាស់បាន ហើយការប្ដឹងជំទាស់គឺដើម្បីធានាដល់ការវិនិច្ឆ័យ និងការសម្រេចសេចក្ដីដោយតុលាការជាន់ខ្ពស់។ បណ្ដឹងជំទាស់ត្រូវដាក់ក្នុងអំឡុងពេល ០២ (ពីរ) សប្ដាហ៍ ដែលអំឡុងពេលនេះមិនអាចពន្យារបាននោះទេ[120] គិតចាប់ពីថ្ងៃដែលទទួលការបញ្ជូនឯកសារដែលបង្ហាញនៅចំណុច **(២.១) មូលហេតុបណ្ដឹងជំទាស់** និង **(២.២) នីតិវិធីនៃបណ្ដឹងជំទាស់។**

### ២.១. ដីកាសម្រេចដែលអាចប្ដឹងជំទាស់

ការដាក់ពាក្យបណ្ដឹងជំទាស់អាចប្រព្រឹត្តិទៅបាន អាស្រ័យលើចំណុចដែលច្បាប់កំណត់ឱ្យប្ដឹង ធ្លាប់បានបញ្ជាក់រួចហើយថា ចំណុចដែលអាចប្ដឹងជំទាស់បាន លុះត្រាតែមានច្បាប់ចែងយ៉ាងច្បាស់ថាអាចប្ដឹងជំទាស់បានដូច្នេះយើងនឹងបង្ហាញអំពីចំណុចជាក់លាក់មួយចំនួន ដែលភាគីអាចប្ដឹងជំទាស់បានរួមមាន **(២.១.១) ដីកាសម្រេចអំពីពាក្យសុំតវ៉ា** និង **(២.១.២) ដីកាសម្រេចអំពីពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរក្សាការពារ** ព្រមទាំង **(២.១.៣) ដីកាសម្រេចលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ** លើសពីនេះទៀតក្នុងចំណុចនេះក៏មានបកស្រាយពីកាលៈទេសៈដែលបណ្ដាលឱ្យបណ្ដឹងជំទាស់មិនអាចធ្វើទៅបាន។

#### ២.១.១. ដីកាសម្រេចអំពីពាក្យសុំតវ៉ា

បន្ទាប់ពីបញ្ចប់ការវិនិច្ឆ័យក្នុងការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន តុលាការនឹងចេញដីកាសម្រេចអំពីពាក្យសុំតវ៉ា ដែលមានអត្ថន័យទទួលស្គាល់ ឬផ្លាស់ប្ដូរ ឬលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ហើយបន្ទាប់ពីភាគីទទួលដីកាសម្រេចអំពីពាក្យសុំតវ៉ាតាមរយៈការបញ្ជូនរួចមក បើមិនពេញ

---

[117] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៥៤ កថាខណ្ឌទី១ និងកថាខណ្ឌទី២

[118] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៥៦

[119] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥៩ កថាខណ្ឌទី២

[120] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦១ កថាខណ្ឌទី១ និងកថាខណ្ឌទី២

ចិត្តនឹងដីកាសម្រេចនេះទាំងម្ចាស់បំណុល ឬកូនបំណុលអាចដាក់ពាក្យបណ្ដឹងជំទាស់នឹងដីកាសម្រេចអំពីពាក្យសុំតវ៉ាបាន។[121]

### ២.១.២. ដីកាសម្រេចអំពីពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរក្សាការពារ

ពេលកូនបំណុលបានដាក់ពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដោយហេតុថាម្ចាស់បំណុលមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ឬការផ្លាស់ប្ដូរស្ថានភាព ក្នុងករណីនេះដីកាសម្រេចអំពីពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន រួមមាន ដីកាសម្រេចលើកចោលពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬដីកាសម្រេចលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន។ នៅពេលភាគីទទួលដីកាសម្រេចនេះតាមរយៈការបញ្ជូនរួចហើយ[122] ក្នុងករណីមិនពេញចិត្តនឹងដីកាសម្រេចនេះទាំងម្ចាស់បំណុល ឬកូនបំណុលអាចដាក់ពាក្យបណ្ដឹងជំទាស់ចំពោះដីកាសម្រេចនោះបាន។[123]

### ២.១.៣. ដីកាសម្រេចលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ

ដើម្បីទទួលបានដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ម្ចាស់បំណុលត្រូវដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ក្នុងករណីដែលតុលាការពិនិត្យឃើញថាបានបំពេញលក្ខខណ្ឌនៃការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នអស់ហើយ តុលាការនឹងចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ប៉ុន្តែក្នុងករណីដែលមិនទាន់បំពេញលក្ខខណ្ឌគ្រប់គ្រាន់នោះទេ តុលាការនឹងលើកពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នរបស់ម្ចាស់បំណុលចោល ហើយដីកាសម្រេចលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននេះ ម្ចាស់បំណុលអាចធ្វើការប្ដឹងជំទាស់បាន បន្ទាប់ពីទទួលការបញ្ជូន។[124]

នៅក្នុងកាលៈទេសៈដែលតុលាការនៃបណ្ដឹងជំទាស់បានចេញសេចក្ដីសម្រេចអំពីពាក្យសុំតវ៉ា ចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន បណ្ដឹងជំទាស់មិនត្រូវយកមកអនុវត្តឡើយ[125] ពីព្រោះមានការបកស្រាយថាដីកាសម្រេចអំពីពាក្យសុំតវ៉ាដែលបានសម្រេចដោយតុលាការនៃបណ្ដឹងជំទាស់ បានបំពេញលក្ខខណ្ឌនៃការជម្រះក្ដី ០២ (ពីរ) ថ្នាក់រួចហើយ ទើបច្បាប់មិនអនុញ្ញាតឱ្យធ្វើការប្ដឹងជំទាស់ទៀតបាន ពោលបើម្ចាស់បំណុលបានដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននៅសាលាដំបូងរាជធានីភ្នំពេញ ហើយត្រូវសាលាដំបូងរាជធានីភ្នំពេញចេញសេចក្ដីសម្រេចលើកចោលពាក្យសុំនោះ បន្ទាប់មកម្ចាស់បំណុលបានដាក់ពាក្យ

[121] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦១ កថាខណ្ឌទី១ ចំណុច ក
[122] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៥៧ កថាខណ្ឌទី៨ និងមាត្រា៥៥៨ កថាខណ្ឌទី៣
[123] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦១ កថាខណ្ឌទី១
[124] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤៤
[125] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦១

បណ្តឹងជំទាស់នឹងសេចក្តីសម្រេចលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះ[126] ករណីសាលាឧទ្ធរណ៍ភ្នំពេញដែលជាតុលាការនៃបណ្តឹងជំទាស់ បានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ហើយកូនបំណុលបានដាក់ពាក្យសុំតវ៉ានឹងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ទៅសាលាឧទ្ធរណ៍ភ្នំពេញ ហេតុដូច្នេះនៅពេលសាលាឧទ្ធរណ៍ភ្នំពេញចេញសេចក្តីសម្រេចអំពីពាក្យសុំតវ៉ាហើយ ភាគីទាំងសងខាងមិនអាចដាក់ពាក្យបណ្តឹងជំទាស់ទៅតុលាការកំពូលបាននោះទេ ដោយហេតុថាដីកាសម្រេចនេះ បានបំពេញលក្ខខណ្ឌនៃប្រព័ន្ធនៃការជម្រះក្តី ០២ (ពីរ) ថ្នាក់រួចទៅហើយ។ ផ្ទុយទៅវិញបើបណ្តឹងអង្គសេចក្តីកំពុងចាត់ការនៅសាលាឧទ្ធរណ៍ ហើយសាលាឧទ្ធរណ៍បានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬដីកាសម្រេចដែលលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ភាគីអាចប្តឹងជំទាស់ទៅតុលាការកំពូលបាន ដោយសារតែតុលាការកំពូលបានដើរតួជាតុលាការនៃបណ្តឹងជំទាស់ ហើយដីកាសម្រេចទាំងអស់នេះមិនទាន់បំពេញលក្ខខណ្ឌនៃប្រព័ន្ធនៃការជម្រះក្តី ០២ (ពីរ) ថ្នាក់នៅឡើយ។

### ២.២. នីតិវិធីនៃបណ្តឹងជំទាស់

ក្នុងនីតិវិធីនៃបណ្តឹងជំទាស់ ត្រូវយកនីតិវិធីនៃការតវ៉ាចំពោះដីកាសម្រេចត្រូវយកមកអនុវត្តនៅក្នុងនីតិវិធីបណ្តឹងជំទាស់នេះ ដែលមានដូចខាងក្រោមនេះ៖

ក. **ការវិនិច្ឆ័យ៖** តុលាការត្រូវកំណត់ជាចាំបាច់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការសារសួរដែលភាគីទាំងសងអាចចូលរួមបាន។[127]

ខ. **ការបញ្ចប់ការវិនិច្ឆ័យ៖** តុលាការត្រូវសម្រេចបញ្ចប់ការវិនិច្ឆ័យ ដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យមួយ ឬប្រកាសនៅកាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការសាកសួរដែលភាគីទាំងសងខាងអាចចូលរួមបានថាបញ្ចប់ការវិនិច្ឆ័យ។[128]

គ. **ដីកាសម្រេច៖** តុលាការនឹងចេញដីកាសម្រេចអំពីបណ្តឹងជំទាស់ ដែលមានខ្លឹមសារដូចដីកាសម្រេចអំពីពាក្យសុំតវ៉ាផងដែរ រួមមានទទួលស្គាល់ ផ្លាស់ប្តូរ ឬលុបចោល។[129]

ឃ. **ការបញ្ជូន៖** បន្ទាប់ពីចេញដីកាសម្រេចអំពីបណ្តឹងជំទាស់ នីតិវិធីនៃការបញ្ជូនទៅភាគីទាំងសងខាងនឹងត្រូវយកមកអនុវត្តផងដែរ។[130]

---

[126] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤៤ កថាខណ្ឌទី២

[127] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦១ កថាខណ្ឌទី៣ និងមាត្រា៥៥២

[128] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦១ កថាខណ្ឌទី៣ និងមាត្រា៥៥៣

[129] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦១ កថាខណ្ឌទី៣ និងមាត្រា៥៥៤

[130] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦១ កថាខណ្ឌទី៣ និងមាត្រា៥៤៣

ង. **ការជំនុំជម្រះសាជាថ្មីចំពោះដីកាសម្រេច៖** ចំពោះដីកាសម្រេចដែលបានប្ដឹងឧបាស្រ័យតាមនីតិវិធីនៃបណ្ដឹងជំទាស់ ហើយបានចូលជាស្ថាពរ ភាគីអាចធ្វើការដាក់សុំឱ្យជំនុំជម្រះសាជាថ្មីចំពោះដីកាសម្រេចខាងលើនេះបាន។[131]

## ផ្នែកទី២៖ ការលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

ក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ា ឬដីកាសម្រេចអំពីបណ្ដឹងជំទាស់ តុលាការអាចសម្រេចលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន បើតុលាការយល់ឃើញថាដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន មិនមានភាពត្រឹមត្រូវ ហើយចំពោះការលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន តុលាការអាចដាក់លក្ខខណ្ឌឱ្យកូនបំណុលដាក់ប្រាតិភោគបាន[132] ប៉ុន្តែក្រៅពីការលុបដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នតាមអានុភាពនៃដីកាសម្រេចអំពីពាក្យសុំតវ៉ា ឬដីកាសម្រេចអំពីបណ្ដឹងជំទាស់ មានមូលហេតុសំខាន់ៗចំនួន ០២ (ពីរ) ទៀតដែលបណ្ដាលឱ្យដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវបានលុបចោល ដោយមូលហេតុនោះនឹងពន្យល់ឱ្យបានលម្អិតនៅចំណុច (១) **ការមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដី** និងចំណុច (២) **ការផ្លាស់ប្ដូរស្ថានភាព**។

### ១. ការមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដី

ការរឹបអូសជាបណ្ដោះអាសន្ន គឺជានីតិវិធីបណ្ដោះអាសន្នដែលម្ចាស់បំណុលអាចប្រើប្រាស់ ដើម្បីកម្រិតសិទ្ធិចាត់ចែងអចលនវត្ថុរបស់កូនបំណុល និងជានីតិវិធីបន្ទាប់បន្សំដើម្បីធានាការអនុវត្តដោយបង្ខំ បន្ទាប់ពីទទួលបានលិខិតអនុវត្តតាមរយៈបណ្ដឹងអង្គសេចក្ដីតែប៉ុណ្ណោះ ហេតុដូចនេះហើយការដាក់ពាក្យបណ្ដឹងអង្គសេចក្ដីជាកត្តាចាំបាច់បំផុតនៅក្នុងរឿងក្ដីរក្សាការពារ។ បន្ទាប់ពីចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នរួចមក តុលាការដែលបានចេញដីកាសម្រេចនេះ ត្រូវបង្គាប់ឱ្យម្ចាស់បំណុលដាក់ពាក្យបណ្ដឹងអង្គសេចក្ដី បន្ទាប់ពីនេះម្ចាស់បំណុលត្រូវដាក់លិខិតបញ្ជាក់ពីការដាក់ពាក្យបណ្ដឹងអង្គសេចក្ដីនោះ នៅក្នុងអំឡុងពេលដែលទទួលស្គាល់ថាសមរម្យ ដែលមានរយៈពេលមិនតិចជាង០២(ពីរ)សប្ដាហ៍ឡើយ តាមពាក្យសុំរបស់កូនបំណុល។[133] ការកំណត់នេះមានគោលបំណងឱ្យម្ចាស់បំណុលដាក់ពាក្យបណ្ដឹងអង្គសេចក្ដីឱ្យបានឆាប់រហ័ស និងទប់ស្កាត់ការខូចខាតយ៉ាងធ្ងន់ធ្ងរដល់កូនបំណុល ដោយសារស្ថានភាពដែលម្ចាស់បំណុលអាចនឹងទុកស្ថានភាពដែលមានដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នយូរអង្វែង ដោយមិនអើពើចំពោះការដាក់ពាក្យបណ្ដឹងអង្គសេចក្ដីឡើយ។ ក្នុងករណីដែលម្ចាស់បំណុលមិនដាក់លិខិតបញ្ជាក់ពីការដាក់បណ្ដឹងអង្គសេចក្ដី នៅក្នុងអំឡុងពេលដែលត្រូវបានកំណត់នោះទេ កូនបំណុលអាចដាក់ពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន លើសពីនេះទៅក្នុងករណីដែលពាក្យបណ្ដឹងអង្គសេចក្ដីត្រូវបានដក ឬលើកចោលក្រោយពេលដែលម្ចាស់បំណុល

[131] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦១ កថាខណ្ឌទី៣ និងមាត្រា៣១៧

[132] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៥៤ កថាខណ្ឌទី១ និងកថាខណ្ឌទី២

[133] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៥៧ កថាខណ្ឌទី១ និងកថាខណ្ឌទី២ និងកថាខណ្ឌទី៣

បានដាក់លិខិតបញ្ជាក់អំពីការដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ត្រូវចាត់ទុកថាលិខិតបញ្ជាក់នេះមិនបានដាក់។[134] គួរបញ្ជាក់ថាកិច្ចសន្យាមជ្ឈត្តកម្មអំពីអង្គសេចក្ដី ការចាប់ផ្ដើមនីតិវិធីមជ្ឈត្តកម្ម ត្រូវចាត់ទុកដូចការដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ប៉ុន្តែក្នុងករណីនីតិវិធីមជ្ឈត្តកម្មចប់ដោយមិនមានសេចក្ដីសម្រេចមជ្ឈត្តករទេ ម្ចាស់បំណុលត្រូវដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ក្នុងអំឡុងពេលដែលទទួលស្គាល់ថាសមរម្យ ដែលមានរយៈពេលមិនតិចជាង ០២ (ពីរ) សប្ដាហ៍ គិតចាប់ពីថ្ងៃដែលនីតិវិធីនៅមជ្ឈត្តកម្មនោះបានបញ្ចប់។[135] ដីកាសម្រេចអំពីពាក្យសុំទាមទារឱ្យលុបចោលដីការសម្រេចរឹបអូសជាបណ្ដោះអាសន្នត្រូវបញ្ជូនទៅភាគី[136] ក្នុងករណីភាគីណាមួយមិនពេញចិត្តអាចប្ដឹងជំទាស់នឹងដីកាសម្រេចនេះបាន។[137]

**២. ការផ្លាស់ប្ដូរស្ថានភាព**

មូលហេតុចុងក្រោយ គឺការផ្លាស់ប្ដូរស្ថានភាពមានន័យថា បើមានរលត់សិទ្ធិដែលត្រូវបានរក្សាការពារ ឬភាពចាំបាច់ក្នុងការរក្សាការពារ ឬការផ្លាស់ប្ដូរផ្សេងទៀតនៃស្ថានភាព តុលាការនៃបណ្ដឹងអង្គសេចក្ដី ឬតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន អាចលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នតាមពាក្យសុំរបស់កូនបំណុល ព្រមទាំងមានសេចក្ដីបញ្ជាក់ដំបូងអំពីហេតុដែលនាំឱ្យរលត់ផងដែរ។[138] ការផ្លាស់ប្ដូរស្ថានភាពនេះសំដៅលើកាលៈទេសៈចំនួនដូចជា សិទ្ធិទាមទារទាំងអស់ត្រូវទទួលបានការសង ឬកូនបំណុលក្លាយជាបុគ្គលមានទ្រព្យសម្បត្តិគ្រប់គ្រាន់ដើម្បីសង ឬករណីដែលកូនបំណុលបានដឹងពីអង្គហេតុដែលនាំឱ្យដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នមានភាពមិនត្រឹមត្រូវ ដោយកាលៈទេសៈទាំងអស់នេះសុទ្ធតែហេតុដែលនាំឱ្យសិទ្ធិដែលត្រូវបានរក្សាការពារត្រូវបានរលត់ ចំពោះដីកាសម្រេចអំពីពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នអាចប្ដឹងជំទាស់បាន។[139]

---

[134] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៥៧ កថាខណ្ឌទី៣ និងកថាខណ្ឌទី៤

[135] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៥៧ កថាខណ្ឌទី៥ និងកថាខណ្ឌទី៦

[136] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៥៧ កថាខណ្ឌទី៨

[137] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦១ កថាខណ្ឌទី១ ចំណុច ក

[138] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៥៨ កថាខណ្ឌទី១ និងកថាខណ្ឌទី៦

[139] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦១ កថាខណ្ឌទី១ ចំណុច ក

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាប្រធានបទស្តីពី **"នីតិវិធីចាត់ចែងរក្សាការពាររឹបអូសជាបណ្តោះអាសន្នអចលនវត្ថុ"** រួចមក យើងអាចសង្កេតបានថា ការរឹបអូសជាបណ្តោះអាសន្ន មានចរិតលក្ខណៈពិសេសចំនួន ០៤ (បួន) ដូចជា លក្ខណៈបណ្តោះអាសន្ន លក្ខណៈបន្ទាន់ លក្ខណៈបន្ទាប់បន្សំ និងលក្ខណៈសម្ងាត់ ដែលលក្ខណៈពិសេសទាំងអស់នេះហើយ បានធ្វើឱ្យនីតិវិធីរឹបអូសជាបណ្តោះអាសន្ន មានលក្ខណៈសម្បត្តិប្លែកខុសពីនីតិវិធីផ្សេងទៀត។ តុលាការអាចចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុរបស់កូនបំណុល បានទោះបីជាតុលាការនៃបណ្តឹងអង្គសេចក្តីមិនទាន់បានសម្រេចឱ្យច្បាស់លាស់ពីអត្ថិភាពនៃសិទ្ធិទាមទាររបស់ម្ចាស់បំណុលក៏ដោយ ថ្វីត្បិតតែការសម្រេចបែបនេះធ្វើឱ្យប៉ះពាល់ផលប្រយោជន៍ស្របច្បាប់របស់កូនបំណុលពិតមែន ប៉ុន្តែទស្សនៈម្ខាងទៀត គឺគ្រាន់តែដើម្បីការពារសិទ្ធិរបស់ម្ចាស់បំណុលតែប៉ុណ្ណោះ បើមិនបានសិក្សាឱ្យស៊ីជម្រៅពីនីតិវិធីនេះ កូនបំណុលអាចនឹងមើលឃើញថាច្បាប់បានលំអៀងទៅកាន់ម្ចាស់បំណុល ជាក់ស្តែងមិនមានភាពលំអៀងណាមួយកើតឡើងក្នុងវិស័យច្បាប់នោះទេ នីតិវិធីរឹបអូសជាបណ្តោះអាសន្ន ក៏បានបញ្ញត្តិពីហេតុដែលការពារកូនបំណុលពីការបាត់បង់ប្រយោជន៍ស្របច្បាប់ ដោយសារការអនុវត្តរឹបអូសជាបណ្តោះអាសន្ន រួមមានការបង្គាប់ម្ចាស់បំណុលឱ្យដាក់ប្រាតិភោគ ការដាក់ប្រាក់រំដោះ ដែលសុទ្ធសឹងតែជាយន្តការប្រើប្រាស់ក្នុងគោលបំណងការពារកូនបំណុល ឱ្យជៀសផុតពីការប្រើប្រាស់សិទ្ធិទាំងបំពានរបស់ម្ចាស់បំណុលតែប៉ុណ្ណោះ ហើយការដាក់ប្រាក់រំដោះ មិនត្រឹមតែការពារប្រយោជន៍កូនបំណុលពីការរឹបអូសជាបណ្តោះអាសន្នទេ ប្រព័ន្ធនេះក៏បានធ្វើឱ្យម្ចាស់បំណុលស្ងប់ចិត្តថានឹងទទួលបានការសងនៅពេលឈ្នះបណ្តឹងអង្គសេចក្តីផងដែរ។

ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន មិនចាំបាច់បំពេញលក្ខខណ្ឌដូចការអនុវត្តដោយបង្ខំនោះទេ ដោយការអនុវត្តរឹបអូសជាបណ្តោះអាសន្ន មិនត្រូវការរូបមន្តអនុវត្តនោះទេ ហើយការអនុវត្តរឹបអូសជាបណ្តោះអាសន្ន អាចធ្វើទៅបានមុនពេលដែលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវបញ្ជូនទៅដល់កូនបំណុល ការប្បញ្ញត្តិបែបនេះដើម្បីជៀសវាងសកម្មភាពដែលកូនបំណុលដឹងខ្លួនមុន ហើយបានចាត់ចែងអចលនវត្ថុទៅតតិយជន ដែលនាំឱ្យដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវប្រែក្លាយជាអស់ន័យ ហើយម្ចាស់បំណុលនឹងនៅតែខូចខាតប្រយោជន៍ស្របច្បាប់របស់ខ្លួនដដែល។ សូមបញ្ជាក់ម្តងទៀតថា នីតិវិធីរឹបអូសជាបណ្តោះអាសន្ន ជានីតិវិធីបណ្តោះអាសន្នដើម្បីធានាឱ្យការអនុវត្តបង្ខំនាពេលអនាគតអាចធ្វើទៅបានដោយរលូន និងគ្មានឧបសគ្គមករារាំងនាពេលអនុវត្តតែប៉ុណ្ណោះ ហេតុនេះទើបយើងឃើញថានីតិវិធីរឹបអូសជាបណ្តោះអាសន្ន មានលក្ខណៈស្ទើរតែដូចគ្នានឹងនីតិវិធីអនុវត្តដោយបង្ខំ ទាំងទ្រឹស្តី និងការអនុវត្ត។ ជាការពិតណាស់នៅក្រោយពេលអនុវត្តរឹបអូសជាបណ្តោះអាសន្នចប់ ហើយលក្ខខណ្ឌនៃការអនុវត្តដោយបង្ខំត្រូវបានបំពេញនោះ ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ត្រូវបំលែងទៅជាការអនុវត្តដោយបង្ខំវិញបានត្រឹមទំហំនៃការអនុវត្ត មានន័យថានីតិវិធីបន្ទាប់គឺអាចអនុវត្ត

លក់ដោយបង្ខំតាមផ្លូវតុលាការយកតែម្តង ដោយមិនចាំបាច់ដើរនីតិវិធីអនុវត្តដោយបង្ខំសាជាថ្មីវិញនោះទេ ដូច្នេះ បើម្ចាស់បំណុលជ្រើសរើសយកនីតិវិធីរឹបអូសជាបណ្តោះអាសន្នមកប្រើប្រាស់នោះ ម្ចាស់បំណុលរឹតតែចំណេញពេលវេលានៅពេលខ្លួនឈ្នះបណ្តឹងអង្គសេចក្តី ហើយធានាដល់ការអនុវត្តដោយបង្ខំនាពេលអនាគត។ ហើយការអនុវត្តរឹបអូសជាបណ្តោះអាសន្នអាចត្រូវបានតុលាការសម្រេចឱ្យផ្អាក ឬលុបចោល ប្រសិនបើមានមូលហេតុត្រឹមត្រូវតាមច្បាប់កំណត់ ដោយក្រឡាបញ្ជីត្រូវធ្វើលិខិតផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ទៅកាន់រដ្ឋបាលសុរិយោដីដែលមានសមត្ថកិច្ចលុបការចុះបញ្ជីរឹបអូសជាបណ្តោះអាសន្ន។

នៅពេលតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន នៅដំណាក់កាលដំបូងបំផុតកូនបំណុលអាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ទៅតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន បន្ទាប់ពីទទួលពាក្យសុំតវ៉ា តុលាការនឹងកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការសាកសួរដែលភាគីទាំងសងខាងអាចចូលរួមបាន បន្ទាប់ពីបញ្ចប់នីតិវិធីតុលាការនឹងចេញដីកាសម្រេចអំពីពាក្យសុំតវ៉ា។ ក្នុងករណីភាគីមិនពេញចិត្តចំពោះដីកាសម្រេចអំពីពាក្យសុំតវ៉ា ភាគីអាចដាក់បណ្តឹងជំទាស់ទៅតុលាការនៃបណ្តឹងជំទាស់បាន មិនខុសគ្នានោះទេតុលាការនៃបណ្តឹងជំទាស់នឹងកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការសាកសួរដែលភាគីទាំងសងខាងអាចចូលរួមបាន ហើយតុលាការនឹងចេញដីកាសម្រេចអំពីបណ្តឹងជំទាស់ ដែលមានអត្ថន័យទទួលស្គាល់ ផ្លាស់ប្តូរ ឬលុបចោល។ គួរបញ្ជាក់ដែរថាក្រៅពីការលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដោយសារដីកាសម្រេចអំពីពាក្យសុំតវ៉ា ឬដីកាសម្រេចអំពីបណ្តឹងជំទាស់ នៅមានមូលហេតុពីរទៀតដែលធ្វើឱ្យដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវបានលុបចោល រួមមានការលុបដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដោយសារមិនដាក់បណ្តឹងអង្គសេចក្តី ជាអាទិ៍ ឬការលុបដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដោយសារការផ្លាស់ប្តូរស្ថានភាព។

សរុបសេចក្តីមក ថ្វីត្បិតតែនីតិវិធីរឹបអូសជាបណ្តោះអាសន្ន ជានីតិវិធីមានលក្ខណៈមិនមានភាពអចិន្ត្រៃយ៍ពិតមែន ប៉ុន្តែនីតិវិធីនេះបានផ្តល់មកវិញជាលទ្ធផលជាទីគាប់ចិត្ត ហើយមិនត្រូវការពេលវេលាយូរសម្រាប់អនុវត្តឡើយ ទោះបីជាលំហូរនីតិវិធីមានភាពលំបាក ប៉ុន្តែបើសិក្សាស្វែងយល់ឱ្យបានស៊ីជម្រៅ នោះអ្នកអនុវត្តនឹងដឹងច្បាស់ពីអត្ថប្រយោជន៍នៃការប្រើប្រាស់នីតិវិធីនេះ សម្រាប់ដោះស្រាយបញ្ហាដែលកើតមានឡើងក្នុងសង្គមរស់នៅបច្ចុប្បន្ន ហើយនីតិវិធីនេះពិតជាដើរតួយ៉ាងសំខាន់ក្នុងការការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ភាគីបើប្រើប្រាស់ឱ្យបានត្រឹមត្រូវស្របតាមអង្គហេតុ និងស្ថានភាពជាក់ស្តែងនីមួយៗ។ ក្នុងនាមជាអ្នកសិក្សាផ្នែកនីតិសាស្ត្រមួយរូប យើងគប្បីសិក្សាពីរបបគតិយុត្តនៃឯកសារច្បាប់នីមួយៗឱ្យបានច្បាស់លាស់សិន មុននឹងប្រើប្រាស់ជាផ្លូវការ ដើម្បីជៀសវាងពីការបង់បាត់ ឬខូចខាតប្រយោជន៍ស្របច្បាប់របស់បុគ្គលណាម្នាក់ ដោយសារការប្រើប្រាស់មិនបានត្រឹមត្រូវ។

# អនុសាសន៍

# អនុសាសន៍

នៅចុងបញ្ចប់នៃកិច្ចការស្រាវជ្រាវនេះ យើងខ្ញុំមានយោបល់មួយចំនួនពាក់ព័ន្ធនឹងប្រធានបទខាងលើនេះ ដោយយើងបានដឹងរួចហើយថា **"នីតិវិធីរឹបអូសជាបណ្ដោះអាសន្ន"** ជានីតិវិធីមួយដែលបានជួយសម្រួលយ៉ាងខ្លាំងដល់នីតិវិធីអនុវត្តដោយបង្ខំ ប៉ុន្តែទន្ទឹមនឹងការប្រើប្រាស់បានត្រឹមត្រូវរបស់អ្នកអនុវត្តច្បាប់ ក៏នៅមានប្រជាជនទូទៅមួយចំនួនធំនៅមិនទាន់ទទួលបានការយល់ដឹងពាក់ព័ន្ធនឹងនីតិវិធីនេះឱ្យបានច្បាស់លាស់នោះទេ និងមិនបានប្រើប្រាស់នីតិវិធីនេះឱ្យបានត្រឹមត្រូវស្របតាមកាលៈទេសៈនៃអង្គហេតុនីមួយៗនៅឡើយ ហេតុដូច្នេះក្នុងនាមយើងខ្ញុំជាអ្នកសិក្សាផ្នែកច្បាប់សូមធ្វើការផ្ដល់មតិយោបល់មួយចំនួនចំពោះបញ្ហាទាំងនេះដូចតទៅ៖

**ក. ក្រសួងយុត្តិធម៌**

- បន្តពង្រឹងសកម្មភាពផ្សព្វផ្សាយនីតិវិធីរឹបអូសជាបណ្ដោះអាសន្ននេះជូនសារធារណៈជន តាមរយៈប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ដូចជាកម្មវិធីទូរទស្សន៍ វិទ្យុ កាសែតជាដើមបន្តទៀត។
- បន្តពង្រឹងសមត្ថភាពដល់អ្នកអនុវត្តច្បាប់ និងអ្នកមានវិជ្ជាជីវៈ តាមរយៈការបង្កើតឱ្យមានជាសិក្ខាសាលា កម្មវិធីចំណេះដឹងផ្លូវច្បាប់ជាដើម។

**ខ. ស្ថាប័នតុលាការ**

- គួរតែសាកសួរម្ចាស់បំណុលឱ្យអស់សេចក្ដី មុនសម្រេចលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬសម្រេចច្រានចោលការទាមទារមួយចំនួនរបស់ម្ចាស់បំណុលពីព្រោះក្នុងករណីមួយចំនួន ម្ចាស់បំណុលមិនបានបញ្ជាក់ឱ្យអស់សេចក្ដីពីសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ព្រមទាំងភាពចាំបាច់ នៅក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដោយសារបញ្ហាចំណេះដឹងពាក់ព័ន្ធនឹងការអនុវត្តនីតិវិធី។
- មុនពេលតុលាការសម្រេចចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នអចលនវត្ថុ តុលាការក៏ត្រូវសាកសួរម្ចាស់បំណុលឱ្យអស់សេចក្ដីដែរ ដើម្បីជៀសវាងពីស្ថានភាពដែលទំហំនៃការរឹបអូសជាបណ្ដោះអាសន្ន ធំជាងទំហំនៃសិទ្ធិលើបំណុលដែលម្ចាស់បំណុលមានលើកូនបំណុល ដែលជាហេតុនាំឱ្យប៉ះពាល់ដល់ប្រយោជន៍ស្របច្បាប់របស់កូនបំណុល។

ទាំងអស់នេះគ្រាន់តែជាមតិយោបល់របស់ក្រុមយើងខ្ញុំ ដែលជាការតបទៅនឹងការសិក្សាទៅលើប្រធានបទ **"ការចាត់ចែងរក្សាការពាររឹបអូសបណ្ដោះអាសន្នអចលនវត្ថុ"** ចំពោះការកែតម្រូវ ឬពិនិត្យលើចំណុចទាំងអស់នេះ គឺជាចំណាត់ការរបស់ស្ថាប័នជំនាញ។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងព្រះរាជក្រម

- ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣១, ០៨ ធ្នូ ២០០៧។
- ក្រមនីតិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។
- ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១។

## ២. អនុក្រឹត្យ

- អនុក្រឹត្យស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយ សម្រាប់ការផ្តល់សេវារដ្ឋបាល នៅរដ្ឋបាលថ្នាក់ក្រោមជាតិ, លេខ ១៨អនក្របក, ០៨ កុម្ភៈ ២០១៧។

## ៣. ប្រកាស

- ប្រកាសអន្តរក្រសួងរវាងក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី, លេខ ៥៩ប្រកដនស/១១, ០៣ ឧសភា ២០១១។
- ប្រកាសអន្តរក្រសួងរវាងក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី, លេខ ៣០កយដនសប្រក/១៣, ២៩ មករា ២០១៣។
- ប្រកាសអន្តរក្រសួងរវាងក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសចំពោះអចលនវត្ថុ ដែលមិនទាន់បានចុះបញ្ជី, លេខ ២១៤ ប្រកដនស, ២១ វិច្ឆិកា ២០១៤។
- ប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង, លេខ ៣៥៦សហវប្រក, ២៦ មីនា ២០១៩។

## ៤. សារាចរណែនាំ

- សារាចររបស់ក្រសួងយុត្តិធម៌ ស្តីពីសេចក្តីណែនាំអំពីនីតិវិធីរដ្ឋប្បវេណី, លេខ ០៤សរច៨៤, ០៨ កញ្ញា ១៩៨៤។

## ៥. ឯកសារផ្សេងទៀត

- ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី. *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី,* ភាគ២ គន្លឹ៤. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០។

- ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី. *សេចក្តីកំណត់មាត្រានីមួយនៃក្រមនីតិវិធីរដ្ឋប្បវេណី.* ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៧។
- គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ, ក្រសួងយុត្តិធម៌, រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច. *មេរៀនស្តីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី,* ភាគ១. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១៥។
- ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី. *សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី៖ ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ,* ភាគ២. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩។
- គ្រូបង្គោលនៃសាលាភូមិន្ទចៅក្រម, នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃវិទ្យាស្ថានស្រាវជ្រាវ និងបណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌ប្រទេសជប៉ុន. *សៀវភៅស្តីពីស្តីពីការពន្យល់អំពីបណ្តឹងតវ៉ាការតវ៉ា និងបណ្តឹងជំទាស់ ទាក់ទងនឹងការអនុវត្ត.* ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១១។
- គ្រូបង្គោលនៃសាលាភូមិន្ទចៅក្រម, នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃវិទ្យាស្ថានស្រាវជ្រាវ និងបណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌ប្រទេសជប៉ុន. *សៀវភៅស្តីពីនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ.* ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០០៩។
- ក្រុមការងារនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ. *ស្លាយមេរៀនស្តីពីការផ្អាក ការលុបចោល នីតិវិធីនៃការអនុវត្តដោយបង្ខំ។*
- កម្មវិធីៈ ខ្ញុំស្វែងយល់ពីច្បាប់, ឧទ្ទេសនាមដោយលោកចៅក្រម ចាយ ច័នតារាវណ្ណ. *សិក្ខាសាលាស្តីពីបញ្ហា និងដំណោះស្រាយក្នុងការអនុវត្តនីតិវិធីអនុវត្តដោយបង្ខំ.* ភ្នំពេញ, ២០២០។
- រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ឧទ្ទេសនាមដោយលោកជំទាវ ចាំង ស៊ីណាត. *ស្លាយមេរៀនស្តីពីការចាត់ចែងរក្សាការពារ។*
- វិភាគទានច្បាប់, ឧទេសនាមដោយលោកមេធាវី អ៊ីវ ប៉ូលី. *សិក្ខាសាលាស្តីពីកិច្ចពិភាក្សាស្តីពីខ្លឹមសារនៃដីកាសម្រេចរក្សាការពារ,* ភ្នំពេញ៖ វិភាគទានច្បាប់, ២០២១។
- ជំនាញការនៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ Mr. MAEDA YUTA. *ស្លាយមេរៀនស្តីពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី.* ផ្នែកទី៤។
- ក្រសួងយុត្តិធម៌, នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ, វិទ្យាសាស្ត្រស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់, ឧទេសនាមដោយសាស្ត្រចារ្យ YUKAWA RYO. *ស្លាយមេរៀនស្តីពីការរឹបអូសជាបណ្តោះអាសន្ននូវអចលនវត្ថុ។*